ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា



# របាយការណ៍ស្តីពីប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនៅកម្ពុជា

រៀបចំដោយ

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ខែមីនា ឆ្នាំ២០២០

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍ស្តីពីប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនៅកម្ពុជា

រៀបចំដោយ

គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

ខែមីនា ឆ្នាំ២០២០

# មាតិកា


*អារម្ភកថា*

*ខ្លឹមសារសង្ខេបប្រតិបត្តិ* i-vi

*ជំពូកទី១ - សេចក្តីផ្តើម - បរិការណ៍នៃភាពជាដៃគូ* ១-៣

*ជំពូកទី២ - ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍* ៤

វឌ្ឍនភាពស្តីពីភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ ៤

យន្តការភាពជាដៃគូថ្មី ១០

*ជំពូកទី៣ - ការវិវត្តនៃហិរញ្ញប្បទានសហប្រតិបត្តិការ* ១២

ការវិវត្តនៃហិរញ្ញប្បទានសហប្រតិបត្តិការ ១២

ការប្រែប្រួលសំខាន់ៗនៃការបើកផ្តល់ហិរញ្ញប្បទាន ១៥

ការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ ១៥

ទម្រង់ និងទំហំនៃការបើកផ្តល់ឥណទានសម្បទាន ឆ្នាំ២០១៤-២០២១ ១៧

ការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះ ១៨

ការគាំទ្រដល់រាជធានី-ខេត្ត ឆ្នាំ២០១៧-២០១៩ ២០

ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ជាតិ ២១

*ជំពូកទី៤ - ស្ថានភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងអន្តរវិស័យ* ២៥

ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់លើកកម្ពស់សមភាពយេនឌ័រ ២៥

ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការអភិវឌ្ឍវិស័យឯកជន ២៧

ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការប្រែប្រួលអាកាសធាតុ ២៩

វិធានការសម្រាប់ពង្រឹងការកត់ត្រាហិរញ្ញប្បទានរបស់អន្តរវិស័យ ៣១

*ជំពូកទី៥ - ការគាំទ្រហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា* ៣២

តួនាទីហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍
វិស័យឧស្សាហកម្មកម្ពុជា ៣២

ការវិភាគហិរញ្ញប្បទានគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៨-២០១៩ ៣២

ហិរញ្ញប្បទានសហប្រតិបត្តិការគាំទ្រវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស
និងវិជ្ជាជីវៈនៅកម្ពុជា ៣៧

*ជំពូកទី៦ - ការចាកចេញពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួចរបស់កម្ពុជា* ៣៩

អត្ថប្រយោជន៍ និងភាពអនុគ្រោះសម្រាប់កម្ពុជាក្នុងឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួច ៣៩

វឌ្ឍនភាពរបស់កម្ពុជាក្នុងការឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ៤២

ផលប៉ះពាល់នៃការឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ៤៣

គោលនយោបាយសំខាន់ៗសម្រាប់ការឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច ៤៥

*ជំពូកទី៧ - ការគ្រប់គ្រងដោយផ្តោតលើលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព* ៥០
ការវិវត្តបន្ទាប់ពីអភិក្រមស្តីពីការគ្រប់គ្រងដោយផ្តោតលើលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ ៥០
ការអនុវត្តអភិក្រមដោយផ្តោតលើលទ្ធផលនៅកម្ពុជា ៥១
ការអនុវត្តគោលការណ៍ស្តីពីការគ្រប់គ្រងដោយផ្តោតលើលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព
នៅកម្ពុជា (MfSDR) ៥២
*ជំពូកទី៨ - សេចក្តីសន្និដ្ឋាន* ៥៣

## បញ្ជីតារាង


២.១- សូចនាករស្ដីពីស័ក្ដិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ តាមដៃគូអភិវឌ្ឍន៍ ៩
២.២-គោលដៅទី ១៧ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ១០
៣.១-ការបើកផ្ដល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ១៤
៣.២-ការបើកផ្ដល់ហិរញ្ញប្បទានតាមវិស័យ ឆ្នាំ២០១១-២០២១ ១៦
៣.៣-ការបើកផ្ដល់ និងសកម្មភាពរបស់ដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារ
បច្ចេកទេសចម្រុះ ឆ្នាំ២០១៧-២០២១ ១៩
៣.៤-ដៃគូអភិវឌ្ឍន៍សំខាន់ៗក្នុងក្រុមការងារបច្ចេកទេសចម្រុះ ២០
៣.៥-ការបើកផ្ដល់តាមរាជធានី-ខេត្ត ឆ្នាំ២០១៧-២០១៩ ២១
៣.៦-ការបើកផ្ដល់របស់ដៃគូអភិវឌ្ឍន៍សំខាន់ៗតាមរាជធានី-ខេត្ត ឆ្នាំ២០១៩ ២១
៣.៧-ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ ឆ្នាំ២០១៧-២០១៩ ២២
៣.៨-ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ ឆ្នាំ២០១៧-២០១៩ ២៣
៤.១-វិស័យសម្គាល់បន្ថែម ២៥
៤.២-ការបញ្ជ្រាបសមភាពយេនឌ័រតាមវិស័យ ឆ្នាំ២០១៨-២០១៩ ២៦
៤.៣-ការបញ្ជ្រាបសមភាពយេនឌ័ររបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៨-២០១៩ ២៧
៤.៤-ការបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជនតាមវិស័យ ឆ្នាំ២០១៨-២០១៩ ២៨
៤.៥-ការបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជនរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៨-២០១៩ ២៩
៤.៦-ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុតាមវិស័យ ឆ្នាំ២០១៨-២០១៩ ៣០
៤.៧-ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៨-២០១៩ ៣១
៥.១-ហិរញ្ញប្បទានគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៨-២០១៩ ៣៣
៥.២-ធនធានរយៈពេលមធ្យមឆ្នាំ២០១៥-២០១៩ គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ៣៤
៥.៣-ធនធានរយៈពេលមធ្យមឆ្នាំ២០១៥-២០១៩ គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ៣៥
៥.៤-ការបញ្ជ្រាបគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មរបស់
ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៨-២០១៩ ៣៦
៥.៥-ការបញ្ជ្រាបការគាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម
តាមវិស័យឆ្នាំ២០១៨-២០១៩ ៣៧
៥.៦-ធនធានរបស់ដៃគូអភិវឌ្ឍន៍គាំទ្រដល់វិស័យអប់រំបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ ៣៨
៦.១-លក្ខខណ្ឌវិនិច្ឆ័យសម្រាប់កម្ពុជាឆ្លងផុតពីប្រទេសមានការអភិវឌ្ឍតិចតួច ៤៣
៦.២-កំណើនអត្រាពន្ធជាមធ្យមបន្ទាប់ពីការឆ្លងផុតពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ៤៥
៧.១-គោលការណ៍ស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ដោយផ្ដោតលើលទ្ធផល ៥០

## បញ្ជីគំនូរ


២.១- ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៨ ៥

២.២- ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៩ ៥

២.៣-ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ ឆ្នាំ២០១៨ ៦

២.៤- ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ ឆ្នាំ២០១៩ ៦

២.៥- ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ ឆ្នាំ២០១៨ ៦

២.៦- ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ ឆ្នាំ២០១៩ ៦

២.៧- ភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទានឆ្នាំ២០១៨ ៧

២.៨- ភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទានឆ្នាំ២០១៩ ៧

៣.១- ការបើកផ្តល់ហិរញ្ញប្បទាន ឆ្នាំ២០១០-២០២១ ១៣

៣.២ -ហិរញ្ញប្បទានសម្រាប់ប្រជាជនម្នាក់ និងអនុបាតហិរញ្ញប្បទានធៀបនឹង ផ.ស.ស ឆ្នាំ២០១០-២០២១ ១៣

៣.៣- ដៃគូផ្តល់ហិរញ្ញប្បទានសំខាន់ៗ ឆ្នាំ២០១៦-២០២១ ១៥

៣.៤- ទំហំហិរញ្ញប្បទានដែលផ្តល់ដោយដៃគូសំខាន់ៗ ឆ្នាំ២០១៦-២០២១ ១៥

៣.៥- អនុបាតនៃការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ ឆ្នាំ២០១៤-២០២១ ១៧

៣.៦- ទម្រង់នៃការបើកផ្តល់របស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៤-២០២១ ១៨

៣.៧- ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ ឆ្នាំ២០១៧-២០១៩ ២៣

៣.៨- ភាគរយនៃធនធានរបស់អង្គការមិនមែនរាជរដ្ឋាភិបាល ឆ្នាំ២០១៧-២០១៩ ២៣

៦.១- ការនាំចេញរបស់កម្ពុជា ៤១


## បញ្ជីឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី១: ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមដៃគូអភិវឌ្ឍន៍ និងតាមវិស័យ ឆ្នាំ២០១៧

ឧបសម្ព័ន្ធទី២: ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមដៃគូអភិវឌ្ឍន៍ និងតាមវិស័យ ឆ្នាំ២០១៨

ឧបសម្ព័ន្ធទី៣: ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមដៃគូអភិវឌ្ឍន៍ និងតាមវិស័យ ឆ្នាំ ២០១៩

ឧបសម្ព័ន្ធទី៤: ការបើកផ្តល់ និងការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១០-២០២១

ឧបសម្ព័ន្ធទី៥: ការបើកផ្តល់ និងការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការតាមវិស័យ ឆ្នាំ២០១០-២០២១

ឧបសម្ព័ន្ធទី៦: ការបើកផ្តល់ និងការព្យាករណ៍ហិរញ្ញប្បទានសហប្រតិបត្តិការតាមរាជធានី និងខេត្ត ឆ្នាំ២០១៧-២០២០

# អារម្ភកថា

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលបានសម្រេចវឌ្ឍនភាព និងសមិទ្ធផលសំខាន់ៗ ក្នុងការលើកកម្ពស់លទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ។ រាជរដ្ឋាភិបាលសម្រេចជោគជ័យយ៉ាងត្រចះត្រចង់ ក្នុងការរក្សាបានសន្តិភាពពេញលេញ, សន្តិសុខ, ស្ថិរភាពនយោបាយ, ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចដោយប្រុងប្រយ័ត្ន និងការកែទម្រង់អភិបាលកិច្ច ដូចជាការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការកែទម្រង់រដ្ឋបាលសាធារណៈ និងការកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលធ្វើឱ្យប្រសើរឡើងនូវគុណភាពសេវាសាធារណៈ និងការបែងចែកផលលាភនៃការអភិវឌ្ឍសេដ្ឋកិច្ចរឹងមាំ ប្រកបដោយបរិយាប័ន្ន សម្រាប់សុខុមាលភាពរបស់ប្រជាជនគ្រប់រូប ។ សមិទ្ធផលទាំងនេះបានឆ្លុះបញ្ចាំងអំពីភាពជាម្ចាស់, សមត្ថភាព និងភាពជាអ្នកដឹកនាំខាងនយោបាយដ៏រឹងមាំរបស់រាជរដ្ឋាភិបាល ក្នុងការតម្រង់ទិសភាពជាដៃគូក្នុងការអភិវឌ្ឍ ដើម្បីឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ។

ផ្អែកលើសមិទ្ធផលដ៏ត្រចះត្រចង់ទាំងនេះ រាជរដ្ឋាភិបាលនីតិកាលទី ៦ នៃរដ្ឋសភា បានដាក់ចេញនូវកម្មវិធីនយោបាយ ដែលបានកំណត់នូវគោលដៅជាយុទ្ធសាស្ត្រ និងគោលនយោបាយអាទិភាពច្បាស់លាស់ ក៏ដូចជាវិធានការជាក់ស្តែង សម្រាប់អនុវត្តចាប់ពីឆ្នាំ២០១៩ តទៅ ។ យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ សម្រាប់កំណើន, ការងារ, សមធម៌ និងប្រសិទ្ធភាព ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល បានផ្តល់នូវទស្សនវិស័យច្បាស់លាស់ ដើម្បីជំរុញការអភិវឌ្ឍកម្ពុជាឈានឆ្ពោះទៅសម្រេចចក្ខុវិស័យ ឆ្នាំ២០៣០ និង២០៥០ ។ រីឯផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ ដែលបានបញ្ចូលគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា គឺជាក្របខណ្ឌគោលនយោបាយសម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ ។

ដើម្បីឈានទៅសម្រេចចក្ខុវិស័យ ឆ្នាំ២០៣០ និង២០៥០ រាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ សម្រាប់លើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច, ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព ដែលតភ្ជាប់សេដ្ឋកិច្ចកម្ពុជាទៅនឹងខ្សែចង្វាក់តម្លៃសកល និងតំបន់ ។

ការសម្រេចបានគោលដៅប្រកបដោយមហិច្ឆតា ទាមទារការលើកកម្ពស់ប្រសិទ្ធភាពនៃភាពជាដៃគូជាមួយគ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់ ។ កម្ពុជាបន្តពង្រឹងវឌ្ឍនភាពកន្លងមក និងបានត្រៀមខ្លួនជាស្រេច ដើម្បីដោះស្រាយបញ្ហាប្រឈម និងក្តាប់ជាប់នូវកាលានុវត្តភាពថ្មីៗក្នុងជវភាពតំបន់ និងសកលលោក ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ដើម្បីបន្តលើកកម្ពស់ស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ និងអនុវត្តបណ្តាគោលការណ៍ស្តីពីភាពជាដៃគូ ស្របតាមបរិការណ៍កម្ពុជា ព្រមទាំងអនុវត្តការប្តេជ្ញា និងបទដ្ឋានសកលនានា ។

គោលដៅចម្បងនៃរបាយការណ៍ស្ដីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងភាពជាដៃគូ ឆ្នាំ២០១៨-២០១៩ ដែលបានរៀបចំដោយគណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា (ក.អ.ក/គ.ជ.នា) គឺការតាមដានវឌ្ឍនភាព នៃភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ និងការវិវត្តនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា ដោយផ្អែកលើសក្ខីកម្មជាក់ស្ដែង ។ របាយការណ៍នេះបានផ្ដល់មូលដ្ឋានសម្រាប់រាជរដ្ឋាភិបាលបន្តពង្រឹងប្រសិទ្ធភាពនៃភាពជាដៃគូ ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ ក្នុងក្របខណ្ឌនៃរបៀបវារៈស្ដីពីកិច្ចអភិវឌ្ឍន៍ ប្រកបដោយចីរភាព ឆ្នាំ២០៣០ ក៏ដូចជាការត្រៀមរបស់កម្ពុជាសម្រាប់ចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច នាបណ្ដាឆ្នាំខាងមុខ ។

ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះឯកឧត្តមរដ្ឋមន្ត្រីប្រតិភូ **ឈឿង យ៉ាណារ៉ា** អគ្គលេខាធិការ ក.អ.ក/គ.ជ.នា និង សហការី ដែលបានរៀបចំរបាយការណ៍វិភាគនេះ ។ ខ្ញុំជឿជាក់ថា ការវិភាគទាំងឡាយក្នុងរបាយការណ៍នេះនឹងផ្ដល់ ព័ត៌មានសំខាន់ៗ សម្រាប់អ្នករៀបចំគោលនយោបាយ និងតួអង្គអភិវឌ្ឍន៍ទាំងអស់ និងជាមូលដ្ឋានសម្រាប់បន្តពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍នៅកម្ពុជា ។

ថ្ងៃ ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ខែមីនា ឆ្នាំ២០២០

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**

**អនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**ជិន ប៊ុនស៊ាន**

# ខ្លឹមសារសង្ខេបប្រតិបត្តិ

ក្នុងរយៈពេលជាងពីរទសវត្សរ៍នេះ រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលសំខាន់ៗជាច្រើនក្នុងកិច្ចអភិវឌ្ឍន៍ជាតិ ទន្ទឹមនឹងការធានាបានសន្តិភាព និងសន្តិសុខទូទាំងប្រទេស, ស្ថិរភាពនយោបាយ, ការលើកកម្ពស់កំណើនប្រកបដោយចីរភាព និងធន់នឹងវិបត្តិ, ការកាត់បន្ថយភាពក្រីក្រ និងការបង្កើតការងារជូនប្រជាជន ព្រមទាំងការពង្រឹងសមត្ថភាពស្ថាប័នសាធារណៈ ។ ជាក់ស្តែង ក្នុងឆ្នាំ២០១៨ កំណើនសេដ្ឋកិច្ចសម្រេចបាន ៧,៥% ដែលជាកម្រិតខ្ពស់បំផុតក្នុងរយៈពេល ១០ឆ្នាំចុងក្រោយនេះ និង ៧,១% ក្នុងឆ្នាំ២០១៩ ដែលធ្វើឱ្យភាពក្រីក្របានធ្លាក់ចុះមកនៅត្រឹមក្រោម ១០% និងបានបង្កើនចំណូលរបស់ប្រជាជនម្នាក់ដល់ ១.៥៤៨ ដុល្លារ ក្នុងឆ្នាំ២០១៨ និងប្រមាណ ១.៦៧៤ ដុល្លារ ក្នុងឆ្នាំ២០១៩ ។

ដើម្បីដោះស្រាយបញ្ហាប្រឈមដែលលេចឡើងថ្មីៗ និងដើម្បីឈានទៅសម្រេចចក្ខុវិស័យ ឆ្នាំ២០៣០ និងឆ្នាំ២០៥០ រាជរដ្ឋាភិបាលបានចាត់វិធានការជាក់ស្តែង សម្រាប់ឆ្លើយតបទៅនឹងការវិវត្តដ៏ឆាប់រហ័សនៃបរិការណ៍អភិវឌ្ឍន៍សកល ។ ក្នុងន័យនេះ យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ដែលជារបៀបវារៈអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច បានបញ្ជាក់អំពីតួនាទីដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ និងបានកំណត់ផែនទីចង្អុលផ្លូវ ដើម្បីក្តាប់យកនូវកាលានុវត្តភាព និងដោះស្រាយបញ្ហាប្រឈមនានា ។ រីឯផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ ដែលបានបញ្ចូលគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា គឺជាឧបករណ៍សម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និងការកែទម្រង់ពាក់ព័ន្ធនានា ដែលជួយពង្រឹងសមត្ថភាពរបស់រាជរដ្ឋាភិបាល ក្នុងការកៀរគរ និងការគ្រប់គ្រងធនធាន សម្រាប់គាំទ្រការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និងគោលដៅអភិវឌ្ឍន៍ជាតិ ។

## *វឌ្ឍនភាពស្តីពីភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍*

រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពសំខាន់ៗគួរឱ្យកត់សម្គាល់ ក្នុងការអនុវត្តការប្តេជ្ញាស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ និងភាពជាដៃគូសកល ដែលបានឯកភាពនៅទីក្រុងប៊ូសាន ក្នុងឆ្នាំ២០១១ ។ តាមរយៈក្របខណ្ឌលទ្ធផលនៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ រាជរដ្ឋាភិបាលបានធ្វើស្ថាប័ននីយកម្មការប្តេជ្ញាស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ជាតិ និងសកល ដែលផ្សារភ្ជាប់ទៅនឹងគោលការណ៍ភាពជាដៃគូសកល, ក្របខណ្ឌតាមដាននៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និងយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ រាជរដ្ឋាភិបាលបានពិនិត្យ និងកែសម្រួលសេចក្តីណែនាំស្តីពីក្រុមការងារបច្ចេកទេសចម្រុះ និងសេចក្តីណែនាំស្តីពីសូចនាករតាមដានរួមគ្នា តាមរយៈការពិគ្រោះយោបល់ប្រកបដោយបរិយាប័ន្ន ដើម្បីឆ្លើយតបទៅនឹងបរិការណ៍នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ដែលមានការវិវត្តឆាប់រហ័ស និងដើម្បីលើកកម្ពស់ភាពជាដៃគូផ្តោតលើលទ្ធផល ដូចមានចែងក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។ គណៈកម្មាធិការនីតិសម្បទា និងអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.អ.ក/គ.ជ.ន)

បានបំពេញតួនាទីដឹកនាំក្នុងការរៀបចំសូចនាករតាមដានរួមគ្នា ដើម្បីតម្រឹម និងគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

កម្ពុជាសម្រេចបានវឌ្ឍនភាព ដើម្បីឈានទៅសម្រេចការប្តេជ្ញាសកលស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ។ ហិរញ្ញប្បទានដែលបានកត់ត្រាក្នុងថវិការដ្ឋ បានកើនពី ៨៣% ក្នុងឆ្នាំ២០១៧ ដល់ ៩២% ក្នុងឆ្នាំ២០១៨ និងឆ្នាំ ២០១៩ ។ សូចនាករស្តីពីភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទាន មានភាពល្អប្រសើរ ក្នុងរង្វង់ ១១៩% ក្នុងឆ្នាំ ២០១៨ និង ១២២% ក្នុងឆ្នាំ២០១៩ ។ ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈបានកើនពី ៧៥% ក្នុងឆ្នាំ ២០១៨ ដល់ ៨១% ក្នុងឆ្នាំ ២០១៩ ។ ទន្ទឹមនឹងវឌ្ឍនភាពទាំងនេះ កម្ពុជាបានជួបប្រទះបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ។ ហិរញ្ញប្បទានដែលបានប្រើប្រាស់ក្របខណ្ឌលទ្ធផលជាតិ មានត្រឹមតែ ៦៣% និងហិរញ្ញប្បទានដែលបានប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ ត្រឹមតែ ៥០% នៃការបើកផ្តល់ហិរញ្ញប្បទានសម្រាប់វិស័យសាធារណៈក្នុងឆ្នាំ២០១៩ ពោលគឺមានវឌ្ឍនភាពបន្តិចបន្តួចប៉ុណ្ណោះ ។ ទោះបីការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិកំពុងមានវឌ្ឍនភាពក៏ដោយ ក៏ប្រព័ន្ធនេះនៅមិនទាន់ត្រូវបានប្រើប្រាស់ឱ្យបានទូលំទូលាយដោយដៃគូអភិវឌ្ឍន៍ឡើយ ។ កិច្ចខិតខំប្រឹងប្រែងបន្ថែមដើម្បីសម្រេចការប្តេជ្ញានានាដែលបានចែងក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ នឹងត្រូវផ្តោតលើការប្រើប្រាស់ក្របខណ្ឌលទ្ធផលជាតិឱ្យបានទូលំទូលាយជាងមុន ពិសេសនៅក្នុងក្រុមការងារបច្ចេកទេសចម្រុះ និងការអនុវត្តប្រកបដោយប្រសិទ្ធភាព នូវសូចនាករតាមដានរួមគ្នា និងការលើកកម្ពស់កិច្ចពិគ្រោះយោបល់ស្តីពីភាពជាដៃគូនៅគ្រប់កម្រិត ។

### *ការវិវត្តនៃហិរញ្ញប្បទានសហប្រតិបត្តិការ*

ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការបានកើនពីប្រមាណ ១.៥០០ លានដុល្លារ ក្នុងឆ្នាំ២០១៨ ដល់ ១.៨៩០ លានដុល្លារ ក្នុងឆ្នាំ២០១៩ ។ ហិរញ្ញប្បទានឥតសំណងមានទំហំថេរ ក្នុងរង្វង់ ៨០០ លានដុល្លារ ក្នុងមួយឆ្នាំ ដោយបានកើនឡើងបន្តិចពី ៨១៣ លានដុល្លារ ក្នុងឆ្នាំ២០១៦ ដល់ ៨៩៣ លានដុល្លារ ក្នុងឆ្នាំ២០១៩ ។ ការប្រែប្រួលទំហំហិរញ្ញប្បទានសហប្រតិបត្តិការប្រចាំឆ្នាំ គឺបណ្តាលមកពីការកើនឡើងឥណទានសម្បទានពី ២៥% នៃហិរញ្ញប្បទានសរុប ក្នុងឆ្នាំ២០១០ ដល់ ៥៣% នៃហិរញ្ញប្បទានសរុប ក្នុងឆ្នាំ២០១៩ ដោយសាធារណរដ្ឋបារាំង, សាធារណរដ្ឋប្រជាមានិតចិន, ជប៉ុន និងធនាគារអភិវឌ្ឍន៍អាស៊ី បានបង្កើនគម្រោង រៀងៗខ្លួន ។

សាធារណរដ្ឋប្រជាមានិតចិននៅតែជាដៃគូដែលបានផ្តល់ហិរញ្ញប្បទានច្រើនជាងគេ ដោយបានផ្តល់ជិត ៥០០ លានដុល្លារ ក្នុងឆ្នាំ២០១៩ ។ ដៃគូអភិវឌ្ឍន៍ពហុភាគី កំពុងបង្កើនការគាំទ្ររបស់ខ្លួន ក្នុងនោះ ការបើកផ្តល់ហិរញ្ញប្បទានរបស់ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី បានកើនឡើងខ្លាំងរៀងៗខ្លួន ពី ១៧ លានដុល្លារ និង ១១៨ លានដុល្លារ ក្នុងឆ្នាំ២០១៦ ដល់ ៧០ លានដុល្លារ និង ២៤៦ លានដុល្លារ ក្នុងឆ្នាំ២០១៩ ។ ការបើកផ្តល់ហិរញ្ញប្បទានរបស់ប្រទេសជាសមាជិកសហភាពអឺរ៉ុបបានធ្លាក់ចុះ លើកលែងគណៈកម្មាធិការអឺរ៉ុប និងសាធារណរដ្ឋបារាំង ដែលបានបង្កើនការបើកផ្តល់ហិរញ្ញប្បទានរៀងៗខ្លួន ចំនួន ៦៥ លានដុល្លារ និង ២០៧ លានដុល្លារ ក្នុងឆ្នាំ ២០១៩ ។ អនុបាតនៃការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូ ៦ (រួមមានសាធារណរដ្ឋប្រជាមានិតចិន, ធនាគារ

អភិវឌ្ឍន៍អាស៊ី, ជប៉ុន, បារាំង, កូរ៉េ និងធនាគារពិភពលោក) បានកើនពី ៤៩%ក្នុងឆ្នាំ២០១៦ ដល់ ៦៨% ក្នុងឆ្នាំ ២០១៩ ។ គួរកត់សម្គាល់ដែរថា សាធារណរដ្ឋប្រជាមានិតចិន និងកូរ៉េ កំពុងបង្កើនការបើកផ្តល់ហិរញ្ញប្បទានឥតសំណង ទន្ទឹមនឹងការបង្កើនការបើកផ្តល់ឥណទានសម្បទាន ។

## ការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ

### និន្នាការនៃការបើកផ្តល់ហិរញ្ញប្បទាន (លានដុល្លារ)




### ការវិភាជតាមវិស័យ ឆ្នាំ២០១៩ (លានដុល្លារ)




### ការបើកផ្តល់របស់ដៃគូអភិវឌ្ឍន៍ (លានដុល្លារ)

| ដៃគូអភិវឌ្ឍន៍ | 2016 | 2017 | 2018 | 2019 ប៉ាន់ស្មាន | 2020 ព្យាករណ៍ |
|---|---|---|---|---|---|
| UN Own Fund | 65.7 | 59.4 | 55.1 | 66.5 | 80.6 |
| Work Bank | 17.6 | 21.1 | 24.8 | 69.7 | 140.8 |
| ADB | 118.2 | 125.7 | 135.9 | 246.0 | 283.1 |
| GAVI Alliance | 16.3 | 10.9 | 7.4 | 8.7 | 5.4 |
| Global Fund | 28.2 | 33.1 | 19.9 | 40.9 | 33.9 |
| EU/EC | 55.7 | 50.8 | 89.7 | 64.6 | 90.3 |
| Czech Republic | 1.5 | 1.3 | 1.1 | 2.0 | 0.7 |
| France | 32.1 | 90.8 | 78.9 | 207.8 | 62.2 |
| Germany | 46.9 | 38.4 | 40.5 | 24.9 | 25.6 |
| Ireland | 0.6 | 0.7 | 0.8 | 0.8 | 0.7 |
| Sweden | 30.1 | 33.5 | 23.8 | 23.8 | 12.4 |
| United Kingdom | 1.6 | 2.3 | 1.2 | 0.9 | 0.1 |
| Australia | 51.9 | 58.3 | 49.2 | 38.8 | 28.4 |
| Canada | 3.2 | 3.4 | 3.1 | 2.0 | 1.0 |
| China | 307.2 | 415.8 | 353.0 | 496.2 | 421.6 |
| Japan | 119.7 | 146.4 | 175.4 | 192.7 | 336.5 |
| New Zealand | 4.0 | 4.9 | 5.0 | 7.2 | 2.5 |
| Republic of Korea | 42.0 | 57.1 | 44.1 | 71.3 | 58.0 |
| Switzerland | 15.8 | 15.5 | 14.0 | 13.4 | 8.3 |
| USA | 77.9 | 93.2 | 94.8 | 59.6 | 43.9 |
| NGO Core Funds | 251.0 | 259.8 | 273.1 | 250.2 | 42.0 |
| Pipeline Projects | - | - | - | - | 219.8 |
| សរុប | 1,287.1 | 1,522.2 | 1,490.6 | 1,887.9 | 1,897.7 |

ចំពោះការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យវិញ វិស័យសង្គមកិច្ចទទួលហិរញ្ញប្បទាន ៥០០ លានដុល្លារជាមធ្យម ក្នុងមួយឆ្នាំ ក្នុងចន្លោះឆ្នាំ២០១១-២០១៩ ប៉ុន្តែបានធ្លាក់ចុះពី ៣៥% នៃការបើកផ្តល់ហិរញ្ញប្បទាន ក្នុងឆ្នាំ ២០១៤ មកត្រឹម ២៨% ក្នុងឆ្នាំ២០១៩ ។ ការបើកផ្តល់ហិរញ្ញប្បទានក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ និងវិស័យសេដ្ឋកិច្ច បានកើនឡើងជិតទ្វេដង ទន្ទឹមនឹងការបើកផ្តល់សម្រាប់អន្តរវិស័យរក្សាទំហំថេរ ក្នុងរយៈពេលដូចគ្នា ។

ក្នុងចន្លោះឆ្នាំ២០១៧-២០១៩ ធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាលមាន ៣៧១ លានដុល្លារជាមធ្យមក្នុងមួយឆ្នាំ ។ ក្នុងឆ្នាំ២០១៨ ធនធាននេះបានកើនឡើងបន្តិច ធៀបនឹងឆ្នាំ២០១៧ ដោយសារកំណើននៃធនធានផ្ទាល់របស់ពួកគេ ។ រីឯធនធានរបស់ដៃគូអភិវឌ្ឍន៍ នៅរក្សាទំហំថេរ ប្រមាណ ១០០ លានដុល្លារ ក្នុងមួយឆ្នាំ សម្រាប់គាំទ្រសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាល ។

### *ស្ថានភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងអន្តរវិស័យ*

ការវិភាគបានផ្តោតលើធនធានគាំទ្រវិស័យសម្គាល់បន្ថែម ៣ គឺ÷ សមភាពយេនឌ័រ, ការអភិវឌ្ឍវិស័យឯកជន និងការប្រែប្រួលអាកាសធាតុ ។

*ហិរញ្ញប្បទានសម្រាប់លើកកម្ពស់សមភាពយេនឌ័រ :* ក្នុងឆ្នាំ២០១៩ ហិរញ្ញប្បទាន ទំហំ ៥,២ លានដុល្លារ (០,២៨% នៃហិរញ្ញប្បទានសរុប) បានគាំទ្រវិស័យគោលយេនឌ័រ ។ ប៉ុន្តែ ហិរញ្ញប្បទានបន្ថែមទំហំ ៨២,៧ លានដុល្លារ បានចូលរួមដោយប្រយោលក្នុងការលើកកម្ពស់សមភាពយេនឌ័រ (កើន ៣២% ធៀបនឹងឆ្នាំ២០១៨) ។ ប្រការនេះបានរំលេចឱ្យឃើញថា ការងារយេនឌ័រត្រូវបានបញ្ជ្រាបទៅក្នុងកម្មវិធីអភិវឌ្ឍន៍របស់ដៃគូអភិវឌ្ឍន៍នីមួយៗ ដែលទាមទារឱ្យកិច្ចសម្របសម្រួលបន្ថែមទៀត ។

*ហិរញ្ញប្បទានសម្រាប់គាំទ្រការអភិវឌ្ឍវិស័យឯកជន :* ក្នុងឆ្នាំ២០១៩ គម្រោងដែលមានធនធាន ២០៩ លានដុល្លារ បានចូលរួមដោយប្រយោលក្នុងការអភិវឌ្ឍវិស័យឯកជន(កើន ៤៨% ធៀបនឹងឆ្នាំ២០១៨) ។វិស័យថាមពល និងវិស័យដឹកជញ្ជូន គឺជាវិស័យដែលបានបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជនច្រើនជាងគេ ។

*ហិរញ្ញប្បទានសម្រាប់គាំទ្រការប្រែប្រួលអាកាសធាតុ :* ធនធាន ១១,៦ លានដុល្លារ ក្នុងឆ្នាំ២០១៨ និង ១៣,៣ លានដុល្លារ ក្នុងឆ្នាំ២០១៩ បានគាំទ្រវិស័យគោលការប្រែប្រួលអាកាសធាតុ ។ រីឯហិរញ្ញប្បទានសរុបសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ មានទំហំ ៧៩ លានដុល្លារ ក្នុងឆ្នាំ២០១៩ ពោលគឺកើន៣៩% ធៀបនឹងឆ្នាំ២០១៨ ។ វិស័យនគរូបនីយកម្ម ទទួលបានធនធានសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុច្រើនជាងគេ ពោលគឺ ១៥% នៃការបើកផ្តល់ហិរញ្ញប្បទានសរុបសម្រាប់វិស័យនេះ ក្នុងឆ្នាំ២០១៩ ។ បន្ទាប់មកគឺ វិស័យបរិស្ថាន និងចីរភាព ១៣%, វិស័យកសិកម្ម ១២%, ការអភិវឌ្ឍជនបទ ៨% និងវិស័យទឹកស្អាត និងអនាម័យ ៣% ។

### *ហិរញ្ញប្បទានសហប្រតិបត្តិការគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា*

ក្រោមភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា សម្រេចបានវឌ្ឍនភាពសំខាន់ៗជាច្រើន ។ យោងតាមរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា សម្រាប់ឆ្នាំ២០១៧-២០១៨, អនុបាតវិស័យឧស្សាហកម្មធៀបនឹងផលិតផលក្នុងស្រុកសរុប បានកើនពី ២៧,៧% ក្នុងឆ្នាំ២០១៥ ដល់ ៣២,៦% ក្នុងឆ្នាំ២០១៨ ពោលគឺបានសម្រេចលើសគោលដៅឆ្នាំ២០២៥ ដែលកំណត់ត្រឹមតែ ៣០% ។

ក្នុងឆ្នាំ២០១៨ ហិរញ្ញប្បទានប្រមាណ ១៥៧ លានដុល្លារ ស្មើនឹង ១៣% នៃហិរញ្ញប្បទានសរុប ត្រូវបានបើកផ្តល់ សម្រាប់គាំទ្រវិធានការគន្លឹះបួនជាក់ស្តែង និងវិធានការគោលនយោបាយ និងផែនការសកម្មភាពនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ហើយអាចកើនដល់ ២៦៥,៧ លានដុល្លារ ក្នុងឆ្នាំ២០១៨ ។ វិស័យដឹកជញ្ជូន, វិស័យថាមពលអគ្គិសនី និងវិស័យកសិកម្ម ទទួលបានហិរញ្ញប្បទានច្រើនជាងគេ សម្រាប់បញ្ជ្រាបគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ។

*វឌ្ឍនភាពរបស់កម្ពុជាក្នុងការឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច*

កំណើនសេដ្ឋកិច្ចដ៏រឹងមាំ និងវឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រីក្រ បានធ្វើឱ្យកម្ពុជាសម្រេចបានខ្ពស់ជាងលក្ខខណ្ឌវិនិច្ឆ័យស្តីពីការអភិវឌ្ឍធនធានមនុស្ស សម្រាប់ឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច និងកំពុងឈានទៅសម្រេចលក្ខខណ្ឌស្តីពីភាពងាយរងគ្រោះខាងសេដ្ឋកិច្ច ។ ចំណូលជាតិសម្រាប់ប្រជាជនម្នាក់អាចកើនខ្ពស់ជាងលក្ខខណ្ឌវិនិច្ឆ័យ ។ ផ្អែកលើសេណារីយ៉ូនេះ កម្ពុជាសង្ឃឹមថា នឹងត្រូវបានដាក់បញ្ចូលទៅក្នុងបញ្ជីប្រទេសសម្រាប់ឆ្លងផុតពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច នៅក្នុងកិច្ចប្រជុំត្រួតពិនិត្យលើកក្រោយរបស់គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ នាឆ្នាំ២០២១ ។

ការចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច អាចប្រឈមនឹងការបាត់បង់អត្ថប្រយោជន៍ និងសម្បទានមួយចំនួន ពិសេសក្នុងវិស័យពាណិជ្ជកម្ម, ហិរញ្ញប្បទានសហប្រតិបត្តិការ និងការគាំទ្របច្ចេកទេសដទៃទៀត ។ ប៉ុន្តែ រាជរដ្ឋាភិបាលបានពិនិត្យយ៉ាងម៉ត់ចត់ អំពីតម្រូវការនៃការចាកចេញ និងផលប៉ះពាល់ដែលជាបច្ច័យនៃការចាកចេញនេះ ។ វិធានការគោលនយោបាយនឹងផ្តោតការយកចិត្តទុកដាក់លើការងារសំខាន់ៗ រួមមាន÷

-*ការកាត់បន្ថយភាពងាយរងគ្រោះខាងសេដ្ឋកិច្ច :* ការបន្តអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា និងគោលនយោបាយដទៃទៀត ពិសេសពាក់ព័ន្ធនឹងការពង្រីកវិស័យកម្មន្តសាល, សហគ្រាសតូច និងមធ្យម និងសេវាកម្ម, ការលើកកម្ពស់ឧស្សាហូបនីយកម្ម, ការធ្វើពិពិធកម្មការនាំចេញ, ការធ្វើទំនើបកម្មកសិកម្ម និងការត្រៀមបង្ការគ្រោះមហន្តរាយ គឺជាកត្តាគន្លឹះសម្រាប់ពន្លឿនការកាត់បន្ថយភាពងាយរងគ្រោះខាងសេដ្ឋកិច្ច ។

-*កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ :* ការថយចុះហិរញ្ញប្បទានឥតសំណង និងការជំនួសដោយឥណទានសម្បទាន នឹងត្រូវបំពេញដោយការបន្តកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការកៀរគរធនធានក្នុងស្រុក ។ ក្នុងន័យនេះ ការបន្តអនុវត្តប្រកបដោយប្រសិទ្ធភាពនូវយុទ្ធសាស្ត្រស្តីពីការកៀរគរចំណូល ឆ្នាំ២០១៩-២០២៣ និងយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ឆ្នាំ២០១៩-២០២៣ គឺជាកិច្ចការសំខាន់របស់រាជរដ្ឋាភិបាល ។

-*ពាណិជ្ជកម្ម :* ការបន្តទំនាក់ទំនងល្អជាមួយដៃគូពាណិជ្ជកម្ម ដើម្បីរក្សាបានភាពអនុគ្រោះ និងការធានាភាពអំណោយផលក្នុងដំណាក់កាលអន្តរកាល ក៏កិច្ចការសំខាន់របស់រាជរដ្ឋាភិបាលផងដែរ ។

- *ហេដ្ឋារចនាសម្ព័ន្ធ, ឡូជីស្ទីក និងគោលនយោបាយវិនិយោគ :* គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ គឺជាឧបករណ៍គន្លឹះ ដើម្បីប្រែក្លាយរចនាសម្ព័ន្ធឧស្សាហកម្ម ពីឧស្សាហកម្មអតិពលកម្មឱ្យទៅជាឧស្សាហកម្មផ្អែកលើជំនាញ ។ ក្នុងន័យនេះ ការយកចិត្តទុកដាក់ត្រូវផ្តោតទៅលើការបន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធ, ឡូជីស្ទីក និងគោលនយោបាយវិនិយោគ ដើម្បីទាក់ទាញការវិនិយោគកាន់តែច្រើនក្នុងវិស័យឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់,មានបច្ចេកវិទ្យា និងប្រើប្រាស់ទុនវិនិយោគច្រើន ។

*ការគ្រប់គ្រងដោយផ្តោតលើលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព*

ដោយផ្អែកលើសក្ខីកម្ម និងគោលការណ៍ស្តីពីស័ក្តិសិទ្ធិភាពនៃកិច្ចអភិវឌ្ឍន៍ និងចីរភាព, អភិក្រមស្តីពីការផ្តោតលើលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ បានក្លាយជាត្រីវិស័យសម្រាប់ណែនាំកិច្ចសហប្រតិបត្តិការរវាងកម្ពុជា និងដៃគូ

អភិវឌ្ឍន៍ តាមរយៈការបង្កើត និងអនុវត្តប្រព័ន្ធតាមដាន, វាយតម្លៃ និងរាយការណ៍ ដែលអាចលើកកម្ពស់កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ដោយផ្តោតលើលទ្ធផល ។

ក្នុងបរិការណ៍កម្ពុជា កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ត្រូវបានអនុវត្តស្របតាមអភិក្រមដោយផ្តោតលើលទ្ធផល ។ ក្នុងន័យនេះ យុទ្ធសាស្ត្រចតុកោណបានក្លាយជាក្របខណ្ឌអភិវឌ្ឍន៍ជាតិគ្រប់ជ្រុងជ្រោយ ដើម្បីសម្រេចលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ ។ ក្របខណ្ឌលទ្ធផលនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ត្រូវបានដាក់បញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ រីឯផែនការយុទ្ធសាស្ត្រថវិកាបានក្លាយទៅជាឧបករណ៍សម្រាប់ផ្សារភ្ជាប់ធនធានទៅនឹងលទ្ធផល ទន្ទឹមនឹងពេលដែលហិរញ្ញប្បទានសហប្រតិបត្តិការត្រូវបញ្ចូលជាបណ្តើរៗទៅក្នុងច្បាប់ថវិកាជាតិ ដែលជាផ្នែកមួយនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។

### *ការសន្និដ្ឋាន*

រាជរដ្ឋាភិបាលនឹងបន្តអនុវត្តគោលនយោបាយគន្លឹះៗ ដែលជំរុញការធ្វើទំនើបកម្មសេដ្ឋកិច្ច ។ ការចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច គឺជាគោលដៅបន្ថែមមួយទៀត សម្រាប់ឈានឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជា ឆ្នាំ២០៣០ និងឆ្នាំ២០៥០ ។ ដោយសារមានកំណើនចំណូលថវិកាជាតិ ធនធានក្រៅប្រទេសនឹងបំពេញបន្ថែមឱ្យធនធានក្នុងស្រុក និងហិរញ្ញប្បទានអភិវឌ្ឍន៍ដទៃទៀត រួមទាំងធនធានពីវិស័យឯកជន ដើម្បីបន្តជំរុញកំណើនប្រកបដោយបរិយាប័ន្ន និងកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា ។ ក្នុងន័យនេះ ទំហំសរុបនៃហិរញ្ញប្បទានសហប្រតិបត្តិការដែលកៀរគរបានកន្លងមក បានឆ្លុះបញ្ចាំងពីការបន្តធ្វើការងាររបស់រាជរដ្ឋាភិបាល ជាមួយបណ្តាដៃគូ និងតម្រឹមធនធានទាំងនេះជាមួយនឹងអាទិភាពជាតិ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងបន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្ន ជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ក្នុងគោលដៅកៀរគរធនធានដើម្បីរួមចំណែកដល់ការសម្រេចបានលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព ។

# ជំពូកទី ១

# សេចក្តីផ្តើម - បរិការណ៍នៃភាពជាដៃគូ

ក្នុងជាងពីរទសវត្សរ៍កន្លងមកនេះ រាជរដ្ឋាភិបាលសម្រេចសមិទ្ធផលសំខាន់ៗជាច្រើនក្នុងកិច្ចអភិវឌ្ឍន៍ជាតិ ។ អាទិភាពខ្ពស់បំផុតក្នុងរបៀបវារៈនៃកិច្ចអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល គឺការធានាសន្តិភាព និងសន្តិសុខ, ស្ថិរភាពនយោបាយ, ការលើកកកម្ពស់កំណើនប្រកបដោយចីរភាព និងធន់នឹងវិបត្តិ, ការកាត់បន្ថយភាពក្រីក្រ និងការបង្កើតការងារជូនប្រជាជន ព្រមទាំងការពង្រឹងសមត្ថភាពស្ថាប័នសាធារណៈ ។

ទន្ទឹមនឹងការប្រែប្រួលយ៉ាងឆាប់រហ័សនៃបរិការណ៍អភិវឌ្ឍន៍សកល កម្ពុជាសម្រេចបានវឌ្ឍនភាពជាទីមោទនៈក្នុងការអនុវត្តរបៀបវារៈអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ។ ជាក់ស្តែង ក្នុងឆ្នាំ២០១៨ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ច ៧,៥% ដែលជាកំណើនខ្ពស់បំផុតក្នុងរយៈពេល១០ឆ្នាំចុងក្រោយនេះ ដោយសារសន្ទុះនៃការអភិវឌ្ឍវិស័យឯកជន និងការបន្តកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការកែលម្អបរិយាកាសធុរកិច្ច ។ ចំណូលរបស់ប្រជាជនម្នាក់បានកើនដល់ ១.៥៤៨ ដុល្លារ ក្នុងឆ្នាំ២០១៨ និងប្រមាណ ១.៦៧៩ ដុល្លារ ក្នុងឆ្នាំ២០១៩ ហើយអាចបន្តកើនដល់ ១.៨០៧ ដុល្លារ ក្នុងឆ្នាំ២០២០ ។ រីឯភាពក្រីក្រត្រូវបានកាត់បន្ថយមកនៅត្រឹមក្រោម ១០% ។ សមិទ្ធផលទាំងនេះបានឆ្លុះបញ្ចាំងអំពីភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល ក្នុងដំណើរការនៃការអភិវឌ្ឍប្រកបដោយសមធម៌, ចីរភាព និងបរិយាប័ន្ន ។

ក្នុងឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប ទន្ទឹមនឹងការត្រៀមចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួចនាឆ្នាំខាងមុខ កម្ពុជានៅបន្តប្រឈមនឹងបញ្ហាថ្មីៗបន្ថែមទៀត ។ ក្នុងន័យនេះ កម្ពុជានឹងបន្តរក្សា និងពង្រឹងវឌ្ឍនភាពក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដោយការយកចិត្តទុកដាក់ដល់ការពង្រឹងប្រព័ន្ធ និងសមត្ថភាពនៃស្ថាប័នសាធារណៈ ដែលរួមចំណែកដល់ការលើកកម្ពស់កំណើនសេដ្ឋកិច្ចរយៈពេលវែង និងជំរុញភាពប្រកួតប្រជែង ។ ដើម្បីសម្រេចគោលដៅប្រកបដោយមហិច្ឆតាក្នុងការប្រែក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់ នាឆ្នាំ២០៥០ ព្រមទាំងរបៀបវារៈស្តីពីកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០៣០ រាជរដ្ឋាភិបាលនឹងរៀបចំក្របខណ្ឌគោលនយោបាយប្រកបដោយសង្គតិភាព, ការគាំទ្រហិរញ្ញប្បទាន និងភាពជាដៃគូ ដើម្បីជំរុញភាពប្រកួតប្រជែងសេដ្ឋកិច្ច, ពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការ ។

ក្នុងការដឹកនាំកិច្ចអភិវឌ្ឍន៍ជាតិ រាជរដ្ឋាភិបាលបានយល់ច្បាស់អំពីការវិវត្តឆាប់រហ័សនៃបរិការណ៍សកល ដែលបានជះឥទ្ធិពលដល់ការផ្លាស់ប្តូរជាវភាពនៃការអភិវឌ្ឍ និងភាពជាដៃគូនៅកម្ពុជា ។ លើមូលដ្ឋាននេះ របៀបវារៈស្តីពីកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០៣០ គឺជាក្របខណ្ឌរួមសម្រាប់កិច្ចសហប្រតិបត្តិការ, ប៉ុន្តែ ក៏នៅមានបញ្ហាប្រឈមសកលជាច្រើនទៀតដែលទាមទារដំណោះស្រាយ ដូចជាភាពមិនច្បាស់លាស់នៃពាណិជ្ជកម្មអន្តរជាតិ, ការប្រែប្រួលអាកាសធាតុ និងបញ្ហាសន្តិសុខជាដើម ។

រាជរដ្ឋាភិបាលបានត្រៀមជាស្រេច ដើម្បីក្ដាប់យកកាលានុវត្តភាពថ្មីៗ និងដោះស្រាយបញ្ហាប្រឈមទាំងនេះ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ដែលជារបៀបវារៈអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី ៦ នៃរដ្ឋសភា ដោយផ្អែកលើវឌ្ឍនភាព និងបទពិសោធន៍កន្លងមក ។

យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ បានបន្តផ្ដោតអាទិភាពលើ÷ ១) ការអភិវឌ្ឍធនធានមនុស្ស, ២) ការធ្វើពិពិធកម្មសេដ្ឋកិច្ច, ៣) ការអភិវឌ្ឍវិស័យឯកជន និង ៤) ការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ ដែលបានបញ្ចូលគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា គឺជាឧបករណ៍សម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ ដោយបានកំណត់សកម្មភាពជាក់លាក់ និងសូចនាករដែលអាចវាស់វែងបាន ដែលជាផ្នែកមួយនៃរបៀបវារៈប្រកបដោយមហិច្ឆតាសម្រាប់ការកែទម្រង់ និងការធ្វើទំនើបកម្ម ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបានរៀបចំសូចនាករសមិទ្ធកម្មគន្លឹះ ដែលជាក្របខណ្ឌសម្រាប់តាមដាន និងវាយតម្លៃដោយផ្អែកលើលទ្ធផល អំពីវឌ្ឍនភាពក្នុងការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ ។

ការបន្តកិច្ចប្រឹងប្រែងក្នុងការកែទម្រង់អភិបាលកិច្ច ដូចជាការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ការកែទម្រង់រដ្ឋបាលសាធារណៈ និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងការអនុវត្តគោលនយោបាយគន្លឹះៗ ដូចជាយុទ្ធសាស្ត្រស្ដីពីការកៀរគរចំណូល ឆ្នាំ២០១៩-២០២៣, យុទ្ធសាស្ត្រស្ដីពីការគ្រប់គ្រងបំណុលសាធារណៈ ឆ្នាំ២០១៩-២០២៣ និងយុទ្ធសាស្ត្រស្ដីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈ ឆ្នាំ២០១៩-២០២៣ បានបង្កើនសមត្ថភាពដឹកនាំរបស់រាជរដ្ឋាភិបាល ក្នុងការកៀរគរ និងគ្រប់គ្រងចំណូលជាតិ សម្រាប់អនុវត្តយុទ្ធសាស្ត្រចតុកោណ- ដំណាក់កាលទី ៤ និងរបៀបវារៈនៃកិច្ចអភិវឌ្ឍន៍ជាតិ ។

ក្នុងការអនុវត្តគោលនយោបាយស្ដីពីការបែងចែកឡើងវិញនូវផ្លែផ្កានៃកិច្ចអភិវឌ្ឍន៍ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវក្របខណ្ឌគោលនយោបាយជាតិគាំពារសង្គម ឆ្នាំ២០១៦-២០២៥ ដើម្បីធានាសន្តិសុខប្រាក់ចំណូលរបស់ប្រជាជន, លើកកម្ពស់សុខុមាលភាព, ពង្រឹងសាមគ្គីភាពសង្គម, កាត់បន្ថយភាពក្រីក្រ, ភាពងាយរងគ្រោះ និងវិសមភាព ។

ដើម្បីជំរុញការផ្លាស់ប្ដូររចនាសម្ព័ន្ធសង្គម-សេដ្ឋកិច្ច រាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ក្នុងគោលដៅធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា ពីឧស្សាហកម្មអតិពលកម្មទៅជាឧស្សាហកម្មផ្អែកលើជំនាញ ដែលរួមចំណែកដល់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន, ក៏ដូចជាពន្លឿនការធ្វើពិពិធកម្មសេដ្ឋកិច្ច, ពង្រឹងភាពប្រកួតប្រជែង និងលើកកម្ពស់ផលិតភាព ។

ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ទន្ទឹមនឹងការត្រៀមចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច រាជរដ្ឋាភិបាលត្រូវការធនធានយ៉ាងគំហុក ទន្ទឹមនឹងការយកចិត្តទុកដាក់ដល់បញ្ហាស្មុគស្មាញនានាដែលពាក់ព័ន្ធនឹងទំនាក់ទំនងអន្តរជាតិ, រចនាសម្ព័ន្ធនៃហិរញ្ញប្បទាន និងការ

ផ្លាស់ប្តូរទម្រង់ផ្តល់ធនធានទាំងនេះ ។ រាជរដ្ឋាភិបាលទទួលស្គាល់តួនាទីកាតាលីករនៃហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់កៀរគរធនធានអភិវឌ្ឍន៍ដទៃ ទាំងវិស័យសាធារណៈ និងឯកជន ។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ ដើម្បីបន្តអនុវត្តការប្តេជ្ញាសកលស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ និងភាពជាដៃគូ ។

ផ្អែកលើសមិទ្ធផលដែលសម្រេចបានកន្លងមក, យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនេះ នឹងបន្តលើកកម្ពស់ការសម្របសម្រួលយន្តការភាពជាដៃគូ, កៀរគរធនធាន និងពង្រឹងភាពជាដៃគូជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ ។ យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនេះ ក៏បានរៀបចំសេចក្តីណែនាំសម្រាប់អនុវត្តយន្តការ និងឧបករណ៍សំខាន់ៗ ដើម្បីលើកកម្ពស់ភាពជាដៃគូប្រកបដោយបរិយាប័ន្ន និងស័ក្តិសិទ្ធិភាពនៅគ្រប់កម្រិតនៃកិច្ចអភិវឌ្ឍន៍ ។

របាយការណ៍ស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ និងភាពជាដៃគូ ឆ្នាំ២០១៨-២០១៩ បានពិនិត្យអំពីការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ និងការរួមចំណែកដល់ការអនុវត្តបណ្តាអាទិភាពនៃកិច្ចអភិវឌ្ឍន៍ជាតិ ។ របាយការណ៍នេះបានប្រើប្រាស់ទិន្នន័យដែលដៃគូអភិវឌ្ឍន៍បានកត់ត្រាក្នុងប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ សម្រាប់វិភាគនិន្នាការនៃហិរញ្ញប្បទានសហប្រតិបត្តិការ ក៏ដូចជារំលេចអំពីវឌ្ឍនភាពនៃការអនុវត្តការប្តេជ្ញាស្តីពីភាពជាដៃគូ ក្នុងបរិការណ៍កម្ពុជាបច្ចុប្បន្ន ។

របាយការណ៍នេះនឹងផ្តល់ជូនអ្នករៀបចំគោលនយោបាយនូវព័ត៌មានសំខាន់ៗ ដែលពាក់ព័ន្ធនឹងលំហូរហិរញ្ញប្បទានសហប្រតិបត្តិការ និងការតម្រឹមធនធានទាំងនេះ ជាមួយនឹងរបៀបវារៈក្នុងកិច្ចអភិវឌ្ឍន៍ជាតិ ។ លទ្ធផលនៃការវិភាគនេះនឹងត្រូវប្រើប្រាស់ សម្រាប់រួមចំណែកកែលម្អគោលនយោបាយស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ក៏ដូចជាធាតុចូលសម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃភាពជាដៃគូ រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងអស់ ទន្ទឹមនឹងការប្តេជ្ញារបស់រាជរដ្ឋាភិបាលក្នុងការធានាគណនេយ្យភាពទ្វេទិស និងតម្លាភាពក្នុងការប្រើប្រាស់ធនធានដែលរួមចំណែកដល់ការលើកកម្ពស់លទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ។

# ជំពូកទី ២
# ភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍

### *វឌ្ឍនភាពស្ដីពីភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍*

រាជរដ្ឋាភិបាលប្ដេជ្ញាអនុវត្តឱ្យសម្រេចបានការប្ដេជ្ញាស្ដីពីភាពជាដៃគូសកល ។ កិច្ចប្រឹងប្រែងនេះត្រូវបានឆ្លុះបញ្ចាំង តាមរយៈលទ្ធផលនៃការធ្វើអង្កេតទីក្រុងប៊ូសាន ឆ្នាំ២០១៨ និងការបញ្ចូលសូចនាករសមស្របមួយចំនួនទៅក្នុងក្របខណ្ឌលទ្ធផលនៃយុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។ សូចនាករជាច្រើនក៏ត្រូវបានបញ្ចូលក្នុងក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ដែលនឹងត្រូវបានអនុវត្តតាមរយៈផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ ។ សូចនាករទាំងនេះក៏ត្រូវបានរំលេចក្នុងក្របខណ្ឌតាមដានសូចនាករសមិទ្ធកម្មគន្លឹះផ្ដោតលើលទ្ធផលនៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ ។ ក្នុងន័យនេះ ជំពូកនេះមិនត្រឹមតែជាមូលដ្ឋានបង្អែកសម្រាប់កិច្ចការពាក់ព័ន្ធនឹងភាពជាដៃគូ ប៉ុន្តែក៏បានវាយតម្លៃវឌ្ឍនភាពនៃភាពជាដៃគូ ធៀបនឹងគោលដៅដែលបានកំណត់ក្នុងក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា, យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។

រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ក្នុងការអនុវត្តការប្ដេជ្ញាស្ដីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ និងភាពជាដៃគូសកល ដែលបានឯកភាពនៅទីក្រុងប៊ូសាន នាឆ្នាំ២០១១ ។ ដើម្បីសម្រេចបានការប្ដេជ្ញាក្នុងការអនុវត្តយុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ និងលើកកម្ពស់ភាពជាដៃគូដោយផ្ដោតលើលទ្ធផល រាជរដ្ឋាភិបាលបានពង្រឹងយន្តការក្រុមការងារបច្ចេកទេសចម្រុះ និងជំរុញប្រសិទ្ធភាពនៃការប្រើប្រាស់សូចនាករតាមដានរួមគ្នា ។ ដើម្បីធានាសមិទ្ធកម្មប្រកបដោយប្រសិទ្ធភាពនៃយន្តការក្រុមការងារបច្ចេកទេសចម្រុះ និងសូចនាករតាមដានរួមគ្នា, ការអនុវត្តដោយភាពទន់ភ្លន់នូវសេចក្ដីណែនាំដែលពាក់ព័ន្ធ គឺជាកិច្ចការសំខាន់ ។ សេចក្ដីណែនាំដែលពាក់ព័ន្ធទាំងនេះត្រូវបានកែសម្រួលក្នុងឆ្នាំ២០១៩ តាមរយៈការពិគ្រោះយោបល់ប្រកបដោយបរិយាប័ន្ន ។

ផ្អែកលើសេចក្ដីណែនាំដែលបានកែសម្រួលនេះ ក.អ.ក/គ.ជ.ទា បានដឹកនាំការរៀបចំ និងការត្រួតពិនិត្យការអនុវត្តសូចនាករតាមដានរួមគ្នាថ្មីនេះ ។ ស្របជាមួយនឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានវឌ្ឍនភាពល្អប្រសើរ ហើយការអនុវត្តថវិកាកម្មវិធីកាន់តែផ្ដោតលើលទ្ធផល, សូចនាករតាមដានរួមគ្នាថ្មីដែលបានតម្រឹមជាមួយយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រតាមវិស័យ ត្រូវបានពិភាក្សាក្នុងកិច្ចប្រជុំក្រុមការងារបច្ចេកទេសចម្រុះ ហើយបានផ្សារភ្ជាប់សូចនាករទាំងនេះទៅនឹងកម្មវិធីនីយកម្ម និងថវិកានីយកម្ម ។ សូចនាករតាមដានរួមគ្នាថ្មីត្រូវបានរៀបចំឡើង ដោយផ្អែកលើយុទ្ធសាស្ត្រ និងផែនការតាមវិស័យ និងការកែទម្រង់ដែលមានស្រាប់ ហើយបានដាក់បញ្ចូលក្នុងផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង និងស្ថាប័ន ។ សូចនាករតាមដានរួមគ្នា ឆ្នាំ២០១៩-២០២៣ ត្រូវបានទទួលការអនុម័តដ៏ខ្ពង់ខ្ពស់ពី **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាខែកញ្ញា ឆ្នាំ២០១៩ ។

ទន្ទឹមនឹងសមិទ្ធផលគួរឱ្យកត់សម្គាល់ទាំងនេះ ក៏នៅមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ។ កិច្ចការសំខាន់គឺការជំរុញឱ្យដៃគូអភិវឌ្ឍន៍បង្កើនការប្រើប្រាស់ក្របខណ្ឌលទ្ធផល និងប្រព័ន្ធជាតិ ពិសេសប្រព័ន្ធលទ្ធកម្មជាតិ ដោយសារសូចនាករនៅមានវឌ្ឍនភាពតិចតួចប៉ុណ្ណោះ ។ ចំពោះការប្រើប្រាស់ប្រព័ន្ធជាតិ ក្នុងឆ្នាំ២០១៨ ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការដែលបានគាំទ្រដល់វិស័យសាធារណៈ ចំនួន ៧៥% បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហើយអាចកើនដល់ ៨១% ក្នុងឆ្នាំ២០១៩ ។ ទោះបីទំហំឥណទានសម្បទានបានកើនឡើងជាបន្តបន្ទាប់ ទន្ទឹមនឹងការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានវឌ្ឍនភាពក៏ដោយ ក៏ដៃគូពហុភាគីមួយចំនួននៅបន្តប្រើប្រាស់ប្រព័ន្ធថវិការបស់ខ្លួន ពិសេសប្រព័ន្ធរបាយការណ៍ហិរញ្ញវត្ថុ និងប្រព័ន្ធសវនកម្ម ។

| **គំនូរទី២.១: ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៨** | **គំនូរទី ២.២: ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១៩** |
| --- | --- |
|  |  |





*%នៃហិរញ្ញប្បទានដែលបានគាំទ្រវិស័យសាធារណៈ

កិច្ចប្រឹងប្រែងបន្ថែមទៀត ទាំងខាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ នឹងផ្តោតលើការបង្កើនការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីឈានទៅសម្រេចគោលដៅដែលបានកំណត់ក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ (៨៥% ត្រឹមឆ្នាំ២០២៣) ។ ក្នុងឆ្នាំ២០១៨ ដៃគូពហុភាគី ដូចជា GAVI, មូលនិធិអន្តរជាតិអភិវឌ្ឍន៍កសិកម្ម, អង្គការយូនីសេហ្វ, ធនាគារអភិវឌ្ឍន៍អាស៊ី និងសហគមន៍អឺរ៉ុប បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លើសពី ៧៥% នៃធនធានរៀងៗខ្លួន ។ រីឯសាធារណរដ្ឋប្រជាមានិតចិន, បារាំង និងស្វីស បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៩០% នៃការបើកផ្តល់ធនធានរបស់ខ្លួន ។ ដោយសន្មតថាឥណទានសម្បទានបានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងឆ្នាំ២០១៩, ដៃគូទ្វេភាគី ដូចជាសាធារណរដ្ឋប្រជាមានិតចិន និងបារាំង ព្រមទាំងដៃគូពហុភាគី រួមមានធនាគារអភិវឌ្ឍន៍អាស៊ី, មូលនិធិអន្តរជាតិអភិវឌ្ឍន៍កសិកម្ម, GAVI និងអង្គការយូនីសេហ្វ បានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈស្ទើរតែ ១០០%នៃការបើកផ្តល់ធនធានរបស់ខ្លួន ។

ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ គឺជាបញ្ហាប្រឈមចម្បង ។ ក្នុងឆ្នាំ២០១៨, ៤៧% នៃហិរញ្ញប្បទានសហប្រតិបត្តិការដែលបានបើកផ្តល់ដល់វិស័យសាធារណៈ បានប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ ហើយអាចកើន

ដល់ ៥០% នៅឆ្នាំ២០១៩ ។ ទោះបីជាដៃគូអភិវឌ្ឍន៍បានបង្កើនការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក៏ដោយ ក៏ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិនៅមានកម្រិតនៅឡើយ និងត្រូវយកចិត្តទុកដាក់បន្ថែមទៀត ។ ដៃគូអភិវឌ្ឍន៍ដែលផ្តល់ឥណទានសម្បទានគប្បីពិនិត្យលទ្ធភាពបង្កើនការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ ដើម្បីឈានទៅសម្រេចគោលដៅ ៦០% នៅត្រឹមឆ្នាំ២០២៣ ។

**គំនូរទី២.៣: ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ ឆ្នាំ២០១៨**




**គំនូរទី២.៤ ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ ឆ្នាំ២០១៩**




*%នៃហិរញ្ញប្បទានដែលបានគាំទ្រវិស័យសាធារណៈ

ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ បានកើនឡើងពី ៨៣% ក្នុងឆ្នាំ២០១៧ ដល់ ៩២% ក្នុងឆ្នាំ២០១៨ និង ២០១៩ ដោយសារការកើនឡើងនៃឥណទានសម្បទាន ដែលជាទូទៅត្រូវបានកត់ត្រាក្នុងថវិការដ្ឋ ។ ការបន្តរក្សាវឌ្ឍនភាពបែបនេះ គឺជាកត្តាចាំបាច់ ដើម្បីអាចឈានទៅសម្រេចគោលដៅ ៩៥% ត្រឹមឆ្នាំ២០២៣ ។ លើសពីនេះ ហិរញ្ញប្បទានឥតសំណងដែលបានបើកផ្តល់សម្រាប់គាំទ្រថវិកា និងគម្រោង/កម្មវិធីវិនិយោគត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធថវិកា និងបានកត់ត្រាក្នុងថវិការដ្ឋ ។

**គំនូរទី២.៥: ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ ឆ្នាំ២០១៨**




**គំនូរទី២.៦: ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ ឆ្នាំ២០១៩**




*%នៃហិរញ្ញប្បទានដែលបានគាំទ្រវិស័យសាធារណៈ

ទិន្នន័យបានបង្ហាញថា រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពលើសូចនាករស្តីពីភាពអាចទស្សន៍ទាយបាន ។ ការបើកផ្តល់ហិរញ្ញប្បទានសម្រេចបាន ១១៥% ធៀបនឹងការព្យាករណ៍ ក្នុងឆ្នាំ២០១៨ និង ១២២% ក្នុងឆ្នាំ២០១៩ ។ ក្នុងឆ្នាំ២០១៨ ដៃគូអភិវឌ្ឍន៍ ដូចជាមូលនិធិអន្តរជាតិអភិវឌ្ឍន៍កសិកម្ម, សាធារណរដ្ឋកូរ៉េ, កម្មវិធីអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ និងអូស្ត្រាលី បានបើកផ្តល់ហិរញ្ញប្បទានជិត ១០០% ធៀបនឹងហិរញ្ញប្បទានដែលគ្រោងផ្តល់ ។ រីឯ

សហគមន៍អឺរ៉ុប, សហរដ្ឋអាមេរិក, ចិន, អាល្លឺម៉ង់ និង GAVI បានបើកផ្តល់ហិរញ្ញប្បទានលើសពីការគ្រោងផ្តល់ ។ ការព្យាករណ៍ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការរបស់អង្គការសុខភាពពិភពលោក, ធនាគារអភិវឌ្ឍន៍អាស៊ី, អាល្លឺម៉ង់ និងបារាំង មានភាពប្រសើរឡើង នៅឆ្នាំ២០១៩ ។ ដោយសារថវិការដ្ឋគឺជាឧបករណ៍ សម្រាប់អនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល សំដៅឈានទៅសម្រេចគោលដៅនៃយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា, ភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទានសហប្រតិបត្តិការ គឺជាកត្តាសំខាន់ក្នុងការរៀបចំផែនការថវិកា ។

ការខ្វះចន្លោះរបស់ដៃគូអភិវឌ្ឍន៍ក្នុងការទស្សន៍ទាយហិរញ្ញប្បទានរបស់ខ្លួន អាចបណ្តាលមកពីបញ្ហាមួយក្នុងចំណោមបញ្ហាសំខាន់ៗ ៣ គឺ÷ ក) ខ្វះការយកចិត្តទុកដាក់ក្នុងការប៉ាន់ស្មានហិរញ្ញប្បទាន ពិសេសក្នុងដំណាក់កាលរៀបចំផែនការ, ខ) ការអនុវត្តមានគម្លាតខុសឆ្ងាយពីផែនការ ឬ គ) ទិន្នន័យមិនបានកត់ត្រាត្រឹមត្រូវក្នុងដំណាក់កាលរៀបចំផែនការ ឬក្នុងដំណាក់កាលរៀបចំរបាយការណ៍ ។ ការរៀបចំកម្មវិធីឱ្យបានពិស្តា, ការកត់ត្រាទិន្នន័យ និងរបាយការណ៍ស្តីពីការបើកផ្តល់ហិរញ្ញប្បទាន គឺជាកិច្ចការសំខាន់សម្រាប់ធានាភាពប្រាកដប្រជាក្នុងការទស្សន៍ទាយទំហំហិរញ្ញប្បទាន ។

**គំនូរទី២.៧: ភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទាន ឆ្នាំ២០១៨**




**គំនូរទី ២.៨: ភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទាន ឆ្នាំ២០១៩**




*%នៃហិរញ្ញប្បទានដែលបានគាំទ្រវិស័យសាធារណៈ

ដៃគូអភិវឌ្ឍន៍គប្បីយកចិត្តទុកដាក់បន្ថែម ដល់ការបង្កើនការប្រើប្រាស់ក្របខណ្ឌលទ្ធផលជាតិដែលមានស្រាប់ ។ ក្នុងឆ្នាំ២០១៨, ៦០% នៃហិរញ្ញប្បទានដែលបើកផ្តល់ដល់វិស័យសាធារណៈ បានប្រើប្រាស់ក្របខណ្ឌលទ្ធផលជាតិ ហើយបានកើនបន្តិច ដល់ ៦៣% ក្នុងឆ្នាំ២០១៩ ។ ក្នុងន័យនេះ ការបង្កើនការប្រើប្រាស់ក្របខណ្ឌលទ្ធផលជាតិរបស់ដៃគូអភិវឌ្ឍន៍ គឺជាប្រការសំខាន់ ដើម្បីឈានទៅសម្រេចបានចំណុចដៅ ៨០% ដូចបានកំណត់ក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។

ដៃគូអភិវឌ្ឍន៍គប្បីចូលរួមអនុវត្តគំនិតផ្តួចផ្តើមនានារបស់រាជរដ្ឋាភិបាល ដើម្បីឈានទៅបង្កើតប្រព័ន្ធគ្រប់គ្រងផ្តោតលើលទ្ធផល ។ រាជរដ្ឋាភិបាលបានអនុម័តក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា រួមទាំងចំណុចដៅ និងសូចនាករ ដែលបានក្លាយទៅជាក្របខណ្ឌលទ្ធផលសម្រាប់អនុវត្តគោលដៅអភិវឌ្ឍន៍ប្រកប

ដោយចីរភាពកម្ពុជា ។ តួអង្គអភិវឌ្ឍន៍ទាំងអស់នឹងប្រើប្រាស់កាន់តែច្រើនឡើងៗនូវក្របខណ្ឌលទ្ធផលនេះក្នុងការរៀបចំផែនការរបស់ខ្លួន ។ លើសពីនេះ រាជរដ្ឋាភិបាលបានរៀបចំសូចនាករសមិទ្ធកម្មគន្លឹះ ដែលជាក្របខណ្ឌតាមដានដោយផ្តោតលើលទ្ធផល សម្រាប់វាយតម្លៃវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្រ្តចតុកោណ-ដំណាក់កាលទី៤ ។ សម្រាប់ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៩-២០២៣ និងនៅកម្រិតវិស័យ ក្រសួង និងស្ថាប័ន បានធ្វើបច្ចុប្បន្នភាពយុទ្ធសាស្រ្ត និងផែនការតាមវិស័យ សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំថវិកា ។ ក្នុងស្មារតីនេះ ដៃគូអភិវឌ្ឍន៍គួរយកចិត្តទុកដាក់លើគំនិតផ្តួចផ្តើមទាំងនេះ ក្នុងពេលពិនិត្យឡើងវិញនូវក្របខណ្ឌលទ្ធផលរបស់ខ្លួន ។

រាជរដ្ឋាភិបាលបានប្តេជ្ញា និងខិតខំលើកកម្ពស់លទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព ក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ។ សមិទ្ធផលសំខាន់ៗរួមមាន÷ ការកៀរគរធនធាន និងការតម្រឹមជាមួយអាទិភាពនៃកិច្ចអភិវឌ្ឍន៍ជាតិ, ភាពជាដៃគូប្រកបដោយបរិយាប័ន្នក្នុងកិច្ចដំណើរការអភិវឌ្ឍន៍ និងការពង្រឹងការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ តាមរយៈការអភិវឌ្ឍសមត្ថភាពសម្រាប់អនុវត្តគោលនយោបាយ និងយន្តការសំខាន់ៗ ។ ជាក់ស្តែង យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ បានបន្តសម្របសម្រួលការអនុវត្តយន្តការភាពជាដៃគូ និងបានក្តាប់យកកាលានុវត្តភាពសម្រាប់កៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ និងពង្រឹងភាពជាដៃគូជាមួយគ្រប់ភាគីពាក់ព័ន្ធ ដើម្បីគាំទ្រការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ។ ក្នុងន័យនេះ តារាងទី២.២ បង្ហាញថា រាល់សូចនាកររបស់គោលដៅទី១៧ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលស្ថិតក្នុងអណត្តិការងាររបស់ ក.អ.ក/គ.ជ.នា សុទ្ធតែមានវឌ្ឍនភាពទាំងអស់ ទន្ទឹមនឹងសូចនាករមួយចំនួនសម្រេចបានលើសចំណុចដៅដែលបានកំណត់ ។

## តារាងទី ២.១ សូចនាករស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ តាមដៃគូអភិវឌ្ឍន៍

| | ការប្រើប្រាស់ក្របខណ្ឌលទ្ធផល(%) | | ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (%) | | ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ (%) | | ហិរញ្ញប្បទានកត់ត្រាក្នុងថវិការដ្ឋ (%) | | ភាពអាចទស្សន៍ទាយបាននៃហិរញ្ញប្បទានប្រចាំឆ្នាំ (%) | | ផែនការប្រចាំឆ្នាំផ្តល់ឱ្យប្រទេសដៃគូ | | ផែនការ ៣ ឆ្នាំផ្តល់ឱ្យប្រទេសដៃគូ | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2018 (ជាក់ស្តែង) | 2019 (ប៉ាន់ស្មាន) | 2018 (ជាក់ស្តែង) | 2019 (ប៉ាន់ស្មាន) | 2018 (ជាក់ស្តែង) | 2019 (ប៉ាន់ស្មាន) | 2018 | 2019 | 2018 | 2019 | 2018 | 2019 | 2018 | 2019 |
| UN Agencies | | | | | | | | | | | | | | |
| FAO | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 1383 | Yes | Yes | No | Yes |
| ILO | 100 | 100 | 0 | 0 | 0 | 0 | 0 | 0 | 0 | 125 | Yes | Yes | Yes | Yes |
| UN Women | 100 | 100 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | Yes | Yes | Yes | Yes |
| UN AIDS | 100 | 100 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | No | No | No | No |
| UNDP | 100 | 100 | 0 | 0 | 0 | 0 | 0 | 0 | 112 | 50 | Yes | Yes | Yes | Yes |
| UNESCO | 76 | 90 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | Yes | Yes | Yes | Yes |
| UNFPA | 100 | 100 | 0 | 7 | 0 | 11 | 0 | 0 | 0 | 0 | Yes | Yes | Yes | Yes |
| UNICEF | 100 | 100 | 100 | 100 | 0 | 0 | 0 | 0 | 59 | 0 | No | Yes | No | Yes |
| UNIDO | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | Yes | Yes | Yes | Yes |
| WFP | 100 | 100 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | No | Yes | No | Yes |
| WHO | 100 | 100 | 0 | 0 | 0 | 0 | 0 | 0 | 0 | 110 | No | No | No | No |
| IFAD | 100 | 100 | 100 | 100 | 100 | 100 | 100 | 79 | 144 | 69 | Yes | Yes | Yes | Yes |
| Multilateral | | | | | | | | | | | | | | |
| ADB | 100 | 100 | 99 | 100 | 99 | 100 | 100 | 98 | 58 | 106 | Yes | Yes | Yes | Yes |
| World Bank | 100 | 100 | 34 | 34 | 100 | 100 | 100 | 88 | 29 | 74 | Yes | Yes | Yes | Yes |
| Global Fund | 100 | 100 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | Yes | Yes | No | No |
| GAVI | 100 | 100 | 100 | 100 | 100 | 100 | 0 | 0 | 213 | 166 | Yes | Yes | No | No |
| European Union | | | | | | | | | | | | | | |
| EU/EC | 100 | 100 | 76 | 78 | 79 | 81 | 56 | 97 | 777 | 261 | Yes | Yes | Yes | Yes |
| Czech Rep | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | Yes | Yes | No | Yes |
| France | 95 | 98 | 95 | 98 | 95 | 98 | 0 | 97 | 0 | 86 | Yes | Yes | Yes | Yes |
| Germany | 100 | 100 | 36 | 32 | 50 | 35 | 8 | 38 | 315 | 102 | Yes | Yes | Yes | Yes |
| Ireland | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | Yes | Yes | No | No |
| Sweden | 100 | 49 | 63 | 32 | 94 | 48 | 0 | 0 | 0 | 182 | Yes | Yes | Yes | Yes |
| UK | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | No | Yes | No | No |
| Bilateral | | | | | | | | | | | | | | |
| Australia | 80 | 83 | 44 | 51 | 66 | 77 | 0 | 0 | 85 | 169 | Yes | Yes | Yes | Yes |
| Canada | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | Yes | Yes | Yes | Yes |
| China | 0 | 0 | 97 | 100 | 0 | 0 | 100 | 100 | 440 | 173 | Yes | Yes | Yes | Yes |
| Japan | 90 | 93 | 45 | 53 | 45 | 53 | 96 | 95 | 46 | 71 | Yes | Yes | Yes | Yes |
| New Zealand | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | Yes | Yes | Yes | Yes |
| Rep of Korea | 49 | 72 | 39 | 64 | 14 | 65 | 100 | 52 | 118 | 462 | Yes | Yes | Yes | Yes |
| Switzerland | 100 | 82 | 89 | 0 | 89 | 0 | 0 | 0 | 0 | 0 | Yes | Yes | Yes | Yes |
| USA | 59 | 78 | 0 | | 12 | 18 | 100 | 0 | 584 | 0 | Yes | Yes | Yes | Yes |
| **Total** | **60** | **63** | **75** | **81** | **41** | **50** | **92** | **92** | **119** | **122** | **98** | **99** | **91** | **98** |

តារាងទី ២.២: គោលដៅទី ១៧ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា: ពង្រឹងមធ្យោបាយអនុវត្ត និងបង្កើតភាពរស់រវើកនៃភាពជាដៃគូសកលសម្រាប់កិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព

| ចំណុចដៅ និងសូចនាករ | | ឯកតា | ចំណុចដៅគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា | | | | | ជាក់ស្តែង | | | | វឌ្ឍនភាព |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | 2015 | 2016 | 2017 | 2018 | 2019 | 2016 | 2017 | 2018 | 2019 | |
| 17.3 | កៀរគរធនធានហិរញ្ញវត្ថុបន្ថែមទៀតពីប្រភពចម្រុះ សម្រាប់ផ្តល់ដល់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ | | | | | | | | | | | សម្រេចបានដូចគ្រោងទុក |
| 17.3.1 | សមាមាត្រនៃហិរញ្ញប្បទានធៀបនឹង ផ.ស.ស | សមមាត្រធៀបនឹង ផ.ស.ស | 7.4 | 7.4 | 6.9 | 6.4 | 6.0 | 6.42 | 6.48 | 5.74 | 7.05 | សម្រេចបានមុនចំណុចដៅ |
| 17.9 | លើកកម្ពស់ការគាំទ្រពីអន្តរជាតិ សម្រាប់កសាងសមត្ថភាពដែលបានកំណត់ចំណុចដៅ ប្រកបដោយប្រសិទ្ធភាពក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ដើម្បីគាំទ្រផែនការជាតិ ក្នុងការអនុវត្តនូវគ្រប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (រួមទាំងកិច្ចសហប្រតិបត្តិការជើង-ត្បូង ,កិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការត្រីកោណ | | | | | | | | | | | សម្រេចបានដូចគ្រោងទុក |
| 17.9.1 | ទំហំហិរញ្ញប្បទានសហប្រតិបត្តិការ និងកិច្ចសហប្រតិបត្តិការបច្ចេកបច្ចេក (រួមទាំងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការត្រីកោណ ដែលបានសន្យាផ្តល់ដល់កម្ពុជា | សមមាត្រធៀបនឹង ផ.ស.ស | 1.31 | 1.31 | 1.23 | 1.15 | 1.07 | 1.86 | 1.88 | 1.15 | 1.85 | សម្រេចបានមុនចំណុចដៅ |
| 17.9.2 | ទំហំហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រគោលនយោបាយសេដ្ឋកិច្ច និងការអភិវឌ្ឍ ដែលបានប្តេជ្ញាផ្តល់ឱ្យកម្ពុជា ធៀបនឹងផែនការ | សមមាត្រធៀបនឹង ផ.ស.ស | 0.03 | 0.03 | 0.02 | 0.02 | 0.02 | 0.04 | 0.05 | 0.04 | 0.04 | សម្រេចបានមុនចំណុចដៅ |
| 17.10 | លើកកម្ពស់ប្រព័ន្ធពាណិជ្ជកម្មចម្រុះ, បើកទូលាយ និងសមធម៌ ដែលមានលក្ខណៈជាសកល និងផ្អែកលើមូលដ្ឋានច្បាប់ ក្រោមអង្គការពាណិជ្ជកម្មពិភពលោក រួមទាំងតាមរយៈការបញ្ចប់ការចរចា ក្រោមរបៀបវារៈ ទីក្រុងដូហាស្តីពីកិច្ចអភិវឌ្ឍន៍ | | | | | | | | | | | (ក្រសួងពាណិជ្ជកម្ម) |
| 17.10.1 | ចំនួនច្បាប់ និងបទដ្ឋានគតិយុត្តិពាណិជ្ជកម្ម ដែលបានរៀបចំឡើងដើម្បីសម្រួលដល់អ្នកវិនិយោគក្នុងស្រុក និងធុរជន (ក្រសួងពាណិជ្ជកម្ម) | ចំនួន | 7 | 7 | 7 | 8 | មិនមាន | 7 | 7 | 7 | មិនមាន | (ក្រសួងពាណិជ្ជកម្ម) |
| 17.17.1 | ទំហំហិរញ្ញប្បទានសហប្រតិបត្តិការដែលបានសន្យាផ្តល់ឱ្យសង្គមស៊ីវិល ធៀបនឹង ផ.ស.ស | សមមាត្រធៀបនឹង ផស.ស. | 0.01 | 0.01 | 0.01 | 0.01 | 0.01 | 0.03 | 0.03 | 0.02 | 0.05 | សម្រេចបានមុនចំណុចដៅ |

## *យន្តការភាពជាដៃគូថ្មី*

រាជរដ្ឋាភិបាលនឹងបន្តលើកកម្ពស់កិច្ចពិភាក្សាពហុភាគីនៅគ្រប់កម្រិត ។ ក្នុងន័យនេះ យុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០១៩-២០២៣ បានកំណត់យន្តការពិគ្រោះយោបល់ភាពជាដៃគូថ្មី ៣ បន្ថែម គឺ÷ ១) កិច្ចពិគ្រោះយោបល់ពហុភាគីនៅកម្រិតវិស័យ, ២) កិច្ចពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល និង ៣) កិច្ចពិគ្រោះយោបល់ភាពជាដៃគូនៅថ្នាក់ក្រោមជាតិ ។ សេចក្តីណែនាំសម្រាប់អនុវត្តយន្តការទាំងនេះ ត្រូវបានរៀបចំ និងអនុម័តដោយរាជរដ្ឋាភិបាល នាខែឧសភា ឆ្នាំ២០១៩ ។ រាជរដ្ឋាភិបាល

បានរៀបចំកិច្ចពិគ្រោះយោបល់ជាទៀងទាត់ រវាងរាជរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។ នៅថ្នាក់ជាតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានដឹកនាំកិច្ចពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ ហើយក្រសួងមហាផ្ទៃបានរៀបចំកិច្ចពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ។

នៅថ្នាក់ក្រោមជាតិ, រដ្ឋបាលរាជធានី-ខេត្តបានរៀបចំវេទិកាពិគ្រោះយោបល់រវាងរដ្ឋបាលរាជធានីខេត្ត និងអង្គការមិនមែនរដ្ឋាភិបាល/សហគមន៍មូលដ្ឋាន ។ វេទិកាសម្ព័ន្ធសង្គមស៊ីវិលបានសហការជាមួយរដ្ឋបាលរាជធានី-ខេត្ត ដើម្បីធានាកិច្ចពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន មានគោលដៅច្បាស់លាស់ និងប្រកបដោយបរិយាប័ន្ន ។ កិច្ចពិគ្រោះយោបល់បានផ្តោតលើកិច្ចប្រតិបត្តិការ និងបញ្ហាប្រឈមដែលអង្គការមិនមែនរដ្ឋាភិបាលបានជួបប្រទះក្នុងការអនុវត្តសកម្មភាពរបស់ខ្លួន នៅថ្នាក់ក្រោមជាតិ ។

ចំពោះកិច្ចពិគ្រោះយោបល់ភាពជាដៃគូនៅថ្នាក់ក្រោមជាតិ ក.អ.ក/គ.ជ.ទា បានសម្របសម្រួលជាមួយក្រសួងពាក់ព័ន្ធ និងរដ្ឋបាលរាជធានី-ខេត្ត ដើម្បីគ្រប់គ្រងការរៀបចំកិច្ចពិគ្រោះយោបល់នេះ ។ សិក្ខាសាលាត្រូវបានរៀបចំនៅគ្រប់រដ្ឋបាលរាជធានី-ខេត្តទាំង២៥ សម្រាប់ផ្សព្វផ្សាយសេចក្តីណែនាំស្តីពីកិច្ចពិគ្រោះយោបល់ភាពជាដៃគូនៅថ្នាក់ក្រោមជាតិ ។ យន្តការនេះនឹងត្រូវចាប់ដំណើរការនៅឆ្នាំ២០២០ ជាមួយគ្នានឹងវេទិកាសម្រាប់រៀបចំកម្មវិធីវិនិយោគ ៣ ឆ្នាំរំកិលរបស់រដ្ឋបាលរាជធានី-ខេត្ត ។

សរុបមក ទិន្នន័យ និងការវិភាគខាងលើនេះបានផ្អែកលើក្របខណ្ឌតាមដានថ្នាក់ជាតិ និងសកល ។ ដៃគូអភិវឌ្ឍន៍នឹងធ្វើការកាន់តែជិតស្និទ្ធថែមទៀតជាមួយរាជរដ្ឋាភិបាល ដើម្បីបន្តពង្រឹងឧត្តមានុវត្តន៍នៃភាពជាដៃគូ ។ វឌ្ឍនភាពសំខាន់ៗដូចបានរៀបរាប់ក្នុងរបាយការណ៍នេះ គឺជាមូលដ្ឋានគ្រឹះសម្រាប់ឈានទៅសម្រេចបានការប្តេជ្ញាសកលស្តីពីស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ។ ការប្រើប្រាស់ក្របខណ្ឌលទ្ធផលរបស់រាជរដ្ឋាភិបាល ដែលផ្សារភ្ជាប់ទៅនឹងប្រព័ន្ធផែនការ និងតាមដានរបស់រាជរដ្ឋាភិបាល បានក្លាយជាកិច្ចការសំខាន់ក្នុងការបន្តកិច្ចខិតខំប្រឹងប្រែង ដើម្បីឈានទៅសម្រេចបានស័ក្តិសិទ្ធិភាពក្នុងកិច្ចអភិវឌ្ឍន៍ ហើយត្រូវរំលេចទៅក្នុងប្រព័ន្ធផែនការ, ការអនុវត្ត និងវាយតម្លៃរបស់ដៃគូអភិវឌ្ឍន៍ ។

# ជំពូកទី ៣

# ការវិវត្តនៃហិរញ្ញប្បទានសហប្រតិបត្តិការ

ជំពូកនេះឆ្លុះបញ្ចាំងពីការវិវត្តនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដោយវិភាគអំពីការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ ផ្អែកលើទិន្នន័យគិតត្រឹមថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១៩ ។ ការវិភាគក៏បានផ្តោតលើនិន្នាការនៃការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ក្នុងទសវត្សរ៍ចុងក្រោយ ទន្ទឹមនឹងការផ្តោតសំខាន់លើការបើកផ្តល់ហិរញ្ញប្បទានក្នុងឆ្នាំ២០១៨ និងការប៉ាន់ស្មានក្នុងឆ្នាំ២០១៩ ។ ព័ត៌មាន និងការវិភាគទាំងនេះ គឺជាមូលដ្ឋានសំខាន់សម្រាប់រៀបចំគោលនយោបាយ, ការគ្រប់គ្រង និងកិច្ចពិគ្រោះយោបល់ សម្រាប់សម្របសម្រួលភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ ។

### *ការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ*

ការបើកផ្តល់ហិរញ្ញប្បទានសរុប បានកើនពី ១.៤៩០ លានដុល្លារ ក្នុងឆ្នាំ២០១៨ ដល់ ១.៨៨៨ លានដុល្លារ ក្នុងឆ្នាំ២០១៩ ដោយសារកំណើនឥណទានសម្បទាន ។ អនុបាតនៃឥណទានសម្បទាន ធៀបនឹងហិរញ្ញប្បទានឥតសំណង បានកើនពី ២៥% ក្នុងឆ្នាំ២០១០ ដល់ ៥៣% ក្នុងឆ្នាំ២០១៩ ។

ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការនៅកម្ពុជា មានការប្រែប្រួលគួរឱ្យកត់សម្គាល់ក្នុងទសវត្សរ៍ចុងក្រោយនេះ ។ គំនូសទី ៣.១ បង្ហាញថា ការបើកផ្តល់ហិរញ្ញប្បទានសរុបបានបន្តកើនឡើងម្តងទៀត ចាប់ពីឆ្នាំ២០១៧ បន្ទាប់ពីបានកើនខ្ពស់បំផុតក្នុងឆ្នាំ២០១២ ។ ហិរញ្ញប្បទានឥតសំណងមានទំហំថេរ ក្នុងរង្វង់ ៨០០ លានដុល្លារ ក្នុងមួយឆ្នាំ ដោយបានកើនបន្តិច ពី ៨១៣ លានដុល្លារ ក្នុងឆ្នាំ២០១៦ ដល់ ៨៩៣ លានដុល្លារ ក្នុងឆ្នាំ២០១៩ ។ ការបង្កើនការបើកផ្តល់ឥណទានសម្បទានពីសាធារណរដ្ឋបារាំង, សាធារណរដ្ឋប្រជាមានិតចិន, ជប៉ុន និងធនាគារអភិវឌ្ឍន៍អាស៊ី បានជំរុញឱ្យមានការកើនឡើងនូវអនុបាតនៃឥណទានសម្បទានធៀបនឹងហិរញ្ញប្បទានឥតសំណង ។ ការព្យាករណ៍សម្រាប់ឆ្នាំ២០២០ និងឆ្នាំ២០២១ បានបង្ហាញអំពីការបន្តគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ ដោយសារការកើនឡើងនៃឥណទានសម្បទាន ទន្ទឹមនឹងការប្រែប្រួលទំហំធនធានផ្តល់ដោយដៃគូអភិវឌ្ឍន៍ ។

គំនូសទី ៣.២ បង្ហាញថា ទន្ទឹមនឹងការកើនឡើងនៃហិរញ្ញប្បទានសម្រាប់ប្រជាជនម្នាក់ ចាប់ពីឆ្នាំ២០១០, អនុបាតហិរញ្ញប្បទាន ធៀបនឹង ផ.ស.ស បានធ្លាក់ចុះ ។ ប្រការនេះបង្ហាញអំពីកំណើន ផ.ស.ស ខ្ពស់ប្រកបដោយចីរភាព ។ ក្នុងន័យនេះ ហិរញ្ញប្បទានសហប្រតិបត្តិការគឺជាធនធានសំខាន់ សម្រាប់ជួយជំរុញកំណើនសេដ្ឋកិច្ច និងគាំទ្រការផ្តល់សេវាសាធារណៈ ។

គំនូរទី ៣.១ ការបើកផ្តល់ហិរញ្ញប្បទាន ឆ្នាំ២០១០-២០២១




គំនូរទី ៣.២ ហិរញ្ញប្បទានសម្រាប់ប្រជាជនម្នាក់ និងអនុបាតហិរញ្ញប្បទានធៀបនឹង ផ.ស.ស ឆ្នាំ២០១០-២០២១




ការសម្រេចឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបរបស់ប្រទេសមួយចំនួន អាចនាំទៅដល់ការធ្លាក់ចុះនៃទំហំហិរញ្ញប្បទានសហប្រតិបត្តិការ ។ ប៉ុន្តែ ជាក់ស្តែង កន្លងមក ករណីនេះពុំទាន់កើតឡើងនៅកម្ពុជាឡើយ ដោយសារកម្ពុជាកំពុងស្ថិតក្នុងឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួច និងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការកៀរគរឥណទានសម្បទាន ។

តារាងទី ៣.១ បង្ហាញអំពីការបន្តគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ ក្នុងចន្លោះឆ្នាំ២០១១-២០២១ ទោះបីទំហំធនធានមានការប្រែប្រួលក៏ដោយ ÷

- ដៃគូអភិវឌ្ឍន៍ពហុភាគីបានបង្កើនការគាំទ្ររបស់ខ្លួន ។ ការគាំទ្ររបស់ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ មានការកើនឡើងគួរឱ្យកត់សម្គាល់ ។ ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី បានបង្កើនការបើកផ្តល់ហិរញ្ញប្បទានរៀងៗខ្លួន ពី ១៧ លានដុល្លារ និង ១១៨ លានដុល្លារ ក្នុងឆ្នាំ២០១៦ ដល់ ៧០ លានដុល្លារ និង ២៤៦ លានដុល្លារ ក្នុងឆ្នាំ២០១៩ ។ ទំហំធនធានរបស់ស្ថាប័នទាំងពីរនេះអាចបន្តកើនឡើងបន្ថែមទៀត ក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ ។
- ការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូទ្វេភាគី មានការប្រែប្រួលខ្លាំង ។ សាធារណរដ្ឋប្រជាមានិតចិនបានផ្តល់ហិរញ្ញប្បទានច្រើនជាងគេ ៣៥៣ លានដុល្លារ ក្នុងឆ្នាំ២០១៨ និងកើនដល់ ៥០០ លានដុល្លារ ក្នុងឆ្នាំ២០១៩ ។
- ការបើកផ្តល់របស់ប្រទេសជាសមាជិកសហភាពអឺរ៉ុប បានធ្លាក់ចុះ លើកលែងតែសាធារណរដ្ឋបារាំង ដែលបានបង្កើនការបើកផ្តល់ហិរញ្ញប្បទាន ២០៧ លានដុល្លារ ក្នុងឆ្នាំ ២០១៩ និងគ្រោងបើកផ្តល់ ២៥៨ លានដុល្លារ ក្នុងឆ្នាំ២០២០ និង ៤៦៤ លានដុល្លារ ក្នុងឆ្នាំ២០២១ (រាប់បញ្ចូលគម្រោងដែលគ្រោងអនុវត្ត) ។ ទោះជាយ៉ាងនេះក្តី ការបើកផ្តល់របស់គណៈកម្មាធិការអឺរ៉ុបប្រចាំកម្ពុជាបានកើនឡើង បន្ទាប់ពីមានកិច្ចព្រមព្រៀងលើកម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍រួមគ្នា រវាងប្រទេសជាសមាជិកសហភាពអឺរ៉ុប ។ អាល្លឺម៉ង់

និងស៊ុយអែត បានកាត់បន្ថយការបើកផ្តល់ហិរញ្ញប្បទាន ដោយសារធនធានមួយផ្នែករបស់ពួកគេ ត្រូវបានផ្តល់ឱ្យសហគមអឺរ៉ុប សម្រាប់អនុវត្តកម្មវិធីសហប្រតិបត្តិការអភិវឌ្ឍន៍រួមគ្នា ។

- ការបើកផ្តល់របស់សហរដ្ឋអាមេរិក មានការធ្លាក់ចុះ ដោយសារមានការយឺតយ៉ាវក្នុងការរៀបចំផែនការ ។ រីឯការបើកផ្តល់របស់អូស្ត្រាលីក៏ធ្លាក់ចុះជាបន្តបន្ទាប់ ដោយសារគោលនយោបាយរបស់ទីស្នាក់ការកណ្តាលក្នុងការកាត់បន្ថយហិរញ្ញប្បទាន ។ ប៉ុន្តែ ដៃគូអភិវឌ្ឍន៍ទាំងនេះ នៅបន្តគាំទ្រក្នុងវិស័យដែលមានឧត្តមភាពប្រៀបធៀប ដូចជាខ្សែចង្វាក់តម្លៃកសិកម្ម, ហេដ្ឋារចនាសម្ព័ន្ធជនបទ និងសុខាភិបាល ។ល។

### តារាងទី ៣.១ ការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ (លានដុល្លារ)

| ដៃគូអភិវឌ្ឍន៍ | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 ប៉ាន់ស្មាន | 2020 ព្យាករណ៍ | 2021 ព្យាករណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|
| ភ្នាក់ងារអង្គការសហប្រជាជាតិ | | | | | | | | | | | |
| Total Program Delivered | 89.5 | 88.1 | 100.6 | 107.2 | 93.7 | 91.7 | 87.4 | 79.0 | 98.5 | - | - |
| Total Own Fund Disbursed | 56.5 | 54.3 | 50.0 | 53.9 | 47.2 | 65.7 | 59.4 | 55.1 | 66.5 | 80.6 | 56.2 |
| ដៃគូពហុភាគី | | | | | | | | | | | |
| Work Bank | 73.8 | 66.0 | 35.5 | 50.6 | 17.6 | 17.6 | 21.1 | 24.8 | 69.7 | 140.8 | 124.4 |
| Asian Development Bank | 126.9 | 82.0 | 171.4 | 129.8 | 137.2 | 118.2 | 125.7 | 135.9 | 246.0 | 283.1 | 259.3 |
| GAVI Alliance | 6.7 | 4.9 | 10.7 | 5.5 | 19.0 | 16.3 | 10.9 | 7.4 | 8.7 | 5.4 | - |
| Global Fund | 60.2 | 20.1 | 45.4 | 54.6 | 33.3 | 28.2 | 33.1 | 19.9 | 40.9 | 33.9 | - |
| **សរុប** | **324.1** | **227.3** | **313.0** | **294.4** | **254.3** | **246.0** | **250.1** | **243.1** | **431.8** | **543.7** | **440.0** |
| សហភាពអឺរ៉ុប | | | | | | | | | | | |
| European Commission | 61.0 | 41.6 | 36.6 | 70.3 | 55.8 | 55.7 | 50.8 | 89.7 | 64.6 | 90.3 | 75.5 |
| Czech Republic | - | - | 1.0 | 1.2 | 1.2 | 1.5 | 1.3 | 1.1 | 2.0 | 0.7 | 0.1 |
| France | 19.5 | 24.8 | 17.8 | 59.5 | 63.3 | 32.1 | 90.8 | 78.9 | 207.8 | 62.2 | 12.5 |
| Germany | 43.7 | 44.6 | 34.3 | 29.8 | 25.8 | 46.9 | 38.4 | 40.5 | 24.9 | 25.6 | 21.0 |
| Ireland | 0.7 | 0.3 | 1.2 | 0.7 | 0.6 | 0.6 | 0.7 | 0.8 | 0.8 | 0.7 | - |
| Sweden | 28.6 | 30.2 | 33.8 | 33.0 | 21.8 | 30.1 | 33.5 | 23.8 | 23.8 | 12.4 | 3.0 |
| United Kingdom | 34.2 | 28.2 | 13.7 | 0.1 | 0.2 | 1.6 | 2.3 | 1.2 | 0.9 | 0.1 | - |
| Other EU Member States | 48.3 | 18.2 | 9.9 | 6.0 | - | - | - | - | - | - | - |
| **សរុប** | **236.1** | **187.9** | **148.3** | **200.6** | **168.7** | **168.6** | **217.8** | **235.8** | **324.7** | **192.0** | **112.1** |
| ដៃគូទ្វេភាគី | | | | | | | | | | | |
| Australia | 78.2 | 79.5 | 59.3 | 64.9 | 55.9 | 51.9 | 58.3 | 49.2 | 38.8 | 28.4 | 26.7 |
| Canada | 18.5 | 20.5 | 11.8 | 5.7 | 3.8 | 3.2 | 3.4 | 3.1 | 2.0 | 1.0 | 1.1 |
| China | 332.0 | 460.7 | 436.6 | 347.8 | 339.4 | 307.2 | 415.8 | 353.0 | 496.2 | 421.6 | 257.4 |
| Japan | 114.4 | 172.3 | 130.8 | 111.4 | 110.4 | 119.7 | 146.4 | 175.4 | 192.7 | 336.5 | 298.3 |
| New Zealand | 4.4 | 3.8 | 3.2 | 6.0 | 4.9 | 4.0 | 4.9 | 5.0 | 7.2 | 2.5 | 2.3 |
| Republic of Korea | 45.3 | 46.2 | 50.1 | 80.3 | 61.7 | 42.0 | 57.1 | 44.1 | 71.3 | 58.0 | 72.5 |
| Switzerland | 4.5 | 4.3 | 7.8 | 11.8 | 13.0 | 15.8 | 15.5 | 14.0 | 13.4 | 8.3 | 6.7 |
| United States of America | 64.4 | 85.0 | 93.5 | 91.6 | 101.0 | 77.9 | 93.2 | 94.8 | 59.6 | 43.9 | 31.0 |
| **សរុប** | **661.8** | **872.3** | **793.1** | **719.6** | **690.0** | **621.6** | **794.5** | **738.6** | **881.2** | **900.2** | **696.1** |
| NGO (ធនធានផ្ទាល់) | 200.7 | 212.3 | 220.8 | 228.9 | 237.0 | 251.0 | 259.8 | 273.1 | 250.2 | 42.0 | 10.7 |
| គម្រោងត្រៀមអនុវត្ត | - | - | - | - | - | - | - | - | - | 219.8 | 483.4 |
| **សរុបរួម** | **1,422.6** | **1,499.7** | **1,475.1** | **1,443.4** | **1,350.1** | **1,287.1** | **1,522.2** | **1,490.6** | **1,887.9** | **1,897.7** | **1,742.3** |

## *ការប្រែប្រួលសំខាន់ៗនៃការបើកផ្តល់ហិរញ្ញប្បទាន*

ផ្នែកនេះរំលេចអំពីការប្រែប្រួលគួរឱ្យកត់សម្គាល់នៃការបើកផ្តល់ហិរញ្ញប្បទាន ។ គំនូរទី ៣.៣ បង្ហាញថា សាធារណរដ្ឋប្រជាមានិតចិន គឺជាដៃគូធំជាងគេ ដែលបានបើកផ្តល់ហិរញ្ញប្បទាន ប្រមាណ ៤០០ លានដុល្លារ ជាមធ្យម ក្នុងមួយឆ្នាំ ។ ក្នុងឆ្នាំ២០១៩ សាធារណរដ្ឋបារាំង និងធនាគារពិភពលោក បានបង្កើនការបើកផ្តល់របស់ខ្លួន ៣ ដង ធៀបនឹងឆ្នាំ២០១៦ ។ រីឯធនាគារអភិវឌ្ឍន៍អាស៊ី បានបង្កើនការបើកផ្តល់ទ្វេដង ពី ១១៨ លានដុល្លារ ក្នុងឆ្នាំ២០១៦ ដល់ ២៤៦ លានដុល្លារ ក្នុងឆ្នាំ២០១៩ ក្នុងពេលដែលសាធារណរដ្ឋប្រជាមានិតចិន, កូរ៉េ និងជប៉ុន បានបង្កើនការបើកផ្តល់ហិរញ្ញប្បទានរៀងៗខ្លួន ប្រមាណ ៦២%, ៧០% និង៦១% ។ អនុបាតនៃការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូទាំង ៦ នេះ ធៀបនឹងហិរញ្ញប្បទានសរុប បានកើនពី ៤៩% ក្នុងឆ្នាំ២០១៦ ដល់ ៦៨% ក្នុងឆ្នាំ២០១៩ ។ គំនូរទី ៣.៤ បង្ហាញថា សាធារណរដ្ឋប្រជាមានិតចិន និងកូរ៉េ បានបង្កើនការផ្តល់ហិរញ្ញប្បទានឥតសំណង ទន្ទឹមនឹងការបង្កើនការផ្តល់ឥណទានសម្បទាន ។

**គំនូរទី ៣.៣ ដៃគូផ្តល់ហិរញ្ញប្បទានសំខាន់ៗ ឆ្នាំ២០១៦-២០២១**




**គំនូរ ៣.៤ ទំហំហិរញ្ញប្បទានដែលផ្តល់ដោយដៃគូសំខាន់ ឆ្នាំ២០១៦-២០២១**




## *ការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ*

ជារួម ការបើកផ្តល់ហិរញ្ញប្បទានត្រូវបានតម្រឹមជាមួយអាទិភាពរបស់រាជរដ្ឋាភិបាល ។ ដោយយុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៤ បានផ្តោតលើការធ្វើទំនើបកម្មសេដ្ឋកិច្ចតាមគំរូកំណើនថ្មី ដោយផ្អែកលើអភិក្រមស្តីពីការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាប័ន្ន, ការបើកផ្តល់ហិរញ្ញប្បទានត្រូវបានបង្វែរទៅគាំទ្រកម្មវិធីអភិវឌ្ឍន៍ដែលផ្តោតលើកំណើនសេដ្ឋកិច្ច ។ តារាងទី ៣.២ បង្ហាញថា វិស័យសង្គមកិច្ចបានទទួលហិរញ្ញប្បទាន ៥៣២ លានដុល្លារ ក្នុងឆ្នាំ២០១៩ ។ បន្ទាប់មក គឺវិស័យហេដ្ឋារចនាសម្ព័ន្ធ និងវិស័យសេដ្ឋកិច្ច ដែលហិរញ្ញប្បទានកើនឡើងទ្វេដង ចាប់ពីឆ្នាំ២០១១ ទន្ទឹមនឹងការបើកផ្តល់សម្រាប់អន្តរវិស័យនៅរក្សាទំហំថេរ ក្នុងរយៈពេលដូចគ្នា ។

## តារាងទី ៣.២ - ការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ ឆ្នាំ២០១១-២០២១ (លានដុល្លារ)

| វិស័យ | 2011 | 2012 | 2013 | 2014 | 2015 | 2016 | 2017 | 2018 | 2019 ប៉ាន់ស្មាន | 2020 ព្យាករណ៍ | 2021 ព្យាករណ៍ |
|---|---|---|---|---|---|---|---|---|---|---|---|
| **វិស័យសង្គមកិច្ច** | | | | | | | | | | | |
| សុខាភិបាល | 205.3 | 203.0 | 203.5 | 204.8 | 204.0 | 217.0 | 187.6 | 221.0 | 244.2 | 156.2 | 114.1 |
| ហ៊ីវ/ អេដស៍ | 69.4 | 33.5 | 34.7 | 45.8 | 30.2 | 23.9 | 23.9 | 13.5 | 11.7 | 1.1 | - |
| អប់រំ | 154.6 | 135.3 | 140.6 | 167.1 | 174.1 | 177.8 | 194.6 | 199.6 | 213.8 | 192.9 | 141.6 |
| សហគមន៍ និងសុខុមាលភាពសង្គម | 138.2 | 136.4 | 81.1 | 82.9 | 98.2 | 66.3 | 70.3 | 70.1 | 61.8 | 24.3 | 14.6 |
| **សរុប** | **567.5** | **508.2** | **459.9** | **500.6** | **506.5** | **485.0** | **476.4** | **504.2** | **531.5** | **374.5** | **270.3** |
| **វិស័យសេដ្ឋកិច្ច** | | | | | | | | | | | |
| កសិកម្ម | 144.9 | 185.4 | 184.6 | 218.1 | 171.1 | 145.3 | 184.3 | 183.2 | 309.2 | 209.6 | 309.1 |
| អភិវឌ្ឍន៍ជនបទ | 48.6 | 81.3 | 77.0 | 85.5 | 93.6 | 68.1 | 105.7 | 93.6 | 94.7 | 109.6 | 75.4 |
| កម្មន្តសាល រ៉ែ និងពាណិជ្ជកម្ម | 13.4 | 11.4 | 11.1 | 3.2 | 4.5 | 5.9 | 22.9 | 7.2 | 10.1 | 7.7 | 7.1 |
| សេវាធនាគារ និងធុរកិច្ច | 73.1 | 4.0 | 43.8 | 14.3 | 27.0 | 13.6 | 11.6 | 8.5 | 2.8 | 0.9 | 0.1 |
| នគរូបនីយកម្ម និងការគ្រប់គ្រង | 2.7 | 11.9 | 0.3 | 6.6 | 7.4 | 6.0 | 4.2 | 11.3 | 55.9 | 88.9 | 129.2 |
| **សរុប** | **282.7** | **294.0** | **316.8** | **327.7** | **303.6** | **238.9** | **328.7** | **303.8** | **472.7** | **416.7** | **520.9** |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | | | | |
| ការដឹកជញ្ជូន | 271.2 | 383.6 | 379.0 | 309.4 | 286.8 | 190.8 | 267.9 | 303.1 | 348.2 | 488.1 | 495.3 |
| ទឹកស្អាត និងអនាម័យ | 36.1 | 52.3 | 59.3 | 63.7 | 37.8 | 39.0 | 86.1 | 77.5 | 151.4 | 177.5 | 98.8 |
| ថាមពល និងអគ្គិសនី | 57.3 | 66.7 | 60.1 | 66.5 | 54.8 | 158.5 | 157.8 | 101.1 | 175.5 | 289.5 | 175.2 |
| ព័ត៌មាន និងទូរគមនាគមន៍ | 0.2 | 1.3 | 3.0 | 10.8 | 5.0 | 12.5 | 0.3 | 0.9 | 1.1 | 2.2 | 7.9 |
| **សរុប** | **364.8** | **503.9** | **501.4** | **450.4** | **384.4** | **400.8** | **512.1** | **482.6** | **676.2** | **957.3** | **777.2** |
| **អន្តរវិស័យ** | | | | | | | | | | | |
| យេនឌ័រ | 6.4 | 9.3 | 10.0 | 8.5 | 6.1 | 6.7 | 4.2 | 6.5 | 5.2 | 4.9 | 3.8 |
| ទេសចរណ៍ | 2.2 | 0.8 | 0.7 | 0.6 | 1.8 | 1.4 | 15.0 | 2.8 | 7.1 | 8.7 | 0.4 |
| បរិស្ថាន និងចីរភាព | 18.1 | 14.2 | 24.3 | 26.8 | 33.1 | 30.1 | 27.7 | 43.0 | 36.1 | 17.3 | 13.7 |
| ការប្រែប្រួលអាកាសធាតុ | 5.9 | 7.3 | 8.8 | 7.0 | 7.7 | 7.5 | 7.9 | 11.6 | 13.3 | 4.8 | 31.9 |
| វប្បធម៌ និងសិល្បៈ | 4.3 | 4.6 | 4.6 | 5.5 | 6.2 | 3.9 | 34.1 | 42.6 | 63.8 | 26.1 | 4.2 |
| អភិបាលកិច្ច និងរដ្ឋបាល | 111.9 | 100.7 | 117.7 | 84.3 | 77.8 | 103.6 | 76.2 | 91.2 | 64.7 | 60.8 | 48.7 |
| ការទ្រទ្រង់ថវិកា និងជញ្ជីងទូទាត់ | 0.3 | 14.8 | - | - | - | - | - | - | - | - | 55.9 |
| ជំនួយសង្គ្រោះបន្ទាន់ និងស្បៀងអាហារ | 25.5 | 25.0 | 19.3 | 25.2 | 14.8 | 1.3 | 0.2 | 0.2 | 3.2 | 0.2 | 0.3 |
| **សរុប** | **174.6** | **176.7** | **185.4** | **157.9** | **147.5** | **154.5** | **165.3** | **197.9** | **193.4** | **122.8** | **158.9** |
| ផ្សេងៗ | 32.9 | 17.0 | 11.6 | 7.0 | 7.8 | 8.0 | 39.8 | 2.0 | 14.1 | 26.5 | 15.0 |
| **សរុបរួម** | **1,422.6** | **1,499.7** | **1,475.1** | **1,443.4** | **1,350.1** | **1,287.1** | **1,522.2** | **1,490.6** | **1,887.9** | **1,897.7** | **1,742.3** |

គំនូសទី ៣.៥- អនុបាតនៃការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ ឆ្នាំ២០១៤-២០២១




គំនូសទី ៣.៥ បង្ហាញថា ហិរញ្ញប្បទានសម្រាប់វិស័យសង្គមកិច្ច ធៀបនឹងហិរញ្ញប្បទានសរុប បានធ្លាក់ចុះពី ៣៥% ក្នុងឆ្នាំ២០១៤ មកត្រឹម ២៨% ក្នុងឆ្នាំ២០១៩ ទន្ទឹមនឹងពេលដែលហិរញ្ញប្បទាន សម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធ កើនពី ៣១% ដល់ ៣៦% និងវិស័យសេដ្ឋកិច្ច កើនពី ២៣% ដល់ ២៥% ។ ហិរញ្ញប្បទានសម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានរំពឹងថា នឹងបន្តកើនឡើងក្នុងឆ្នាំ២០២០ និងឆ្នាំ២០២១ ។ ការបន្តធ្លាក់ចុះនៃធនធានរបស់ដៃគូអភិវឌ្ឍន៍ក្នុងវិស័យសង្គមកិច្ច ត្រូវបានបំពេញដោយការបង្កើនថវិការបស់រាជរដ្ឋាភិបាល ។

## *ទម្រង់ និងទំហំនៃការបើកផ្តល់ឥណទានសម្បទាន ឆ្នាំ២០១៤-២០២១*

ដូចបានរៀបរាប់ខាងដើម, ទំហំហិរញ្ញប្បទានបានកើនឡើងនាពេលថ្មីៗនេះ ដោយសារកំណើនឥណទានសម្បទាន សម្រាប់គាំទ្រការធ្វើទំនើបកម្មសេដ្ឋកិច្ច និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ។ ផ្នែកនេះបង្ហាញអំពីការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍តាមទម្រង់ និងតាមវិស័យអាទិភាព ។

គំនូសទី ៣.៦ បង្ហាញអំពីការកើនឡើងរយៈពេលវែងនៃហិរញ្ញប្បទានសម្រាប់វិនិយោគ ទន្ទឹមនឹងការធ្លាក់ចុះនៃកិច្ចសហប្រតិបត្តិការបច្ចេកទេស ។ គំនូរខាងឆ្វេងបានឆ្លុះបញ្ចាំងពីបរិការណ៍បច្ចុប្បន្ន ដែលរាជរដ្ឋាភិបាលបានផ្តោតអាទិភាពខ្ពស់លើការវិនិយោគហេដ្ឋារចនាសម្ព័ន្ធ និងការធ្វើទំនើបកម្មសេដ្ឋកិច្ច ។ អាទិភាពទាំងនេះបានជំរុញឱ្យមានកំណើនឥណទានសម្បទានរបស់ដៃគូអភិវឌ្ឍន៍ (គំនូរខាងស្តាំ) សម្រាប់លើកកម្ពស់ប្រព័ន្ធដឹកជញ្ជូន, ការផ្គត់ផ្គង់ថាមពលអគ្គិសនី និងទឹកស្អាត ក្នុងគោលដៅជំរុញផលិតកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្ម ។

ក្នុងចន្លោះឆ្នាំ២០១៤-២០១៨ ការបើកផ្តល់ហិរញ្ញប្បទាន និងកំណើនឥណទានសម្បទានក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ និងវិស័យសេដ្ឋកិច្ច មិនសូវមានសន្ទុះកើនឡើងខ្លាំងក្លាឡើយ ។ ប៉ុន្តែ ចាប់ពីឆ្នាំ២០១៩ ឥណទានសម្បទានបានកើនឡើងខ្លាំងស្ទើរគ្រប់វិស័យ ពោលគឺ កើនដល់ ៦០០ លានដុល្លារ ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ និង ៣២០ លានដុល្លារ ក្នុងវិស័យសេដ្ឋកិច្ច ហើយអាចបន្តកើនឡើងក្នុងឆ្នាំបន្តបន្ទាប់ទៀត ។ ឥណទានសម្បទានក៏មានកំណើនផងដែរក្នុងវិស័យសង្គមកិច្ច និងអន្តរវិស័យផងដែរ ។

គំនូរទី ៣.៦ ទម្រង់នៃការបើកផ្តល់របស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៤-២០២១




### *ការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះ*

ក្រុមការងារបច្ចេកទេសចម្រុះ គឺជាយន្តការពិគ្រោះយោបល់កម្រិតបច្ចេកទេស សម្រាប់សម្របសម្រួលភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ ដើម្បីសម្រេចលទ្ធផលក្នុងកិច្ចអភិវឌ្ឍន៍ប្រកបដោយបរិយាប័ន្ន និងគណនេយ្យភាព ។ តារាងទី ៣.៣ បង្ហាញថា ក្នុងចន្លោះឆ្នាំ២០១៧-២០២១ គម្រោងចំនួន ៧៨៤ ដែលមានធនធានគិតជាមធ្យម ១.២០០ លានដុល្លារ ក្នុងមួយឆ្នាំ ស្មើនឹង ៨៥% នៃហិរញ្ញប្បទានសរុប ត្រូវបានសម្របសម្រួលដោយក្រុមការងារបច្ចេកទេសចម្រុះ ។

ក្រុមការងារបច្ចេកទេសចម្រុះស្តីពីហេដ្ឋារចនាសម្ព័ន្ធ និងសមាហរណកម្មតំបន់ បានសម្របសម្រួលគម្រោង និងហិរញ្ញប្បទានច្រើនជាងគេ ។ រីឯក្រុមការងារសុខាភិបាល, កសិកម្ម និងទឹក, និងអប់រំ បានទទួលការចូលរួមពីដៃគូអភិវឌ្ឍន៍ច្រើនជាងគេ (១៦, ១៥ និង ១៣ដៃគូអភិវឌ្ឍន៍) ។ ក្រុមការងារស្តីពីការអភិវឌ្ឍវិស័យឯកជន បានសម្របសម្រួលគម្រោងចំនួន ៣ និងមានដៃគូចំនួន ៣ ប៉ុណ្ណោះ ។ ទន្ទឹមនឹងនេះ ក៏គប្បីផ្តោតការយកចិត្តទុកដាក់ដល់ក្រុមការងារកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ និងក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈ ដែលបានសម្របសម្រួលគម្រោងចំនួន ៤ និងមានដៃគូអភិវឌ្ឍន៍ចូលរួមតែ ៣ ប៉ុណ្ណោះ ។

តារាងទី ៣.៣ ការបើកផ្តល់ និងសកម្មភាពរបស់ដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះ ឆ្នាំ២០១៧-២០២១

| ក្រុមការងារបច្ចេកទេសចម្រុះ | ចំនួនគម្រោងសម្របសម្រួលដោយក្រុមការងារ | ចំនួនដៃគូអភិវឌ្ឍន៍ចូលរួម | ការបើកផ្តល់ជាមធ្យមឆ្នាំ២០១៧-២០២១ | ចំនួនគម្រោងជាមធ្យម |
|---|---|---|---|---|
| **វិស័យសង្គមកិច្ច** | | | | |
| សុខាភិបាល | 48 | 16 | 83.1 | 1.7 |
| ហ៊ីវ/ អេដស៍ | 5 | 3 | 3.0 | 0.6 |
| អប់រំ | 47 | 13 | 72.0 | 1.5 |
| សន្តិសុខស្បៀង និងអាហារូបត្ថម្ភ | 11 | 6 | 8.1 | 0.7 |
| ទឹកស្អាតជនបទ និងអនាម័យ | 15 | 4 | 25.2 | 1.7 |
| បណ្តុះបណ្តាល និងវិជ្ជាជីវៈ | 6 | 3 | 1.9 | 0.3 |
| **សរុប** | **132** | **45** | **193.2** | **6.6** |
| **វិស័យសេដ្ឋកិច្ច** | | | | |
| កសិកម្ម និងទឹក | 78 | 15 | 172.2 | 2.2 |
| នេសាទ | 17 | 7 | 23.8 | 1.4 |
| ព្រៃឈើ | 14 | 8 | 8.6 | 0.6 |
| ការគ្រប់គ្រងដីធ្លី | 2 | 2 | 0.4 | 0.2 |
| ការកំចាត់មីន | 11 | 7 | 11.8 | 1.1 |
| ការអភិវឌ្ឍវិស័យឯកជន | 3 | 3 | 7.8 | 2.6 |
| **សរុប** | **125** | **42** | **224.6** | **8.1** |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | | |
| ហេដ្ឋារចនាសម្ព័ន្ធ និងសមាហរណកម្មតំបន់ | 87 | 8 | 564.3 | 6.5 |
| **សរុប** | **87** | **8** | **564.3** | **6.5** |
| **អន្តរវិស័យ និងរដ្ឋបាល** | | | | |
| ការប្រែប្រួលអាកាសធាតុ | 9 | 5 | 0.9 | 0.1 |
| វិមជ្ឈការ និងវិសហមជ្ឈការ | 16 | 9 | 16.2 | 1.0 |
| យេនឌ័រ | 14 | 9 | 8.0 | 0.6 |
| ការកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ | 4 | 3 | 2.7 | 0.7 |
| ភាពជាដៃគូ និងសុខដុមនីយកម្ម | 4 | 4 | 3.2 | 0.8 |
| ផែនការ និងការកាត់បន្ថយភាពក្រីក្រ | 7 | 6 | 6.8 | 1.0 |
| ការកែទម្រង់រដ្ឋបាលសាធារណៈ | 3 | 2 | 2.5 | 0.8 |
| ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | 20 | 8 | 13.0 | 0.6 |
| **សរុប** | **77** | **46** | **53.2** | **5.6** |
| គម្រោង/ហិរញ្ញប្បទានមិនស្ថិតក្រោមការសម្របសម្រួលរបស់ក្រុមការងារបច្ចេកទេសចម្រុះ | 363 | 21 | 169.8 | 0.5 |
| **សរុបរួម** | **784** | **162** | **1,205.2** | **27.3** |

តារាងទី ៣.៤ បង្ហាញថា ធនាគារអភិវឌ្ឍន៍អាស៊ី គឺជាដៃគូអភិវឌ្ឍន៍ដែលបានចូលរួមច្រើនជាងគេ ក្នុងក្រុមការងារបច្ចេកទេសចម្រុះ ។ បច្ចុប្បន្ន ធនាគារអភិវឌ្ឍន៍អាស៊ីមានគម្រោងចំនួន ៨១ ដែលសម្របសម្រួលដោយក្រុមការងារបច្ចេកទេសចម្រុះ ។ បន្ទាប់មក គឺជប៉ុន(៥០ គម្រោង) និងអង្គការស្បៀង និងកសិកម្មនៃអង្គការសហប្រជាជាតិ (៣១ គម្រោង) ។ ក្នុងឆ្នាំ២០១៩ ធនាគារអភិវឌ្ឍន៍អាស៊ីបានបើកផ្តល់ហិរញ្ញប្បទាន ២២៥ លានដុល្លារ ដល់បណ្តា

វិស័យដែលគ្រប់គ្រងដោយក្រុមការងារបច្ចេកទេសចម្រុះ ពោលគឺ បានកើនឡើងទ្វេដង ធៀបនឹងឆ្នាំ២០១៨ ។ រីឯជប៉ុនបានបើកផ្តល់ហិរញ្ញប្បទានប្រមាណ ១២០ លានដុល្លារ ក្នុងមួយឆ្នាំ ដល់វិស័យដែលគ្រប់គ្រងដោយក្រុមការងារបច្ចេកទេសចម្រុះ ។

តារាងទី ៣.៤ ដៃគូអភិវឌ្ឍន៍សំខាន់ៗក្នុងក្រុមការងារបច្ចេកទេសចម្រុះ (លានដុល្លារ)

| ដៃគូអភិវឌ្ឍន៍ | ចំនួនគម្រោង | ការបើកផ្តល់តាមឆ្នាំនីមួយៗ | | | | |
|---|---|---|---|---|---|---|
| | | 2017 | 2018 | 2019 (ប៉ាន់ស្មាន) | 2020 (ព្យាករណ៍) | 2021 (ព្យាករណ៍) |
| ADB | 81 | 90.2 | 120.1 | 245.8 | 283.1 | 259.3 |
| Japan | 50 | 74.2 | 118.1 | 126.1 | 232.6 | 232.8 |
| FAO | 31 | 1.1 | 1.4 | 3.3 | 10.5 | 0.1 |
| Germany | 26 | 27.1 | 36.8 | 26.5 | 23.1 | 19.7 |
| EU/EC | 24 | 41.3 | 54.4 | 30.9 | 40.0 | 36.0 |
| Republic of Korea | 21 | 20.1 | 23.8 | 49.9 | 48.2 | 64.2 |
| China | 19 | 290.0 | 267.4 | 397.3 | 357.6 | 220.2 |
| Switzerland | 18 | 15.9 | 14.4 | 14.4 | 9.8 | 8.1 |
| USA | 17 | 23.0 | 31.4 | 15.9 | 9.3 | 8.1 |
| France | 16 | 37.1 | 47.3 | 161.3 | 9.8 | 11.4 |
| Sweden | 16 | 18.9 | 9.9 | 8.2 | 5.3 | 0.8 |
| World Bank | 16 | 13.3 | 22.6 | 69.2 | 84.3 | 101.0 |
| UNDP | 14 | 1.6 | 3.2 | 4.1 | 3.8 | 1.1 |
| UNICEF | 13 | - | - | 43.7 | 36.5 | 33.0 |
| Australia | 12 | 36.3 | 28.6 | 23.6 | 15.8 | 22.3 |
| Others | 46 | 20.9 | 43.2 | 83.9 | 97.0 | 48.2 |
| សរុប | 421 | 710.9 | 822.4 | 1,304.1 | 1,266.8 | 1,066.4 |

## *ការគាំទ្រដល់រាជធានី-ខេត្ត ឆ្នាំ២០១៧-២០១៩*

ផ្នែកនេះបង្ហាញអំពីការឆ្លើយតបរបស់ដៃគូអភិវឌ្ឍន៍ទៅនឹងតម្រូវការក្នុងការលើកកម្ពស់សេដ្ឋកិច្ច, សង្គម, បរិស្ថាន និងប្រជាសាស្ត្ររបស់រាជធានី-ខេត្តនីមួយៗ សម្រាប់ជាមូលដ្ឋានក្នុងការជំរុញដៃគូអភិវឌ្ឍន៍សំខាន់ៗឱ្យពង្រីកកិច្ចប្រតិបត្តិការនៅតាមភូមិសាស្ត្រនីមួយៗ និងផ្តល់ព័ត៌មានដោយផ្អែកលើសក្ដីកម្មជាក់ស្តែង ដើម្បីពង្រឹងភាពជាដៃគូនៅថ្នាក់ក្រោមជាតិ ស្របតាមសេចក្តីណែនាំនៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ដែលពាក់ព័ន្ធនឹងការពង្រឹងយន្តការពិគ្រោះយោបល់ស្តីពីភាពជាដៃគូនៅថ្នាក់ក្រោមជាតិ ។

តារាងទី ៣.៥ បង្ហាញថា ក្នុងចន្លោះឆ្នាំ២០១៧-២០១៩, ២៥% នៃធនធានសរុប បានគាំទ្រដល់ទូទាំងប្រទេស ដូចជាការគាំទ្រដល់រដ្ឋបាលថ្នាក់ជាតិ និងកម្មវិធីកែទម្រង់នានា ។ ចំណែកឯធនធាន ៧៥% ទៀត បានបើកផ្តល់តាមបណ្តារាជធានី-ខេត្ត ។ រាជធានីភ្នំពេញទទួលបានធនធានច្រើនជាងគេ, បន្ទាប់គឺខេត្តបាត់ដំបង, សៀមរាប, កំពង់ចាម, បន្ទាយមានជ័យ និងខេត្តកណ្តាល ។ ខេត្តដទៃទៀតទទួលធនធានតិចជាង ៣% សម្រាប់ខេត្តនីមួយៗ ដោយខេត្តទាំងអស់នេះ ទទួលបានធនធាន ៣៥% នៃហិរញ្ញប្បទានសរុប ។

តារាងទី៣.៥ ការបើកផ្តល់តាមរាជធានី-ខេត្ត ឆ្នាំ២០១៧-២០១៩

| រាជធានីខេត្ត | 2017 | 2018 | 2019 ប៉ាន់ស្មាន | ភាគរយធៀបនឹងការបើកផ្តល់សរុប |
|---|---|---|---|---|
| ទូទាំងប្រទេស | 420 | 414 | 392 | 25% |
| ភ្នំពេញ | 238 | 222 | 369 | 17% |
| បាត់ដំបង | 86 | 102 | 116 | 6% |
| សៀមរាប | 90 | 83 | 108 | 6% |
| កំពង់ចាម | 48 | 87 | 79 | 4% |
| បន្ទាយមានជ័យ | 58 | 49 | 59 | 3% |
| កណ្តាល | 38 | 39 | 76 | 3% |
| ខេត្តផ្សេងទៀត | 545 | 494 | 689 | 35% |
| សរុប | 1,522 | 1,491 | 1,888 | 100% |

តារាងទី ៣.៦ បង្ហាញពីដៃគូអភិវឌ្ឍន៍សំខាន់ៗ ចំនួន ៦ ដែលបានបើកផ្តល់ហិរញ្ញប្បទានដល់ខេត្ត ក្នុងឆ្នាំ ២០១៩ ។ សាធារណរដ្ឋប្រជាមានិតចិនបានបើកផ្តល់ហិរញ្ញប្បទានច្រើនជាងគេ ១៥២,៦ លានដុល្លារ សម្រាប់ រាជធានីភ្នំពេញ, បន្ទាប់គឺបារាំង (៨០ លានដុល្លារ) និងជប៉ុន (៣២ លានដុល្លារ) ។ ជប៉ុនជាដៃគូសំខាន់សម្រាប់ ខេត្តបាត់ដំបង ដោយបានបើកផ្តល់ ៤០ លានដុល្លារ ទន្ទឹមនឹងពេលដែលបារាំងបានបើកផ្តល់ ៣៤ លានដុល្លារ សម្រាប់ខេត្តកណ្តាល ។

តារាងទី ៣.៦ - ការបើកផ្តល់របស់ដៃគូអភិវឌ្ឍន៍សំខាន់ៗតាមរាជធានី-ខេត្ត ឆ្នាំ២០១៩ (លានដុល្លារ)

| ដៃគូអភិវឌ្ឍន៍ | ភ្នំពេញ | បាត់ដំបង | សៀមរាប | កំពង់ចាម | បន្ទាយមានជ័យ | កណ្តាល | សរុប |
|---|---|---|---|---|---|---|---|
| China | 152.6 | 1.8 | 2.1 | 46.5 | 9.7 | 19.5 | 232.2 |
| France | 80.0 | 10.3 | 10.6 | 12.7 | 0.0 | 33.9 | 147.5 |
| Japan | 32.0 | 40.4 | 12.7 | 0.4 | 19.5 | 0.7 | 105.6 |
| ADB | 15.7 | 24.8 | 17.5 | 6.8 | 8.1 | 0.2 | 73.1 |
| Rep. Korea | 11.2 | 12.2 | 0.4 | 1.0 | 5.6 | 5.9 | 36.4 |
| World Bank | 0.5 | 0.9 | 4.8 | 4.7 | 0.1 | 3.5 | 14.5 |
| Germany | 0.7 | 2.1 | 0.1 | - | 5.9 | 0.3 | 9.0 |
| NGOs | 61.8 | 15.8 | 48.0 | 4.9 | 7.9 | 7.4 | 145.8 |
| Others | 14.4 | 7.5 | 12.1 | 1.9 | 2.3 | 4.5 | 42.9 |
| សរុប | 368.9 | 115.8 | 108.3 | 78.9 | 59.1 | 76.0 | 806.9 |

## *ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ជាតិ*

អង្គការមិនមែនរដ្ឋាភិបាលគឺជាតួអង្គអភិវឌ្ឍន៍ ដែលបាន និងកំពុងប្រតិបត្តិការនៅទូទាំងប្រទេស ដោយ បានធ្វើការជាមួយសហគមន៍ ដើម្បីលើកកម្ពស់ជីវភាពរបស់ប្រជាជន ពិសេសគ្រួសារក្រីក្រ និងក្រុមងាយរងគ្រោះ ។ ធនធានសម្រាប់គាំទ្រសកម្មភាពរបស់ពួកគេ មានប្រភពពី ÷ ១) ធនធានដែលអង្គការមិនមែនរដ្ឋាភិបាលបានគៀគរ ដោយផ្ទាល់ (ធនធានផ្ទាល់) និង ២) ធនធានដែលទទួលបានពីដៃគូអភិវឌ្ឍន៍ (ធនធានរបស់ដៃគូអភិវឌ្ឍន៍) ។ ទិន្នន័យស្តីពីធនធានទាំងនេះត្រូវបានកត់ត្រាក្នុងប្រព័ន្ធទិន្នន័យស្តីពីអង្គការមិនមែនរដ្ឋាភិបាល ។

តារាងទី ៣.៧ បង្ហាញថា ក្នុងចន្លោះឆ្នាំ២០១៧-២០១៩ ធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាលមាន ៣៧១ លានដុល្លារ ជាមធ្យមក្នុងមួយឆ្នាំ ។ ក្នុងឆ្នាំ២០១៨ ធនធានរបស់ពួកគេបានកើនឡើងបន្តិច ធៀបនឹងឆ្នាំ២០១៧ ដោយសារកំណើននៃធនធានផ្ទាល់ ។ រីឯធនធានដែលដៃគូអភិវឌ្ឍន៍បានផ្ដល់ឱ្យអង្គការមិនមែនរដ្ឋាភិបាល នៅរក្សាទំហំថេរ ប្រមាណ ១០០ លានដុល្លារ ក្នុងមួយឆ្នាំ សម្រាប់គាំទ្រសកម្មភាពគម្រោងនានារបស់ពួកគេ ។

**តារាងទី ៣.៧ ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ ឆ្នាំ២០១៧-២០១៩ (លានដុល្លារ)**

| វិស័យ | 2017 | | | 2018 | | | 2019 ប៉ាន់ស្មាន | | |
|---|---|---|---|---|---|---|---|---|---|
| | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប |
| សុខាភិបាល | 83.9 | 36.5 | 120.4 | 86.5 | 35.4 | 121.9 | 85.0 | 30.0 | 115.0 |
| អប់រំ | 66.0 | 13.0 | 79.0 | 65.2 | 8.0 | 73.3 | 59.7 | 9.9 | 69.6 |
| សុខុមាលភាពសង្គម | 59.0 | 7.0 | 66.0 | 58.2 | 5.8 | 64.0 | 48.1 | 6.8 | 54.9 |
| អភិវឌ្ឍន៍ជនបទ | 22.2 | 14.5 | 36.7 | 25.8 | 18.9 | 44.7 | 24.9 | 19.1 | 44.0 |
| កសិកម្ម | 11.3 | 9.0 | 20.2 | 13.3 | 8.5 | 21.8 | 10.2 | 7.7 | 18.0 |
| អភិបាលកិច្ច | 3.6 | 15.3 | 18.8 | 3.7 | 16.3 | 20.0 | 3.7 | 12.3 | 15.9 |
| ហ៊ីវ/ អេដស៍ | 5.5 | 10.4 | 15.9 | 6.9 | 6.6 | 13.5 | 7.6 | 7.6 | 15.2 |
| បរិស្ថាន | 6.3 | 5.4 | 11.8 | 10.4 | 2.6 | 13.0 | 7.8 | 4.0 | 11.8 |
| ផ្សេងៗ | 2.1 | 6.9 | 8.9 | 3.1 | 7.2 | 10.3 | 3.3 | 5.5 | 8.8 |
| **សរុប** | **259.8** | **117.9** | **377.7** | **273.1** | **109.3** | **382.4** | **250.3** | **102.8** | **353.1** |

គំនូរទី ៣.៧ បង្ហាញថា ក្នុងចន្លោះឆ្នាំ២០១៧-២០១៩, ៨៥% នៃធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានប្រើប្រាស់ក្នុងវិស័យសុខាភិបាល, អប់រំ, សុខុមាលភាពសហគមន៍, ការអភិវឌ្ឍជនបទ និងកសិកម្ម ។ គំនូរទី ៣.៨ បង្ហាញថា ធនធាន ៣០% នៃធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាល គឺជាធនធានដែលផ្ដល់ដោយដៃគូអភិវឌ្ឍន៍ ហើយការប្រើប្រាស់ធនធាននេះក៏មានការប្រែប្រួលពីវិស័យមួយទៅវិស័យមួយទៀត ។ គួរកត់សម្គាល់ដែរថា វិស័យសុខុមាលភាពសហគមន៍ទទួលបានធនធានត្រឹម ១១% ពីដៃគូអភិវឌ្ឍន៍ ធៀបនឹងធនធានសរុបសម្រាប់វិស័យនេះ ទន្ទឹមនឹងពេលដែលវិស័យអភិបាលកិច្ចទទួលបានធនធានពីដៃគូអភិវឌ្ឍន៍ រហូតដល់ ៨០% ធៀបនឹងធនធានសរុបសម្រាប់វិស័យនេះ ។

គំនូសទី៣.៧ ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាល តាមវិស័យ ឆ្នាំ២០១៧-២០១៩




គំនូស ៣.៨ ភាគរយនៃធនធានរបស់អង្គការមិន មែនរាជរដ្ឋាភិបាល ឆ្នាំ២០១៧-២០១៩




តារាងទី ៣.៨ បង្ហាញថា ក្នុងឆ្នាំ២០១៨ អង្គការមិនមែនរដ្ឋាភិបាលចំនួន ៣៩១ បានផ្តល់របាយការណ៍ស្តីពីសកម្មភាពរបស់ខ្លួនមក គ.ជ.ន/ក.អ.ក ។ ក្នុងឆ្នាំ២០១៨ អង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗចំនួន ២៨ បានប្រើប្រាស់ធនធាន ២០៥ លានដុល្លារ ពោលគឺស្មើនឹង ៥៤% នៃធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាល ។ ក្នុងចន្លោះឆ្នាំ២០១៧-២០១៩, មូលនិធិគន្ធបុប្ផានៅតែជាអង្គការមិនមែនរដ្ឋាភិបាលឈានមុខគេ ក្នុងការរួមចំណែកផ្តល់សេវាថែទាំសុខភាព ដោយបានប្រើប្រាស់ធនធានជាមធ្យម ប្រមាណ ៣២,៥ លានដុល្លារ ក្នុងមួយឆ្នាំ ស្មើនឹង ៩% នៃធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាល ។

តារាងទី ៣.៨ ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ ឆ្នាំ២០១៧-២០១៩ (លានដុល្លារ)

| ឈ្មោះអង្គការ មិនមែនរដ្ឋាភិបាល | 2017 | | | 2018 | | | 2019 ប៉ាន់ស្មាន | | |
|---|---|---|---|---|---|---|---|---|---|
| | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប |
| Foundation Children's Hospital Kantha Bopha Dr. Beat Richner | 26.9 | 4.3 | 31.2 | 24.7 | 4.6 | 29.3 | 32.7 | 4.3 | 37.0 |
| World Vision Cambodia | 24.1 | 2.7 | 26.8 | 22.6 | 3.0 | 25.6 | 22.6 | 3.3 | 25.9 |
| Save the Children International | 3.0 | 7.6 | 10.6 | 2.9 | 7.6 | 10.5 | 2.3 | 6.0 | 8.3 |
| Population Services International | 7.8 | 2.1 | 9.9 | 8.0 | 2.2 | 10.2 | 10.0 | 5.7 | 15.8 |
| University Research Co., LLC | 0.0 | 7.9 | 7.9 | 0.0 | 9.0 | 9.0 | 0.0 | 3.2 | 3.2 |
| Plan International | 3.6 | 10.5 | 14.2 | 4.0 | 4.4 | 8.4 | 3.6 | 7.4 | 11.0 |
| Cambodian Children's Fund | 7.1 | 0.0 | 7.1 | 7.8 | 0.0 | 7.8 | 7.3 | 0.0 | 7.3 |
| Pour un Sourire d'Enfant | 7.1 | 0.0 | 7.1 | 6.6 | 0.0 | 6.6 | 7.0 | 0.0 | 7.0 |
| Sos Children's Villages of Cambodia | 4.7 | 0.0 | 4.7 | 6.4 | 0.0 | 6.4 | 4.1 | 0.0 | 4.1 |
| Reproductive Health Association of Cambodia | 3.4 | 0.3 | 3.7 | 5.4 | 0.9 | 6.3 | 0.7 | 1.2 | 1.9 |
| Family Health International | 0.0 | 0.0 | 0.0 | 0.0 | 6.1 | 6.1 | 0.0 | 6.3 | 6.3 |
| Japan Relief for Cambodia and World Assistance for Cambodia | 5.4 | 0.3 | 5.7 | 5.4 | 0.7 | 6.1 | 4.5 | 0.1 | 4.6 |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| Hope Worldwide | 6.1 | 0.0 | 6.1 | 5.9 | 0.0 | 5.9 | 4.2 | 0.0 | 4.2 |
| Angkor Hospital for Children | 5.5 | 0.0 | 5.5 | 5.8 | 0.0 | 5.8 | 6.7 | 0.1 | 6.8 |
| Norwegian People's Aid | 1.3 | 3.6 | 4.9 | 1.4 | 3.9 | 5.3 | 2.9 | 2.2 | 5.1 |
| Hazardous Area Life Support Organisation Trust | 0.1 | 4.5 | 4.6 | 0.1 | 5.1 | 5.2 | 0.1 | 6.0 | 6.2 |
| World Wide Fund for Nature Cambodia | 0.7 | 0.8 | 1.5 | 3.1 | 2.0 | 5.1 | 3.0 | 2.8 | 5.8 |
| Medecins Sans Frontieres - France | 2.8 | 0.0 | 2.8 | 4.9 | 0.0 | 4.9 | 3.5 | 0.0 | 3.5 |
| International Development Enterprises Cambodia | 2.2 | 2.0 | 4.2 | 1.5 | 3.2 | 4.7 | 0.0 | 4.6 | 4.6 |
| Child Fund Cambodia | 4.1 | 0.3 | 4.4 | 4.2 | 0.5 | 4.7 | 0.0 | 0.0 | 0.0 |
| CARE International in Cambodia | 1.1 | 3.1 | 4.2 | 1.3 | 3.1 | 4.4 | 1.4 | 1.5 | 2.9 |
| Don Bosco Foundation of Cambodia | 3.5 | 0.2 | 3.7 | 4.4 | 0.0 | 4.4 | 4.4 | 0.0 | 4.4 |
| SNV Netherlands Development Organization | 0.6 | 4.1 | 4.7 | 0.2 | 4.1 | 4.3 | 0.2 | 3.6 | 3.9 |
| Mines Advisory Group | 1.3 | 1.2 | 2.5 | 1.6 | 2.3 | 4.0 | 1.9 | 2.4 | 4.3 |
| Jay Pritzker Academy | 3.7 | 0.0 | 3.7 | 3.9 | 0.0 | 3.9 | 3.9 | 0.0 | 3.9 |
| Heifer International Cambodia | 1.7 | 0.0 | 1.7 | 3.8 | 0.0 | 3.8 | 0.5 | 0.0 | 0.5 |
| Room to Read | 2.9 | 0.0 | 2.9 | 3.4 | 0.0 | 3.4 | 3.6 | 0.0 | 3.6 |
| DanChurchAid | 0.5 | 1.5 | 2.1 | 0.7 | 2.4 | 3.2 | 0.7 | 1.4 | 2.2 |
| **NGOs សំខាន់ៗទាំង ២៨** | **131.2** | **56.9** | **188.2** | **140.0** | **65.1** | **205.1** | **132.1** | **62.1** | **194.1** |
| **NGOs ៣៦៣ ផ្សេងទៀត** | **128.6** | **60.9** | **189.5** | **133.1** | **44.3** | **177.3** | **118.2** | **40.7** | **159.0** |
| **សរុប** | **259.8** | **117.9** | **377.7** | **273.1** | **109.3** | **382.4** | **250.3** | **102.8** | **353.1** |

# ជំពូកទី ៤
# ស្ថានភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ក្នុងអន្តរវិស័យ

កិច្ចប្រឹងប្រែងក្នុងការដឹកនាំកិច្ចអភិវឌ្ឍន៍តម្រូវឱ្យមានកិច្ចសហការអន្តរវិស័យ ។ លើមូលដ្ឋាននេះ ក.អ.ក/គ.ជ.នា បានកែសម្រួលប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ដើម្បីកត់ត្រាធនធានរបស់ដៃគូអភិវឌ្ឍន៍ដែលបានគាំទ្រអន្តរវិស័យ ។ ចាប់ពីឆ្នាំ២០១៥ វិស័យសម្គាល់បន្ថែមត្រូវបានប្រើប្រាស់សម្រាប់កត់ត្រាការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍បន្ថែមក្រៅពីការគាំទ្រដល់វិស័យគោល ។

**តារាងទី ៤.១ វិស័យសម្គាល់បន្ថែម**

| | | | |
|---|---|---|---|
| ១ | ការអភិវឌ្ឍ និងការពង្រឹងសមត្ថភាព និងប្រព័ន្ធរបស់រាជរដ្ឋាភិបាល | ១០ | គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា |
| ២ | ការគាំទ្រការអនុវត្តការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ១១ | ការបង្កើតប្រាក់ចំណូល និងការងារ |
| ៣ | ការគាំទ្រការអនុវត្តការកែទម្រង់ការគ្រប់គ្រងរដ្ឋបាលសាធារណៈ | ១២ | ការអភិវឌ្ឍវិស័យឯកជន |
| ៤ | ការគាំទ្រដល់ការអនុវត្តការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ | ១៣ | កិច្ចសហប្រតិបត្តិការត្បូង-ត្បូង និងកិច្ចសហប្រតិបត្តិការត្រីកោណ |
| ៥ | ការគាំទ្រដល់ការអនុវត្តការកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ | ១៤ | គម្រោងអភិវឌ្ឍន៍សហគមន៍ |
| ៦ | សមភាពយេនឌ័រ និងការផ្តល់សិទ្ធិអំណាចដល់ស្ត្រី | ១៥ | ការចូលរួមជាមួយសង្គមស៊ីវិល ឬ តួអង្គមិនមែនរដ្ឋ |
| ៧ | ការការពារបរិស្ថាន (មិនរាប់បញ្ចូលការប្រែប្រួលអាកាសធាតុ) | ១៦ | សន្តិសុខស្បៀង |
| ៨ | ការប្រែប្រួលអាកាសធាតុ | ១៧ | ការគាំពារសង្គម |
| ៩ | ហ៊ីវ/អេដស៍ (ការយល់ដឹង, ការការពារ និងព្យាបាល) | ១៨ | ការគាំទ្រ និងការអភិវឌ្ឍយុវជន |

វិស័យសម្គាល់បន្ថែមទាំង ១៨ ក្នុងប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ត្រូវបានរៀបចំឡើង ដើម្បីឱ្យដៃគូអភិវឌ្ឍន៍ផ្តល់ព័ត៌មានស្តីពីការគាំទ្ររបស់ខ្លួន ក្រៅពីវិស័យគោល (តារាងទី៤.១) ។ ជំពូកនេះវិភាគអំពីទំហំធនធានដែលគាំទ្រវិស័យសម្គាល់បន្ថែម ៣ គឺ÷ សមភាពយេនឌ័រ, ការអភិវឌ្ឍវិស័យឯកជន និងការប្រែប្រួលអាកាសធាតុ ។

### *ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់លើកកម្ពស់សមភាពយេនឌ័រ*

សមភាពយេនឌ័រ គឺជាវិស័យសំខាន់សម្រាប់ជំរុញកិច្ចអភិវឌ្ឍន៍ និងជាវិស័យអាទិភាពនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល ។ សមភាពយេនឌ័រទទួលបានការគាំទ្រច្រើន ពិសេសការបង្កើនភាពអង់អាចរបស់ស្ត្រី ។ ក្នុងឆ្នាំ២០១៩ ហិរញ្ញប្បទានសហប្រតិបត្តិការ (រួមបញ្ចូលទាំងធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល) ទំហំ ៥,២ លានដុល្លារ ស្មើនឹង 0,២៨% នៃហិរញ្ញប្បទានសហប្រតិបត្តិការសរុប បានគាំទ្រវិស័យគោលយេនឌ័រ ។

ពិនិត្យក្នុងទិដ្ឋភាពនៃការសម្របសម្រួល, គន្លឹះក្នុងការលើកកម្ពស់សមភាពយេនឌ័រ គឺកិច្ចសហការជាមួយដៃគូដែលបានបញ្ជ្រាបសមភាពយេនឌ័រ ទៅក្នុងគម្រោងរបស់ខ្លួន ។ តារាងទី ៤.២ បង្ហាញថា ក្នុងឆ្នាំ២០១៩ ធនធានទំហំ ៨២,៧ លានដុល្លារ ត្រូវបានប្រើប្រាស់សម្រាប់ចូលរួមក្នុងការលើកកម្ពស់សមភាពយេនឌ័រ ពោលគឺបានកើន ៣២% ធៀបនឹងឆ្នាំ ២០១៨ ដោយសារមានការកើនឡើងនូវធនធានសម្រាប់បញ្ជ្រាបយេនឌ័រក្នុងវិស័យអប់រំ និងនគរូបនីយកម្ម និងការគ្រប់គ្រង ប្រមាណ ៦ លានដុល្លារ សម្រាប់វិស័យនីមួយៗ ។

តារាងទី ៤.២ : ការបញ្ជ្រាបសមភាពយេនឌ័រតាមវិស័យ ឆ្នាំ២០១៨-២០១៩ (លានដុល្លារ)

| វិស័យ | ២០១៨ (សរុប) | ២០១៩ | | | | ធនធានតាមវិស័យ ឆ្នាំ២០១៩ | យេនឌ័រ(% នៃធនធានតាមវិស័យ) |
|---|---|---|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| នគរូបនីយកម្ម និងការគ្រប់គ្រង | 1.11 | 3.10 | 4.00 | - | 7.10 | 55.85 | 13% |
| អភិបាលកិច្ច និងរដ្ឋបាល | 8.49 | 3.02 | 3.54 | 1.12 | 7.68 | 64.67 | 12% |
| ការអភិវឌ្ឍជនបទ | 6.51 | 1.56 | 6.03 | - | 7.58 | 94.69 | 8% |
| អប់រំ | 10.76 | 2.15 | 9.02 | 5.55 | 16.73 | 213.79 | 8% |
| ទេសចរណ៍ | 0.14 | - | 0.56 | - | 0.56 | 7.13 | 8% |
| ការប្រែប្រួលអាកាសធាតុ | 0.85 | 0.73 | 0.14 | 0.08 | 0.95 | 13.33 | 7% |
| ទឹកស្អាត និងអនាម័យ | 5.76 | 0.88 | 6.25 | - | 7.12 | 151.40 | 5% |
| កសិកម្ម | 8.22 | 1.74 | 8.05 | 4.34 | 14.13 | 309.24 | 5% |
| បច្ចេកវិទ្យា ព័ត៌មានវិទ្យា និងទំនាក់ទំនង | 0.05 | 0.01 | 0.04 | - | 0.05 | 1.12 | 4% |
| សេវាធុរកិច្ច និងហិរញ្ញវត្ថុ | 0.18 | 0.09 | 0.03 | 0.00 | 0.11 | 2.79 | 4% |
| សុខាភិបាល | 8.64 | 3.27 | 4.73 | 0.95 | 8.95 | 244.22 | 4% |
| ឧស្សាហកម្ម និងពាណិជ្ជកម្ម | 0.31 | 0.08 | 0.14 | 0.09 | 0.32 | 10.13 | 3% |
| ការដឹកជញ្ជូន | 5.00 | 0.22 | 7.62 | - | 7.84 | 348.16 | 2% |
| សហគមន៍ និងសុខុមាលភាពសង្គម | 1.19 | 0.32 | 1.01 | 0.01 | 1.34 | 61.80 | 2% |
| បរិស្ថាន និងចីរភាព | 0.97 | 0.23 | 0.30 | - | 0.53 | 36.06 | 1% |
| ថាមពល និងអគ្គិសនី | 2.89 | 0.70 | 0.36 | - | 1.06 | 175.45 | 1% |
| វប្បធម៌ សិល្បៈ និងកីឡា | 0.15 | 0.12 | 0.02 | - | 0.14 | 63.80 | 0% |
| ហ៊ីវ/អេដស៍ | 0.86 | - | 0.02 | - | 0.02 | 11.72 | 0% |
| ជំនួយសង្គ្រោះបន្ទាន់ និងស្បៀងអាហារ | 0.02 | - | 0.00 | - | 0.00 | 3.24 | 0% |
| ផ្សេងៗ | 0.30 | 0.42 | 0.01 | 0.00 | 0.43 | 19.38 | 2% |
| **សរុប** | **62.40** | **18.62** | **51.88** | **12.15** | **82.65** | **1887.95** | **4%** |

តារាងទី ៤.៣ បង្ហាញថា ដៃគូអភិវឌ្ឍន៍ចំនួន ២៩ បានបញ្ជ្រាបសមភាពយេនឌ័រទៅក្នុងគម្រោងរបស់ខ្លួន ។ ក្នុងនោះ ដៃគូអភិវឌ្ឍន៍នីមួយៗបានប្រើប្រាស់ធនធានតិចជាង ១/៣ នៃហិរញ្ញប្បទានបើកផ្តល់របស់ខ្លួន សម្រាប់បញ្ជ្រាបយេនឌ័រ លើកលែងនូវែលសេឡង់ដែលបានចំណាយធនធានរហូត ដល់ ៣៧% ។ នេះបង្ហាញពីសក្តានុពលក្នុងការលើកកម្ពស់សមភាពយេនឌ័រ តាមរយៈការយកចិត្តទុកដាក់របស់ដៃគូអភិវឌ្ឍន៍ក្នុងការបញ្ជ្រាបកិច្ចការនេះក្នុងគម្រោងរបស់ខ្លួន ។

**តារាងទី ៤.៣ : ការបញ្ជ្រាបសមភាពយេនឌ័ររបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៨-២០១៩ (លានដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | ២០១៨ (សរុប) | ២០១៩ | | | | ធនធានរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៩ | យេនឌ័រ (% នៃ ធនធានរបស់ដៃគូ អភិវឌ្ឍន៍) |
|---|---|---|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| New Zealand | 2.26 | 0.12 | 0.47 | 2.07 | 2.66 | 7.17 | 37% |
| UNESCO | 0.40 | 1.48 | 0.01 | 0.06 | 1.54 | 5.46 | 28% |
| UNCOHCHR | 0.02 | 0.02 | - | - | 0.02 | 0.06 | 25% |
| Ireland | 0.16 | 0.10 | 0.06 | - | 0.16 | 0.76 | 21% |
| UK | 0.14 | 0.15 | 0.02 | 0.01 | 0.18 | 0.93 | 19% |
| World Bank | 4.15 | 0.55 | 12.56 | - | 13.11 | 69.74 | 19% |
| Sweden | 4.21 | 1.75 | 1.18 | 0.92 | 3.85 | 23.76 | 16% |
| Canada | 0.25 | 0.06 | 0.21 | 0.03 | 0.30 | 1.99 | 15% |
| Switzerland | 1.70 | 0.02 | 1.72 | - | 1.74 | 13.41 | 13% |
| Australia | 6.82 | 2.13 | 1.58 | 1.25 | 4.96 | 38.80 | 13% |
| ADB | 15.75 | 5.10 | 23.42 | 0.05 | 28.56 | 245.99 | 12% |
| Czech Republic | 0.06 | 0.06 | 0.17 | - | 0.23 | 1.99 | 11% |
| ILO | 0.43 | - | 0.34 | 0.06 | 0.40 | 3.88 | 10% |
| UN Women | 0.05 | - | - | 0.08 | 0.08 | 0.85 | 10% |
| Germany | 3.37 | 0.66 | 1.62 | 0.09 | 2.37 | 24.87 | 10% |
| WFP | 1.13 | - | 0.76 | - | 0.76 | 8.33 | 9% |
| UNAIDS | 0.01 | - | 0.02 | - | 0.02 | 0.21 | 9% |
| UNDP | 0.94 | 0.33 | 0.58 | - | 0.91 | 10.33 | 9% |
| UNFPA | 0.24 | - | 0.18 | 0.03 | 0.21 | 2.43 | 9% |
| EU/EC | 6.00 | 0.96 | 1.37 | 3.07 | 5.41 | 64.63 | 8% |
| FAO | 0.17 | 0.03 | 0.27 | 0.00 | 0.29 | 3.55 | 8% |
| USA | 6.33 | 2.50 | 2.30 | 0.13 | 4.93 | 59.63 | 8% |
| WHO | 0.12 | 0.11 | - | - | 0.11 | 1.65 | 7% |
| UNICEF | 0.51 | 0.21 | 0.70 | - | 0.91 | 15.80 | 6% |
| France | 3.44 | - | 0.96 | 4.31 | 5.28 | 207.80 | 3% |
| GAVI | 0.92 | 1.01 | - | - | 1.01 | 40.85 | 2% |
| IFAD | 0.22 | 0.30 | - | - | 0.30 | 12.40 | 2% |
| Republic of Korea | 1.21 | 0.07 | 1.20 | - | 1.27 | 71.32 | 2% |
| Japan | 0.75 | 0.92 | 0.18 | - | 1.11 | 192.73 | 1% |
| Others | 0.63 | - | - | - | - | 756.66 | 0% |
| **សរុប** | **62.40** | **18.62** | **51.88** | **12.15** | **82.65** | **1887.95** | **4%** |

### *ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការអភិវឌ្ឍវិស័យឯកជន*

រាជរដ្ឋាភិបាលបានលើកកម្ពស់បរិយាកាសសម្រាប់ទាក់ទាញការវិនិយោគ តាមរយៈការដាក់ឱ្យអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ។ ក្នុងឆ្នាំ២០១៩ ធនធាន ២០៩ លានដុល្លារ បានគាំទ្រការអភិវឌ្ឍវិស័យឯកជន ពោលគឺបានកើន ៤៨% ធៀបនឹងឆ្នាំ២០១៨ ។ វិស័យថាមពល និងវិស័យដឹកជញ្ជូនទទួលបានធនធានច្រើនជាងគេ ដោយសារសាធារណរដ្ឋប្រជាមានិតចិនបានផ្តល់ហិរញ្ញប្បទានសម្រាប់តភ្ជាប់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងអភិវឌ្ឍវិស័យថាមពល ។ តារាងទី ៤.៤ បង្ហាញថាវិស័យដែលបានបញ្ជ្រាបការអភិវឌ្ឍវិស័យឯកជន គឺ÷ វិស័យឧស្សាហកម្ម និងពាណិជ្ជកម្ម, វិស័យនគរូបនីយកម្ម និងការគ្រប់គ្រង និងវិស័យទេសចរណ៍ ។

តារាងទី ៤.៤: ការបញ្ជាបការអភិវឌ្ឍវិស័យឯកជនតាមវិស័យ ឆ្នាំ២០១៨-២០១៩ (លានដុល្លារ)

| វិស័យ | ២០១៨ (សរុប) | ២០១៩ | | | | ធនធានតាមវិស័យ ឆ្នាំ២០១៩ | វិស័យឯកជន (% នៃធនធានតាមវិស័យ) |
|---|---|---|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| ថាមពល និងអគ្គិសនី | 23.61 | 0.00 | 50.69 | 0.95 | 51.64 | 175.45 | 29% |
| ដឹកជញ្ជូន | 82.12 | 0.22 | 96.27 | - | 96.49 | 348.16 | 28% |
| ឧស្សាហកម្ម និងពាណិជ្ជកម្ម | 0.81 | - | 0.60 | 0.88 | 1.48 | 10.13 | 15% |
| នគរូបនីយកម្ម និងការគ្រប់គ្រង | 0.96 | 5.03 | 1.63 | - | 6.66 | 55.85 | 12% |
| ទេសចរណ៍ | 0.24 | 0.01 | 0.65 | 0.04 | 0.70 | 7.13 | 10% |
| ការអភិវឌ្ឍជនបទ | 5.74 | 0.75 | 7.62 | 0.30 | 8.67 | 94.69 | 9% |
| ទឹកស្អាត និងអនាម័យ | 5.78 | 0.20 | 2.90 | 9.52 | 12.62 | 151.40 | 8% |
| កសិកម្ម | 12.45 | 5.58 | 14.18 | 1.62 | 21.38 | 309.24 | 7% |
| បច្ចេកវិទ្យា ព័ត៌មានវិទ្យា និងទំនាក់ទំនង | 0.00 | 0.02 | 0.04 | - | 0.05 | 1.12 | 5% |
| សេវាធុរកិច្ច និងហិរញ្ញវត្ថុ | 0.73 | 0.01 | 0.01 | 0.09 | 0.12 | 2.79 | 4% |
| យេនឌ័រ | 0.03 | 0.09 | 0.02 | - | 0.11 | 5.25 | 2% |
| បរិស្ថាន និងចីរភាព | 1.03 | 0.32 | 0.14 | 0.21 | 0.67 | 36.06 | 2% |
| សហគមន៍ និងសុខុមាលភាពសង្គម | 0.85 | 0.24 | 0.53 | 0.34 | 1.11 | 61.80 | 2% |
| អប់រំ | 2.99 | 0.11 | 2.69 | 0.40 | 3.19 | 213.79 | 1% |
| វប្បធម៌ សិល្បៈ និងកីឡា | 0.88 | 0.19 | 0.74 | - | 0.93 | 63.80 | 1% |
| អភិបាលកិច្ច និងរដ្ឋបាល | 0.89 | 0.35 | 0.54 | 0.03 | 0.92 | 64.67 | 1% |
| ការប្រែប្រួលអាកាសធាតុ | 0.11 | 0.10 | 0.00 | - | 0.10 | 13.33 | 1% |
| សុខាភិបាល | 2.04 | 0.72 | 0.22 | - | 0.94 | 244.22 | 0% |
| ជំនួយសង្គ្រោះបន្ទាន់ និងស្បៀងអាហារ | - | - | 0.00 | - | 0.00 | 3.24 | 0% |
| ហ៊ីវ/អេដស៍ | - | - | - | - | - | 11.72 | 0% |
| ផ្សេងៗ | 0.19 | 1.37 | - | - | 1.37 | 14.13 | 10% |
| សរុប | 141.45 | 15.30 | 179.46 | 14.38 | 209.15 | 1887.95 | 11% |

តារាងទី ៤.៥ បង្ហាញថា សាធារណរដ្ឋប្រជាមានិតចិន, ជប៉ុន, មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម, បារាំង និងអង្គការពលកម្មអន្តរជាតិ គឺជាដៃគូដែលបានបញ្ជាបការអភិវឌ្ឍវិស័យឯកជនច្រើនជាងគេទៅក្នុងគម្រោងរបស់ខ្លួន ។ ទោះបីជាដៃគូទាំង ២៥ បានគាំទ្រការអភិវឌ្ឍវិស័យឯកជនក៏ដោយ ក៏ការគាំទ្រទាំងនេះមានធនធានតិចជាង ១/៤ នៃហិរញ្ញប្បទានបើកផ្តល់សរុបរបស់ខ្លួន ។

តារាងទី ៤.៥ : ការបញ្រ្ជាបការអភិវឌ្ឍវិស័យឯកជនរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៨-២០១៩ (លានដុល្លារ)

| ដៃគូអភិវឌ្ឍន៍ | ២០១៨ (សរុប) | ២០១៩ | | | | ធនធានរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៩ | វិស័យឯកជន (% នៃធនធានរបស់ដៃគូអភិវឌ្ឍន៍) |
|---|---|---|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| China | 76.53 | - | 117.08 | - | 117.08 | 496.18 | 24% |
| Japan | 23.51 | 1.54 | 24.80 | 0.25 | 26.60 | 192.73 | 14% |
| IFAD | 1.02 | - | 1.22 | 0.30 | 1.52 | 12.40 | 12% |
| France | 10.11 | 4.69 | 10.72 | 9.50 | 24.92 | 207.80 | 12% |
| ILO | 0.38 | - | 0.06 | 0.34 | 0.40 | 3.88 | 10% |
| UK | 0.08 | 0.06 | 0.03 | - | 0.09 | 0.93 | 10% |
| WFP | - | - | 0.76 | - | 0.76 | 8.33 | 9% |
| Republic of Korea | 1.89 | 0.07 | 5.69 | 0.44 | 6.20 | 71.32 | 9% |
| ADB | 13.67 | 5.36 | 14.56 | - | 19.92 | 245.99 | 8% |
| Australia | 4.44 | 0.33 | 0.70 | 2.05 | 3.07 | 38.80 | 8% |
| New Zealand | 0.42 | - | 0.39 | 0.16 | 0.55 | 7.17 | 8% |
| WHO | 0.12 | 0.11 | - | - | 0.11 | 1.65 | 7% |
| Germany | 2.74 | 1.18 | 0.15 | 0.26 | 1.58 | 24.87 | 6% |
| UNIDO | 0.01 | - | - | 0.10 | 0.10 | 1.62 | 6% |
| Czech Republic | 0.08 | 0.07 | 0.04 | - | 0.11 | 1.99 | 6% |
| UNICEF | 0.98 | 0.17 | 0.70 | - | 0.87 | 15.80 | 5% |
| Switzerland | 0.56 | 0.11 | 0.53 | - | 0.64 | 13.41 | 5% |
| EU/EC | 1.64 | 0.99 | 0.58 | 0.69 | 2.27 | 64.63 | 4% |
| Canada | 0.09 | - | - | 0.06 | 0.06 | 1.99 | 3% |
| UNESCO | 0.05 | 0.10 | 0.06 | - | 0.16 | 5.46 | 3% |
| UNDP | 0.28 | 0.18 | 0.03 | 0.07 | 0.28 | 10.33 | 3% |
| USA | 2.33 | 0.15 | 1.02 | 0.17 | 1.33 | 59.63 | 2% |
| Sweden | 0.52 | 0.16 | 0.26 | - | 0.42 | 23.76 | 2% |
| UNFPA | - | 0.02 | - | - | 0.02 | 2.43 | 1% |
| World Bank | - | - | 0.07 | - | 0.07 | 69.74 | 0% |
| Others | - | - | - | - | - | 305.14 | 0% |
| **សរុប** | **141.45** | **15.30** | **179.46** | **14.38** | **209.15** | **1887.95** | **11%** |

## *ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រការប្រែប្រួលអាកាសធាតុ*

តាមរយៈការអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពបានបញ្រ្ជាបវិធានការបន្ស៊ាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុទៅក្នុងផែនការអភិវឌ្ឍន៍តាមវិស័យ និងផែនការអភិវឌ្ឍន៍ថ្នាក់ក្រោមជាតិ ក្នុងគោលដៅកាត់បន្ថយផលប៉ះពាល់អវិជ្ជមាននៃការប្រែប្រួលអាកាសធាតុ ដើម្បីធានាដំណើរការនៃការអភិវឌ្ឍជាតិប្រកបដោយចីរភាព ។

ធនធាន ១១,៦ លានដុល្លារ ក្នុងឆ្នាំ២០១៨ និង ១៣,៣ លានដុល្លារ ក្នុងឆ្នាំ ២០១៩ គិតទាំងធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល បានគាំទ្រការប្រែប្រួលអាកាសធាតុ (វិស័យគោល) ។ គម្រោងក្នុងវិស័យដទៃទៀតដែលបានបញ្រ្ជាបការប្រែប្រួលអាកាសធាតុ មានទំហំ ៧៩ លានដុល្លារ ក្នុងឆ្នាំ ២០១៩ ពោលគឺបានកើនឡើងប្រមាណ ២២ លានដុល្លារ ស្មើនឹង ៣៩% ធៀបនឹងឆ្នាំ២០១៨ ។ តារាងទី ៤.៦ បង្ហាញថា ក្នុងឆ្នាំ២០១៩ វិស័យនគរូបនីយកម្ម និងការគ្រប់គ្រង ទទួលបានធនធានច្រើនជាងគេ សម្រាប់បញ្រ្ជាបការប្រែប្រួលអាកាសធាតុ ស្មើនឹង ១៩% នៃហិរញ្ញប្បទានបើកផ្តល់សម្រាប់វិស័យនេះ ។ បន្ទាប់មកគឺវិស័យបរិស្ថាន និងចីរភាព ១៣%, វិស័យកសិកម្ម

១២%, ការអភិវឌ្ឍជនបទ ៨% និងវិស័យទឹកស្អាត និងអនាម័យ ៣% ។ ដោយឡែក វិស័យសំខាន់ៗដែលពាក់ព័ន្ធនឹងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ដូចជាសុខាភិបាល, ថាមពល និងអគ្គិសនី ទទួលធនធានតិចតួចនៅឡើយសម្រាប់បញ្ជ្រាបការប្រែប្រួលអាកាសធាតុ ។ លើមូលដ្ឋាននេះ យើងត្រូវប្រើប្រាស់ឱ្យអស់សក្តានុពលដើម្បីបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍ ។

**តារាងទី ៤.៦ : ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុតាមវិស័យ ឆ្នាំ២០១៨-២០១៩ (លានដុល្លារ)**

| វិស័យ | ២០១៨ | ២០១៩ | | | | ធនធានតាមវិស័យ | ការប្រែប្រួល អាកាសធាតុ (% នៃធនធានតាមវិស័យ) |
|---|---|---|---|---|---|---|---|
| | សរុប | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | ឆ្នាំ២០១៩ | |
| នគរូបនីយកម្ម និងការគ្រប់គ្រង | 1.13 | 3.59 | 6.74 | 0.34 | 10.67 | 55.85 | 19% |
| បរិស្ថាន និងចីរភាព | 5.64 | 0.69 | 1.35 | 2.64 | 4.68 | 36.06 | 13% |
| កសិកម្ម | 27.01 | 4.70 | 25.91 | 6.42 | 37.03 | 309.24 | 12% |
| ការអភិវឌ្ឍជនបទ | 4.01 | 0.09 | 0.97 | 6.31 | 7.36 | 94.69 | 8% |
| ទឹកស្អាត និងអនាម័យ | 3.52 | 0.07 | 5.13 | 0.08 | 5.29 | 151.40 | 3% |
| ការដឹកជញ្ជូន | 7.13 | 1.64 | 7.62 | 0.08 | 9.34 | 348.16 | 3% |
| យេនឌ័រ | 0.14 | 0.09 | - | - | 0.09 | 5.25 | 2% |
| សុខាភិបាល | 3.08 | 1.23 | 1.44 | - | 2.67 | 244.22 | 1% |
| សេវាធុរកិច្ច និងហិរញ្ញវត្ថុ | 0.52 | - | 0.03 | - | 0.03 | 2.79 | 1% |
| អភិបាលកិច្ច និងរដ្ឋបាល | 0.48 | 0.02 | 0.03 | 0.24 | 0.29 | 64.67 | 0% |
| អប់រំ | 1.89 | 0.66 | 0.25 | - | 0.92 | 213.79 | 0% |
| សហគមន៍ និងសុខុមាលភាពសង្គម | 0.06 | 0.02 | 0.02 | 0.18 | 0.23 | 61.80 | 0% |
| ថាមពល និងអគ្គិសនី | 1.95 | - | 0.48 | - | 0.48 | 175.45 | 0% |
| វប្បធម៌ សិល្បៈ និងកីឡា | 0.03 | - | 0.02 | - | 0.02 | 63.80 | 0% |
| ទេសចរណ៍ | - | - | - | - | - | 7.13 | 0% |
| ផ្សេងៗ | 0.30 | - | - | - | - | 27.46 | 0% |
| ហ៊ីវ/អេដស៍ | - | - | - | - | - | 11.72 | 0% |
| ឧស្សាហកម្ម និងពាណិជ្ជកម្ម | - | - | - | - | - | 10.13 | 0% |
| ជំនួយសង្គ្រោះបន្ទាន់ និងស្បៀងអាហារ | 0.01 | - | - | - | - | 3.24 | 0% |
| បច្ចេកវិទ្យា ព័ត៌មានវិទ្យា និងទំនាក់ទំនង | 0.05 | - | - | - | - | 1.12 | 0% |
| **សរុប** | **56.95** | **12.80** | **50.01** | **16.28** | **79.09** | **1887.95** | **4%** |

ដៃគូអភិវឌ្ឍន៍ចំនួន ២២ បានបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគម្រោងអភិវឌ្ឍន៍របស់ខ្លួន ប៉ុន្តែ បានបញ្ជ្រាបតិចជាង ២០% នៃការបើកផ្តល់ហិរញ្ញប្បទានសរុប ក្នុង២០១៩ ប៉ុណ្ណោះ ។ តារាងទី ៤.៧ បង្ហាញថា ដៃគូដែលបានបញ្ជ្រាបការប្រែប្រួលអាកាសធាតុច្រើនជាងគេ គឺធនាគារពិភពលោក ១៧%, ធនាគារអភិវឌ្ឍន៍អាស៊ី ១១% និងមូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម ១០% ។

**តារាងទី ៤.៧ : ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៨-២០១៩ (លានដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | ២០១៨ | ២០១៩ | | | | ធនធានរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៩ | ការប្រែប្រួលអាកាសធាតុ (% នៃធនធានរបស់ដៃគូអភិវឌ្ឍន៍) |
|---|---|---|---|---|---|---|---|
| | សរុប | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| World Bank | 4.00 | 0.21 | 7.17 | 4.73 | 12.11 | 69.74 | 17% |
| ADB | 14.89 | 0.18 | 21.42 | 4.50 | 26.10 | 245.99 | 11% |
| IFAD | 0.89 | - | - | 1.22 | 1.22 | 12.40 | 10% |
| FAO | 0.19 | - | 0.22 | 0.04 | 0.26 | 3.55 | 7% |
| WHO | 0.12 | 0.11 | - | - | 0.11 | 1.65 | 7% |
| UNDP | 0.61 | 0.03 | 0.01 | 0.58 | 0.61 | 10.33 | 6% |
| Australia | 2.30 | 0.97 | 0.12 | 0.87 | 1.97 | 38.80 | 5% |
| Germany | 1.81 | 0.50 | 0.23 | 0.51 | 1.25 | 24.87 | 5% |
| Republic of Korea | 3.61 | 0.53 | 2.64 | 0.07 | 3.23 | 71.32 | 5% |
| Japan | 5.55 | 5.19 | 0.10 | 2.94 | 8.23 | 192.73 | 4% |
| EU/EC | 1.38 | 0.59 | 1.27 | 0.74 | 2.60 | 64.63 | 4% |
| Sweden | 0.50 | 0.70 | 0.11 | - | 0.81 | 23.76 | 3% |
| USA | 4.10 | 0.23 | 1.67 | 0.08 | 1.98 | 59.63 | 3% |
| France | 4.00 | 0.07 | 5.26 | - | 5.33 | 207.80 | 3% |
| China | 11.10 | 3.36 | 9.10 | - | 12.47 | 496.18 | 3% |
| Switzerland | 0.40 | 0.06 | 0.27 | - | 0.32 | 13.41 | 2% |
| UNICEF | - | - | 0.29 | - | 0.29 | 15.80 | 2% |
| New Zealand | - | - | 0.12 | - | 0.12 | 7.17 | 2% |
| Czech Republic | 0.04 | 0.02 | 0.01 | - | 0.03 | 1.99 | 2% |
| UNFPA | - | 0.02 | - | - | 0.02 | 2.43 | 1% |
| ILO | 0.02 | 0.02 | - | - | 0.02 | 3.88 | 0% |
| UNESCO | 0.01 | - | 0.01 | - | 0.01 | 5.46 | 0% |
| Others | 1.42 | - | - | - | - | 314.5 | 0% |
| **សរុប** | **56.95** | **12.80** | **50.01** | **16.28** | **79.09** | **1887.95** | **4%** |

## *វិធានការសម្រាប់ពង្រឹងការកត់ត្រាហិរញ្ញប្បទានរបស់អន្តរវិស័យ*

ទស្សនទាននៃ "ការបញ្ជ្រាប" ត្រូវបានចាត់ទុកជាយុទ្ធសាស្ត្រសម្រាប់បញ្ចូលបញ្ហាអន្តរវិស័យទៅក្នុងការរៀបចំ, ការអនុវត្ត , ការតាមដានត្រួតពិនិត្យ និងវាយតម្លៃគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍ ។ ដៃគូអភិវឌ្ឍន៍មួយចំនួនបានបញ្ជ្រាបបញ្ហាអន្តរវិស័យមួយចំនួន ទៅក្នុងវិស័យអាទិភាពរបស់ខ្លួន ។ រីឯដៃគូអភិវឌ្ឍន៍ដទៃទៀតបានចាត់ទុកថា បញ្ហាអន្តរវិស័យ គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រកិច្ចសហប្រតិបត្តិការ និងបានបញ្ជ្រាបបញ្ហានេះទៅក្នុងកម្មវិធី និងគម្រោងរបស់ខ្លួន ។

ក.អ.ក/គ.ជ.ទា បានសហការជាមួយដៃគូអភិវឌ្ឍន៍ ក្នុងរៀបចំសេចក្តីណែនាំ និងបានបណ្តុះបណ្តាលដល់មន្ត្រីបង្គោលរបស់ដៃគូអភិវឌ្ឍន៍ ដើម្បីកត់ត្រាការគាំទ្រទាំងនេះ ។ ទន្ទឹមនឹងនេះ ការបញ្ជ្រាបបញ្ហាអន្តរវិស័យក៏មិនតម្រូវឱ្យមានការគាំទ្រសកម្មភាពផ្នែកហិរញ្ញវត្ថុ ហើយមិនត្រូវបានរំលេចក្នុងការវិភាគនេះដែរ ។ ក្នុងន័យនេះ គប្បីបន្តកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីរំលេចអំពីកិច្ចប្រឹងប្រែងរបស់ដៃគូអភិវឌ្ឍន៍ក្នុងការបញ្ជ្រាបបញ្ហាអន្តរវិស័យទៅក្នុងកិច្ចការរបស់ពួកគេ និងក្នុងសកម្មភាពរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។

# ជំពូកទី ៥
# ការគាំទ្រហិរញ្ញប្បទានសហប្រតិបត្តិការក្នុងការអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ គឺជាយុទ្ធសាស្ត្រកំណើនសេដ្ឋកិច្ចថ្មី ដែលបំពេញតួនាទីជាយុទ្ធសាស្ត្រពហុវិស័យដ៏សំខាន់ ដើម្បីលើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច, ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព ។ គោលនយោបាយនេះបានដាក់ចេញនូវយុទ្ធសាស្ត្រគន្លឹះ, វិធានការគោលនយោបាយ និងផែនការសកម្មភាព ដែលផ្សារភ្ជាប់ជាមួយគោលដៅ និងចំណុចដៅ ដែលត្រូវសម្រេចឱ្យបានត្រឹមឆ្នាំ២០២៥ ដើម្បីជំរុញសេដ្ឋកិច្ចកម្ពុជាឱ្យរីកចម្រើនកាន់តែខ្ពស់ថែមទៀត នៅក្នុងខ្សែចង្វាក់តម្លៃតំបន់ និងសកល ។

ក្រោមភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំរបស់រាជរដ្ឋាភិបាល, ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា សម្រេចបានវឌ្ឍនភាពជាច្រើន ធៀបនឹងចំណុចដៅសំខាន់ៗ, វិធានការគោលនយោបាយ និងផែនការសកម្មភាព ក៏ដូចជាវិធានការគន្លឹះបួនជាក់ស្តែង ។ ទន្ទឹមនឹងនេះ រចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជាក៏មានការប្រែប្រួលខ្លាំងក្លាផងដែរ ។ យោងតាមរបាយការណ៍ឆ្នាំ២០១៧-២០១៨ ស្តីពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា, អនុបាតវិស័យឧស្សាហកម្មធៀបនឹងផលិតផលក្នុងស្រុកសរុប បានកើនឡើងពី ២៧,៧% ក្នុងឆ្នាំ២០១៥ ដល់ ៣២,៦% ក្នុងឆ្នាំ២០១៨ ពោលគឺសម្រេចបានលើសគោលដៅ ឆ្នាំ២០២៥ ដែលកំណត់ត្រឹមតែ ៣០%។

### *តួនាទីហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា*

ហិរញ្ញប្បទានសហប្រតិបត្តិការបានផ្តល់ប្រភពធនធានសំខាន់ សម្រាប់គាំទ្រការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា លើការងារអាទិភាពសំខាន់ៗរួមមាន ÷ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងប្រព័ន្ធឡូជីស្ទីក, ភាពជាដៃគូផ្ទាល់ជាមួយវិស័យឯកជន, ការវិនិយោគគន្លឹះជាយុទ្ធសាស្ត្រសម្រាប់កិច្ចសម្រួលពាណិជ្ជកម្ម និងការលើកកម្ពស់ភាពប្រកួតប្រជែងសេដ្ឋកិច្ច, ការកៀរគរប្រភពធនធានដទៃទៀត និងការគាំទ្រដល់កិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលដើម្បីធានាបរិស្ថានអំណោយផល និងទាក់ទាញវិនិយោគ ។

ប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានកត់ត្រាការគាំទ្ររបស់ដៃគូអភិវឌ្ឍន៍ សម្រាប់ពន្លឿនការអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ។

### *ការវិភាគហិរញ្ញប្បទានគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៨-២០១៩*

តារាងទី ៥.១ បានបង្ហាញថា ក្នុងឆ្នាំ២០១៨ ហិរញ្ញប្បទានប្រមាណ ១៥៧ លានដុល្លារ ស្មើនឹង ១៣% នៃហិរញ្ញប្បទានសរុប (មិនរាប់បញ្ចូលធនធានរបស់អង្គការមិនមែនរដ្ឋាភិបាល) ត្រូវបានបើកផ្តល់សម្រាប់គាំទ្រវិធានការគន្លឹះបួនជាក់ស្តែង និងវិធានការគោលនយោបាយ និងផែនការសកម្មភាព នៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ។ ក្នុងឆ្នាំ២០១៩ ការបើកផ្តល់អាចកើនរហូតដល់ ២៦៦ លានដុល្លារ ពោលគឺកើន ៥៩% ធៀប

នឹងឆ្នាំ២០១៨ ។ ទន្ទឹមនឹងនេះ ធនធាន ៧០% នៃធនធានសរុបសម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ត្រូវបានបើកផ្តល់សម្រាប់គាំទ្រការអនុវត្តវិធានការគន្លឹះបួនជាក់ស្តែង ក្នុងនោះ ហិរញ្ញប្បទានទំហំ ១៧៥ លានដុល្លារ សម្រាប់វិស័យថាមពល ក្នុងនោះធនធានរបស់សាធារណរដ្ឋប្រជាមានិតចិន ១១៩ លានដុល្លារ ។

**តារាងទី ៥.១ : ហិរញ្ញប្បទានគាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៨-២០១៩ *(លានដុល្លារ)***

| ដៃគូអភិវឌ្ឍន៍ | ឆ្នាំ២០១៨ (សរុប) | ឆ្នាំ២០១៩ | | | | | |
|---|---|---|---|---|---|---|---|
| | | ការជំរុញការទាក់ទាញវិនិយោគ | ការពង្រីកសហគ្រាសធុនតូចនិងមធ្យម | ការកែលម្អបរិស្ថាននិយ័តកម្ម | ការសម្របសម្រួលគោលនយោបាយគាំទ្រ | វិធានការគន្លឹះបួនជាក់ស្តែង | សរុប |
| សាធារណរដ្ឋប្រជាមានិតចិន | 54.7 | - | - | - | - | 119.2 | 119.2 |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 26.7 | 43.1 | - | - | 4.6 | 1.3 | 49 |
| បារាំង | 18.3 | - | - | - | 0.8 | 42.8 | 43.6 |
| ជប៉ុន | 24.7 | 1.8 | 2.3 | - | 5.4 | 8.7 | 18.2 |
| អូស្ត្រាលី | 11.6 | - | - | - | 5.9 | 3.0 | 8.9 |
| សាធារណរដ្ឋកូរ៉េ | 6.0 | - | 1.8 | 1.9 | 1.9 | 0.9 | 6.5 |
| ធនាគារពិភពលោក | - | - | - | - | 4.8 | - | 4.8 |
| នូវែលសេឡង់ | 3.4 | - | - | - | 3.4 | - | 3.4 |
| អាល្លឺម៉ង់ | 1.9 | - | 0.9 | 1.8 | - | - | 2.7 |
| ស្វីស | 2.5 | - | - | 0.03 | 2.3 | 0.02 | 2.4 |
| សហភាពអឺរ៉ុប | 2.5 | - | - | 2.1 | - | - | 2.1 |
| មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍវិស័យកសិកម្ម | 0.6 | - | 1.5 | - | - | - | 1.5 |
| ស៊ុយអែត | 1.2 | - | - | - | 1.1 | - | 1.1 |
| កាណាដា | 0.6 | - | 0.2 | - | 0.3 | - | 0.5 |
| អង្គការយូនីដូ | 0.1 | 0.4 | - | - | - | - | 0.4 |
| អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍ | 0.2 | - | - | 0.2 | 0.05 | - | 0.3 |
| ចក្រភពអង់គ្លេស | 0.3 | - | - | 0.05 | 0.1 | - | 0.2 |
| អង្គការយូណេស្កូ | 0.2 | - | - | - | 0.2 | - | 0.2 |
| អង្គការពលកម្មអន្តជាតិ | 0.1 | - | - | - | 0.2 | - | 0.2 |
| ផ្សេងៗ | 0.3 | - | - | - | - | - | 0.0 |
| **សរុប** | **156.7** | **45.3** | **6.7** | **6.1** | **31.0** | **175.9** | **265.7** |

សាធារណរដ្ឋប្រជាមានិតចិន, ធនាគារអភិវឌ្ឍន៍អាស៊ី, ជប៉ុន, បារាំង និងអូស្ត្រាលី គឺជាដៃគូអភិវឌ្ឍន៍សំខាន់ដែលបានបើកផ្តល់ហិរញ្ញប្បទានប្រមាណ ១៣៦ លានដុល្លារ ក្នុងឆ្នាំ២០១៨ និងប្រមាណ ២៣៨,៩ លានដុល្លារក្នុងឆ្នាំ២០១៩ សម្រាប់គាំទ្រដល់គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ។ វិធានការស្តីពីការជំរុញការវិនិយោគ និងវិធានការស្តីពីការសម្របសម្រួលគោលនយោបាយគាំទ្រ គឺជាផ្នែកការងារដែលបន្តទទួលបានការគាំទ្រភាគច្រើនពីដៃគូអភិវឌ្ឍន៍ ។

តារាងទី ៥.២ បានបង្ហាញថា ក្នុងចន្លោះឆ្នាំ២០១៥-២០១៩ ហិរញ្ញប្បទាន ៩១៧,២ លានដុល្លារ ពោលគឺប្រមាណ ១៨០ លានដុល្លារក្នុងមួយឆ្នាំ ត្រូវបានបើកផ្តល់សម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ។ វិធានការគន្លឹះប្អូនជាក់ស្តែងទទួលបានការគាំទ្រច្រើនជាងគេ ប្រមាណ ៦៥១,៣លានដុល្លារ ខណៈដែលវិធានការគោលនយោបាយស្តីពីការពង្រីកសហគ្រាសធុនតូច និងមធ្យម ទទួលបានការគាំទ្រតិចតួចនៅឡើយ ។ ដូចបានលើកឡើងក្នុងតារាងទី ៥.១, តារាងទី ៥.៣ បានបង្ហាញថា សាធារណរដ្ឋប្រជាមានិតចិន, ធនាគារអភិវឌ្ឍន៍អាស៊ី, បារាំង, ជប៉ុន និងអូស្ត្រាលី គឺជាដៃគូអភិវឌ្ឍន៍សំខាន់ៗដែលបានផ្តល់ហិរញ្ញប្បទានសរុប ៨២៧ លានដុល្លារ សម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ក្នុងចន្លោះឆ្នាំ២០១៥-២០១៩ ។ ក្នុងឆ្នាំ២០១៩ សាធារណរដ្ឋប្រជាមានិតចិន បានបើកផ្តល់ហិរញ្ញប្បទានច្រើនជាងគេ ប្រមាណ ១១៩,២ លានដុល្លារ សម្រាប់គាំទ្រអនុវត្តគោលនយោបាយនេះ តាមរយៈគម្រោងសាងសង់ខ្សែបណ្តាញអគ្គិសនីនៅភាគនិរតី និងបូព៌ា ។

**តារាងទី ៥.២ : ធនធានរយៈពេលមធ្យម ឆ្នាំ២០១៥-២០១៩ គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា**

*(លានដុល្លារ)*

| វិធានការគោលនយោបាយ និងវិធានការគន្លឹះប្អូនជាក់ស្តែង | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ (ប៉ាន់ស្មាន) | សរុប |
|---|---|---|---|---|---|---|
| ការជំរុញវិនិយោគ | 0.2 | 3.3 | 1.8 | 2.5 | 45.4 | 53.2 |
| ការពង្រីកសហគ្រាសធុនតូច និងមធ្យម | 1.1 | 1.7 | 3.6 | 3.9 | 6.7 | 17 |
| ការកែលម្អបរិយាកាសនិយ័តកម្ម | 4.3 | 9.0 | 25.9 | 8.7 | 6.1 | 54.0 |
| ការសម្របសម្រួលគោលនយោបាយគាំទ្រ | 27.4 | 22.2 | 28.2 | 31.9 | 31.5 | 141.2 |
| វិធានការគន្លឹះប្អូនជាក់ស្តែង | 55.9 | 148.0 | 162.0 | 109.5 | 175.9 | 651.3 |
| **សរុប** | **88.8** | **184.2** | **221.8** | **156.7** | **265.7** | **917.2** |

តារាងទី ៥.៣ : ធនធានរយៈពេលមធ្យមឆ្នាំ២០១៥-២០១៩ គាំទ្រគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា

*(លានដុល្លារ)*

| ដៃគូអភិវឌ្ឍន៍ | ឆ្នាំ២០១៥ | ឆ្នាំ២០១៦ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ (ប៉ាន់ស្មាន) | សរុប |
|---|---|---|---|---|---|---|
| សាធារណរដ្ឋប្រជាមានិតចិន | 45.1 | 122.2 | 133.2 | 54.6 | 119.2 | 474.3 |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 11.1 | 9.8 | 19.0 | 26.8 | 49.0 | 115.7 |
| បារាំង | 1.2 | 13.0 | 21.4 | 18.3 | 43.6 | 97.5 |
| ជប៉ុន | 12.8 | 19.0 | 16.5 | 24.8 | 18.2 | 91.3 |
| អូស្ត្រាលី | 7.3 | 9.5 | 11.4 | 11.7 | 8.8 | 48.7 |
| សាធារណរដ្ឋកូរ៉េ | - | 1.1 | 6.3 | 6.0 | 6.5 | 19.9 |
| នូវែលសេឡង់ | 2.6 | 1.9 | 3.1 | 3.4 | 3.4 | 14.4 |
| សហភាពអឺរ៉ុប | 2.8 | 1.7 | 1.3 | 2.4 | 2.0 | 10.2 |
| ស្វីស | 0.5 | 0.8 | 2.0 | 2.5 | 2.3 | 8.1 |
| អាល្លឺម៉ង់ | 0.0 | 1.1 | 2.0 | 1.9 | 2.7 | 7.7 |
| ស៊ុយអែត | 1.1 | 1.3 | 1.2 | 1.2 | 1.0 | 5.8 |
| សហរដ្ឋអាមេរិក | 1.2 | 0.8 | 1.0 | 0.2 | 0.3 | 3.5 |
| អង្គការពលកម្មអន្តរជាតិ | 0.9 | 1.0 | 1.0 | 0.2 | 0.1 | 3.2 |
| ធនាគារពិភពលោក | 1.8 | - | - | - | 4.8 | 6.6 |
| កាណាដា | 0.1 | 0.4 | 0.5 | 0.6 | 0.6 | 2.2 |
| សាធារណរដ្ឋឆែក | 0.3 | 0.4 | 0.3 | - | 0.4 | 1.4 |
| អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍ | 0.0 | 0.1 | 0.6 | 0.2 | 0.2 | 1.1 |
| មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម | - | - | 0.01 | 0.6 | 1.5 | 2.11 |
| អង្គការយូនីដូ | 0.1 | 0.1 | 0.2 | 0.05 | 0.4 | 0.85 |
| ចក្រភពអង់គ្លេស | 0.0 | 0.0 | 0.05 | 0.3 | 0.2 | 0.55 |
| អង្គការយូណេស្កូ | 0.0 | - | 0.1 | 0.2 | 0.1 | 0.4 |
| **សរុប** | **88.8** | **184.2** | **221.8** | **156.7** | **265.7** | **917.2** |

តារាងទី ៥.៤ បានបង្ហាញថា ក្នុងចន្លោះឆ្នាំ២០១៨-២០១៩ ដៃគូអភិវឌ្ឍន៍ចំនួន ១៦ បានបញ្ជ្រាបគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ទៅក្នុងការអនុវត្តគម្រោង និងកម្មវិធីរបស់ខ្លួន ។ ក្នុងឆ្នាំ២០១៨ ដៃគូអភិវឌ្ឍន៍ចំនួន១៥ បានបញ្ជ្រាបគោលនយោបាយនេះ ទៅក្នុងគម្រោងរបស់ពួកគេ ក្នុងទំហំ ១៦០ លានដុល្លារ ។ ហិរញ្ញប្បទាននេះអាចកើនប្រមាណ ៧៨ លានដុល្លារ ក្នុងឆ្នាំ២០១៩ ដោយសារហិរញ្ញប្បទានរបស់សាធារណ-រដ្ឋប្រជាមានិតចិន និងជប៉ុន ។ ក្នុងឆ្នាំ២០១៩ សាធារណរដ្ឋប្រជាមានិតចិន និងជប៉ុន នៅតែជាដៃគូសំខាន់ ដែលបានបញ្ជ្រាបគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ទៅក្នុងគម្រោង និងកម្មវិធី ដែលមាន ២៦,៨% និង ២៥,៤% នៃទំហំហិរញ្ញប្បទានរបស់ខ្លួន ។ បើគិតតាមកម្រិតនៃការបញ្ជ្រាប, សាធារណរដ្ឋប្រជាមានិតចិនបានបើកផ្តល់ ១២០,៩ លានដុល្លារ សម្រាប់បញ្ជ្រាបគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ក្នុងកម្រិតខ្ពស់ជាងគេ ។

តារាងទី ៥.៤ : ការបញ្ជ្រាបគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៨-២០១៩

*(លានដុល្លារ)*

| ដៃគូអភិវឌ្ឍន៍ | ឆ្នាំ២០១៨ (សរុប) | ឆ្នាំ២០១៩ (ប៉ាន់ស្មាន) | | | | ធនធានរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៩ | IDP គិតជា % នៃ ធនធានរបស់ដៃគូអភិវឌ្ឍន៍ ឆ្នាំ២០១៩ |
|---|---|---|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| សាធារណរដ្ឋប្រជាមានិតចិន | 87.6 | 3.3 | 9.1 | 120.9 | 133.4 | 496.1 | 26.8% |
| ជប៉ុន | 39.6 | 7.5 | 11.8 | 29.7 | 49 | 192.7 | 25.4% |
| ស្វីស | 0.5 | 0.1 | 2.0 | - | 2.1 | 13.4 | 15.6% |
| អាល្លឺម៉ង់ | 2.1 | 0.3 | 2.8 | 0.1 | 3.2 | 24.8 | 12.9% |
| បារាំង | 7.4 | 4.4 | 18.8 | 0.07 | 23.3 | 207.8 | 11.2% |
| អង្គការពលកម្មអន្តរជាតិ | 0.4 | 0.01 | 0.4 | - | 0.4 | 3.8 | 10.5% |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 14.5 | 2.8 | 15.6 | 1.4 | 20.0 | 245.9 | 8.1% |
| ធនាគារពិភពលោក | 0.9 | 4.7 | - | | 4.7 | 69.7 | 6.7% |
| អូស្ត្រាលី | 3.4 | 0.06 | 2.0 | - | 2.06 | 38.7 | 5.3% |
| សហភាពអឺរ៉ុប | 2.9 | 1.9 | 0.5 | 0.06 | 2.46 | 64.6 | 3.8% |
| អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍ | 0.4 | 0.4 | 0.0 | - | 0.4 | 10.3 | 3.8% |
| កាណាដា | 0.06 | - | 0.06 | - | 0.06 | 1.9 | 3.1% |
| អង្គការយូនីសេហ្វ | - | 0.1 | - | - | 0.1 | 12.8 | 0.7% |
| ស៊ុយអែត | 0.07 | 0.1 | - | - | 0.1 | 23.7 | 0.4% |
| សាធារណរដ្ឋកូរ៉េ | 0.3 | - | 0.07 | 0.1 | 0.17 | 71.3 | 0.2% |
| ផ្សេងៗ | 0.1 | - | - | - | - | 59.6 | 0% |
| **សរុប (មិនរាប់បញ្ចូលគម្រោងគ្រោងអនុវត្ត)** | **160.6** | **26.2** | **59.4** | **12.8** | **238.4** | **1887.9** | **12.6%** |

តារាងទី ៥.៥ បង្ហាញថា វិស័យដឹកជញ្ជូន, ថាមពល និងអគ្គិសនី និងកសិកម្ម ទទួលធនធានច្រើនជាងគេ ។ បើធៀបនឹងឆ្នាំ២០១៨ ធនធានសម្រាប់បញ្ជ្រាបគោលនយោបាយឧស្សាហកម្មក្នុងវិស័យអប់រំ បានកើនពី ២,៨ លានដុល្លារ ដល់ ៨,៩ លានដុល្លារ សម្រាប់ការអភិវឌ្ឍសមត្ថភាព និងជំនាញក្នុងវិស័យឧស្សាហកម្មនៅកម្ពុជា ។

### តារាងទី ៥.៥: ការបញ្ជាបតាមវិស័យនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ឆ្នាំ២០១៨-២០១៩ *(លានដុល្លារ)*

| វិស័យ | ឆ្នាំ២០១៨ (សរុប) | ឆ្នាំ២០១៩ (ប៉ាន់ស្មាន) | | | | ធនធានរបស់ដៃគូអភិវឌ្ឍន៍ក្នុងឆ្នាំ២០១៩ | IDP គិតជាភាគរយនៃធនធានរបស់ដៃគូអភិវឌ្ឍន៍ក្នុងឆ្នាំ២០១៩ |
|---|---|---|---|---|---|---|---|
| | | កម្រិតទាប | កម្រិតមធ្យម | កម្រិតខ្ពស់ | សរុប | | |
| ថាមពល និងអគ្គិសនី | 25.7 | 0.4 | 12.3 | 41.0 | 53.8 | 175.5 | 30.6% |
| ការដឹកជញ្ជូន និងឡូជីស្ទិក | 88.0 | 0.7 | 4.4 | 98.9 | 103.3 | 348.2 | 29.6% |
| ទឹកស្អាត និងអនាម័យ | 9.1 | - | 19.1 | 0.07 | 19.2 | 151.4 | 12.6% |
| កសិកម្ម | 23.7 | 14.5 | 14.9 | 7.0 | 36.3 | 309.2 | 11.8% |
| ឧស្សាហូបនីយកម្ម និងពាណិជ្ជកម្ម | 0.4 | 0.08 | 0.1 | 0.9 | 1.1 | 10.1 | 10.9% |
| ទេសចរណ៍ | 0.2 | - | 0.7 | - | 0.7 | 7.1 | 9.8% |
| ផ្សេងៗ | | 0.9 | 0.3 | - | 1.2 | 14.1 | 8.5% |
| ការអភិវឌ្ឍជនបទ | 5.2 | 5.0 | 2.0 | - | 7.0 | 94.7 | 7.4% |
| នគរូបនីយកម្ម និងការគ្រប់គ្រង | 1.0 | - | 4.0 | - | 4.0 | 55.9 | 7.1% |
| អប់រំ | 2.8 | 3.6 | 0.5 | 4.7 | 8.9 | 213.8 | 4.1% |
| សេវាធុរកិច្ច និងហិរញ្ញវត្ថុ | 0.2 | - | - | 0.1 | 0.1 | 2.8 | 3.6% |
| អភិបាលកិច្ច និងរដ្ឋបាល | 2.8 | 1.3 | 0.03 | 0.18 | 1.5 | 64.7 | 2.3% |
| ការប្រែប្រួលអាកាសធាតុ | 0.1 | 0.08 | - | - | 0.08 | 13.3 | 0.6% |
| សហគមន៍ និងសុខុមាលភាពសង្គម | 0.4 | 0.1 | 0.3 | - | 0.4 | 61.8 | 0.6% |
| យេនឌ័រ | 0.02 | - | 0.1 | - | 0.02 | 5.2 | 0.3% |
| បរិស្ថាន និងចីរភាព | 0.2 | 0.1 | - | - | 0.1 | 36.1 | 0.2% |
| វប្បធម៌ សិល្បៈ និងកីឡា | 0.02 | 0.01 | - | - | 0.01 | 63.8 | 0.02% |
| សុខាភិបាល | 0.3 | 2.6 | - | - | 0.03 | 244.2 | 0% |
| ជំនួយសង្គ្រោះបន្ទាន់ និងស្បៀងអាហារ | - | - | - | - | - | 3.2 | 0% |
| ហ៊ីវ/ អេដស៍ | - | - | - | - | - | 11.7 | 0% |
| បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ | 0.04 | - | - | - | - | 1.1 | 0% |
| សរុប (មិនរាប់បញ្ចូលគម្រោងគ្រោងនឹងអនុវត្ត) | 160.6 | 26.2 | 59.4 | 152.8 | 238.4 | 1887.9 | 12.6% |

### *ហិរញ្ញប្បទានសហប្រតិបត្តិការគាំទ្រវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅកម្ពុជា*

គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា បានទទួលស្គាល់ពីសារៈសំខាន់នៃការលើកកម្ពស់ការអប់រំ, ការបណ្តុះបណ្តាលបច្ចេកទេស និងជំនាញវិជ្ជាជីវៈ តាមរយៈការកែទម្រង់កម្មវិធីអប់រំ ។ តារាងទី ៥.៦ បង្ហាញថា ក្នុងចន្លោះឆ្នាំ២០១៧-២០១៩ ដៃគូអភិវឌ្ឍន៍ចំនួន ១៧ បានបើកផ្តល់ហិរញ្ញប្បទាន ជាមធ្យម ៣០,៥ លានដុល្លារក្នុងមួយឆ្នាំ សម្រាប់គាំទ្រវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ក្នុងនោះ ក្នុងឆ្នាំ២០១៩ ហិរញ្ញប្បទាន ៨៥% ត្រូវបានបើកផ្តល់ដោយដៃគូអភិវឌ្ឍន៍ ៥ គឺ ÷ អូស្ត្រាលី ៥,៩ លានដុល្លារ, ជប៉ុន ៥,៤ លានដុល្លារ, ធនាគារពិភពលោក ៤,៨ លានដុល្លារ, ធនាគារអភិវឌ្ឍន៍អាស៊ី ៤,៦ លានដុល្លារ និងនូវែលសេឡង់ ៣,៤ លានដុល្លារ ។

### តារាងទី ៥.៦ៈ ធនធានរបស់ដៃគូអភិវឌ្ឍន៍គាំទ្រដល់វិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

*(លានដុល្លារ)*

| ដៃគូអភិវឌ្ឍន៍ | ឆ្នាំ២០១៧ | ឆ្នាំ២០១៨ | ឆ្នាំ២០១៩ (ប៉ាន់ស្មាន) |
|---|---|---|---|
| អូស្ត្រាលី | 7.2 | 6.9 | 5.9 |
| ជប៉ុន | 5.8 | 5.9 | 5.4 |
| ធនាគារពិភពលោក | - | - | 4.8 |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 2.1 | 7.9 | 4.6 |
| នូវែលសេឡង់ | 3.1 | 3.4 | 3.4 |
| ស្វីស | 2.1 | 2.5 | 2.3 |
| សាធារណរដ្ឋកូរ៉េ | 4.2 | 1.6 | 1.7 |
| ស៊ុយអែត | 1.1 | 1.2 | 1 |
| បារាំង | 0.9 | 1 | 0.8 |
| កាណាដា | 0.2 | 0.3 | 0.3 |
| សាធារណរដ្ឋឆែក | - | - | 0.3 |
| អង្គការពលកម្មអន្តរជាតិ | 0.5 | 0.2 | 0.2 |
| អង្គការយូណេស្កូ | 0.1 | 0.3 | 0.2 |
| ចក្រភពអង់គ្លេស | 0.1 | 0.3 | 0.1 |
| អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍ | - | - | 0.05 |
| សហភាពអឺរ៉ុប | 0.2 | 0.07 | - |
| សហរដ្ឋអាមេរិក | 0.2 | 0.2 | - |
| **សរុប** | **28.0** | **31.9** | **31.3** |

# ជំពូកទី ៦
# ការចាកចេញពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួចរបស់កម្ពុជា

កម្ពុជាសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប នាខែកក្កដា ឆ្នាំ២០១៦ ដោយចំណូលជាតិសរុបសម្រាប់ប្រជាជនម្នាក់បានកើនលើសពី១.០២៥ ដុល្លារ ក្នុងឆ្នាំ២០១៥ ។ ចំណាត់ថ្នាក់ប្រទេសមានការអភិវឌ្ឍតិចតួច ត្រូវបានកំណត់ផ្អែកតាមលក្ខខណ្ឌវិនិច្ឆ័យ ៣ គឺ÷ ចំណូលជាតិសរុបសម្រាប់ប្រជាជនម្នាក់, ធនធានមនុស្ស និងភាពងាយរងគ្រោះខាងសេដ្ឋកិច្ច ដែលខុសប្លែកពីចំណាត់ថ្នាក់របស់ធនាគារពិភពលោក ដោយផ្អែកលើលក្ខខណ្ឌចំណូលសម្រាប់ប្រទេសនីមួយៗ ។

ផ្អែកលើវឌ្ឍនភាពយ៉ាងលឿនក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច, កម្ពុជាសង្ឃឹមថានឹងអាចឈានទៅចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ដែលកិច្ចដំណើរការនេះត្រូវពិនិត្យដោយគណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ ។ ជំពូកនេះបង្ហាញអំពីភាពអនុគ្រោះដែលកម្ពុជាទទួលបានក្នុងឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួច ព្រមទាំងកំណត់នូវវិធានការគោលនយោបាយសំខាន់ៗ ក្នុងរយៈពេលអន្តរកាលសម្រាប់ត្រៀមចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ដែលរំពឹងថាអាចចាប់ផ្តើមក្នុងឆ្នាំ២០២១ ។

***អត្ថប្រយោជន៍ និងភាពអនុគ្រោះសម្រាប់កម្ពុជាក្នុងឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួច***

ប្រទេសមានការអភិវឌ្ឍតិចតួចទទួលបានអត្ថប្រយោជន៍ជាច្រើន រួមមាន÷ ការអនុគ្រោះក្នុងការនាំចេញទៅកាន់ទីផ្សារ, ការផ្តល់លក្ខខណ្ឌ និងភាពអនុគ្រោះជាក់លាក់, ជំនួយបច្ចេកទេសផ្នែកពាណិជ្ជកម្ម, និងកិច្ចសម្រួលពាណិជ្ជកម្មក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក ។

ការគាំទ្រដែលប្រទេសមានការអភិវឌ្ឍតិចតួចទទួលបាន ក្រោមកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម (TFAF) និងភាពអនុគ្រោះផ្នែកពាណិជ្ជកម្ម រួមមាន ÷

- អត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងស្តីពីកិច្ចសម្រួលពាណិជ្ជកម្ម (TFAF) ដូចជាការអនុគ្រោះពន្ធ និងការមិនកំណត់កូតាទំនិញចូលទីផ្សារ, កិច្ចសម្រួលបែបបទគយ និងការលើកលែងពន្ធ ផ្អែកលើសមត្ថភាពនៃអនុលោមភាព ដោយរាប់បញ្ចូលទាំងការពន្លឿនការដឹកជញ្ជូន និងលើកដាក់ទំនិញ និងវិធានការប្រកបដោយប្រសិទ្ធភាពក្នុងកិច្ចសហប្រតិបត្តិការដែលពាក់ព័ន្ធនឹងកិច្ចសម្រួលពាណិជ្ជកម្ម និងគយ ។
- ភាពអនុគ្រោះផ្នែកពាណិជ្ជកម្ម ដូចជាការសម្រួលការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មពាក់ព័ន្ធនឹងកម្មសិទ្ធិបញ្ញា (TRIPs) និងកិច្ចព្រមព្រៀងស្តីពីវិធានការសម្រាប់ការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម (TRIMs) ដែលសម្រួលដល់ការអនុវត្តច្បាប់ និងគោលការណ៍នានាស្តីពីកម្មសិទ្ធិបញ្ញា និងការវិនិយោគក្នុងប្រទេសមានការអភិវឌ្ឍតិចតួច ដែលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។

ពាក់ព័ន្ធនឹងកិច្ចការពារលើកម្មសិទ្ធិបញ្ញា, កម្ពុជាអាចបន្តទទួលបានភាពអនុគ្រោះពាក់ព័ន្ធកម្មសិទ្ធិបញ្ញាក្រោមកិច្ចព្រមព្រៀង TRIPS របស់អង្គការពាណិជ្ជកម្មពិភពលោក រហូតដល់ឆ្នាំ ២០២១ ។ ទោះបីត្រូវប្រឈមនឹង

បញ្ហាមួយចំនួនខាងសេដ្ឋកិច្ច, ហិរញ្ញវត្ថុ, បច្ចេកវិទ្យា និងរដ្ឋបាល ឬបញ្ហានានាក្នុងការត្រៀមចាកចេញពីប្រទេសមានការអភិវឌ្ឍតិចតួចក៏ដោយ, ក៏កម្ពុជាត្រូវអនុវត្តទាំងស្រុងនូវគោលការណ៍នៃកិច្ចព្រមព្រៀង TRIPS នៅក្រោយឆ្នាំ ២០២១ ដើម្បីសម្រួលពាណិជ្ជកម្មពាក់ព័ន្ធនឹងចំណេះដឹង និងការបង្កើតថ្មី សម្រាប់ការពារប៉ាតង់កម្មសិទ្ធិបញ្ញាស្ដីពីប្រកាសនីយប័ត្រតក្កកម្ម ក៏ដូចជាការពារការមិនផ្សព្វផ្សាយព័ត៌មាន ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងយកចិត្តទុកដាក់ដល់ការបង្កើតគោលការណ៍ស្ដីពីកម្មសិទ្ធិបញ្ញា ដែលមានសង្គតិភាពជាមួយនឹងកិច្ចព្រមព្រៀងនេះ ពិសេសពាក់ព័ន្ធនឹងកម្មសិទ្ធិស្ដីពីប្រកាសនីយប័ត្រតក្កកម្ម និងគំរូប្លង់ផ្នែកឧស្សាហកម្ម ជាដើម ។

ពាក់ព័ន្ធនឹងការលើកកម្ពស់ការវិនិយោគ, កម្ពុជានឹងអនុវត្តវិធានការទាំងឡាយស្របតាមកិច្ចព្រមព្រៀង TRIMs នៅក្រោយឆ្នាំ ២០២១ ប្រសិនពុំមានការចរចាពន្យារសុពលភាពកិច្ចព្រមព្រៀងនេះ ។ ក្នុងន័យនេះ កម្ពុជាអាចប្រឈមនឹងការរឹតត្បិតក្នុងការអនុវត្តគោលការណ៍មួយចំនួន ដូចជាការប្រើប្រាស់វត្ថុធាតុដើមក្នុងស្រុក, សមិទ្ធកម្មការនាំចេញ, និងបទដ្ឋានលទ្ធកម្មរបស់រដ្ឋាភិបាល ដែលគោលការណ៍ទាំងនេះត្រូវបានអនុវត្តជាទូទៅដោយប្រទេសអភិវឌ្ឍន៍ និងឧស្សាហករដែលបានទទួលជោគជ័យកន្លងមកក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពអំពីភាពបត់បែនក្នុងការអនុវត្តបទប្បញ្ញត្តិរបស់ខ្លួន និងអាចស្នើជំនួយបច្ចេកទេសតាមរយៈកិច្ចសហប្រតិបត្តិការទ្វេភាគី ឬពហុភាគី ដើម្បីពន្លឿនដំណើរការនៃការអនុម័តបទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានា បន្ទាប់ពីការអនុវត្តភាពអនុគ្រោះនៃកិច្ចព្រមព្រៀងទាំងពីរនេះត្រូវបានបញ្ចប់ ។

ហិរញ្ញប្បទានសហប្រតិបត្តិការគឺជាប្រភពធនធានដ៏សំខាន់សម្រាប់បណ្ដាប្រទេសមានការអភិវឌ្ឍតិចតួច ។ អត្ថប្រយោជន៍ដទៃទៀតដែលប្រទេសមានការអភិវឌ្ឍតិចតួចទទួលបាន គឺហិរញ្ញប្បទានសហប្រតិបត្តិការ និងទម្រង់នៃការផ្ដល់ធនធាន និងហិរញ្ញប្បទានសម្រាប់ការប្រែប្រួលអាកាសធាតុ ។ ប្រទេសមានការអភិវឌ្ឍតិចតួចក៏ទទួលបានជំនួយបច្ចេកទេស និងវិធានការគាំទ្រអន្តរជាតិទូទៅ (ISMs) ដូចជាកិច្ចសហប្រតិបត្តិការបច្ចេកទេសសម្រាប់ជំរុញពាណិជ្ជកម្ម, ហិរញ្ញប្បទានសម្រាប់ពាណិជ្ជកម្ម, ធនាគារបច្ចេកវិទ្យារបស់អង្គការសហប្រជាជាតិសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួច, ការគាំទ្រប្រឹក្សាផ្នែកច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោក និងការគាំទ្រសម្រាប់ចូលរួមក្នុងកិច្ចប្រជុំរបស់អង្គការទាំងនេះ ជាដើម ។ លើសពីនេះ ប្រទេសមានការអភិវឌ្ឍតិចតួចអាចទទួលអត្ថប្រយោជន៍ ពីការអនុវត្តផែនការសកម្មភាពសម្រាប់ប្រទេសមានការអភិវឌ្ឍតិចតួច ដែលផ្ដោតលើសមត្ថភាពផលិតកម្ម និងការផ្លាស់ប្ដូររចនាសម្ព័ន្ធសេដ្ឋកិច្ច រួមទាំងការអភិវឌ្ឍមូលធនរូបវន្ត, ធនធានមនុស្ស និងសង្គម ។

ភាពអនុគ្រោះពាណិជ្ជកម្ម គឺជាអត្ថប្រយោជន៍សំខាន់ជាងគេសម្រាប់កម្ពុជា ដែលជាប្រទេសមានការអភិវឌ្ឍតិចតួច ។ សហភាពអឺរ៉ុបគឺជាគោលដៅនាំចេញធំបំផុតរបស់កម្ពុជា ដែលមានទំហំ ៤,៧ ពាន់លានដុល្លារអាមេរិក (ស្មើនឹង ៣៨% នៃការនាំចេញសរុប ក្នុងឆ្នាំ២០១៨) ។ បន្ទាប់មក គឺសហរដ្ឋអាមេរិក, ចិន, ជប៉ុន និងកាណាដា ។ កម្ពុជាក៏ទទួលបានប្រព័ន្ធអនុគ្រោះ “ទំនិញគ្រប់មុខលើកលែងតែសព្វាវុធ (EBA)” ពីសហភាពអឺរ៉ុប ដែលផ្ដល់ភាពអនុគ្រោះពន្ធ និងការមិនកំណត់កូតាសម្រាប់គ្រប់មុខទំនិញនាំចេញ លើកលែងតែសព្វាវុធ ។ បន្ទាប់ពីចាកចេញផុតពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច, កម្ពុជានឹងបាត់បង់ប្រព័ន្ធអនុគ្រោះនេះ ក្នុងរយៈពេលអន្តរកាល

ហើយត្រូវជំនួសវិញដោយការផ្តល់ប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP) ។ បណ្តាប្រទេសអភិវឌ្ឍភាគច្រើននឹងបន្តផ្តល់ភាពអនុគ្រោះក្នុងរយៈពេលអន្តរកាល ដល់បណ្តាប្រទេសដែលទើបឆ្លងផុតពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ។ ដូច្នេះ បន្ទាប់ពីឆ្លងផុតពីប្រទេសមានការអភិវឌ្ឍតិចតួច, លក្ខខណ្ឌអនុគ្រោះផ្នែកពាណិជ្ជកម្មនឹងមានការផ្លាស់ប្តូរ ប៉ុន្តែនៅតែមានលក្ខណៈសម្បទានខ្ពស់ ។ រីឯប្រព័ន្ធ GSP+ របស់សហភាពអឺរ៉ុប ក៏ផ្តល់ភាពអនុគ្រោះស្រដៀងនឹងប្រព័ន្ធ EBA ដែរ ដោយផ្អែកលើលក្ខខណ្ឌវិនិច្ឆ័យមិនមែនសេដ្ឋកិច្ច រួមទាំងការប្តេជ្ញាខាងសិទ្ធិមនុស្ស និងបទដ្ឋានការងារ ។

**គំនូរទី ៦.១ ការនាំចេញរបស់កម្ពុជា**







កម្ពុជាអាចទទួលបានភាពអនុគ្រោះពន្ធខាងពាណិជ្ជកម្ម ក្នុងក្របខណ្ឌអង្គការពាណិជ្ជកម្មពិភពលោក និងប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP) ក្នុងនោះរួមមាន កិច្ចព្រមព្រៀងពាណិជ្ជកម្មជាមួយសហរដ្ឋអាមេរិក ។ ចាប់ពីឆ្នាំ ១៩៩៤ សហរដ្ឋអាមេរិកបានបញ្ចូលបទប្បញ្ញត្តិស្តីពីបទដ្ឋានការងារក្នុងគ្រប់កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីរបស់ខ្លួន ។ ក្នុងកិច្ចព្រមព្រៀងទ្វេភាគីស្តីពីវិស័យវាយនភណ្ឌជាមួយកម្ពុជា, សហរដ្ឋអាមេរិកបានភ្ជាប់ការលើកកម្ពស់បទដ្ឋានការងារជាមួយការបង្កើនចំនួនកូតាសម្បទានពាណិជ្ជកម្ម ។ លើសពីនេះ ក្នុងឆ្នាំ ២០០៦ កម្ពុជា និងសហរដ្ឋ-អាមេរិក បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីពីក្របខណ្ឌវិនិយោគ និងពាណិជ្ជកម្ម ។ ក្នុងឆ្នាំ២០១២ ប្រទេសទាំងពីរបានចាប់ផ្តើមពិភាក្សាលើសន្ធិសញ្ញាស្តីពីការវិនិយោគទ្វេភាគី ។ កន្លងមក កម្ពុជាបានទទួលអត្ថប្រយោជន៍ពីការជួចផ្តើមឱ្យមានការចរាចរទំនិញក្រោមកិច្ចព្រមព្រៀងនេះ ។ ក្នុងន័យនេះ កម្ពុជាដែលជាប្រទេសមានការអភិវឌ្ឍតិចតួច នឹងបន្តសហការជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ដើម្បីទាញយកអត្ថប្រយោជន៍ និងភាពអនុគ្រោះនានាបន្ថែមទៀត ។

*វឌ្ឍនភាពរបស់កម្ពុជាក្នុងការឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច*

ដើម្បីឆ្លងផុតពីប្រទេសមានការអភិវឌ្ឍតិចតួច ប្រទេសនីមួយៗត្រូវសម្រេចលក្ខខណ្ឌ ២ ក្នុងចំណោមលក្ខខណ្ឌវិនិច្ឆ័យទាំង ៣ រួមមាន÷ ចំណូលជាតិសម្រាប់ប្រជាជនម្នាក់, ធនធានមនុស្ស និងភាពងាយរងគ្រោះខាងសេដ្ឋកិច្ច ឬសម្រេចទ្វេដងនូវលក្ខខណ្ឌវិនិច្ឆ័យស្ដីពីចំណូល ក្នុង ២ សម័យកាលជាប់ៗគ្នានៃកិច្ចប្រជុំត្រួតពិនិត្យរបស់គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ ។

តាមរយៈកំណើនសេដ្ឋកិច្ចដ៏រឹងមាំ និងវឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រីក្រ ក៏ដូចជាការអនុវត្តជោគជ័យនូវយុទ្ធសាស្រ្តចតុកោណ, កម្ពុជាសម្រេចបានលើសលក្ខខណ្ឌវិនិច្ឆ័យស្ដីពីការអភិវឌ្ឍធនធានមនុស្ស និងកំពុងឈានទៅសម្រេចលក្ខខណ្ឌស្ដីពីភាពងាយរងគ្រោះខាងសេដ្ឋកិច្ច ។ សន្ទស្សន៍នៃការអភិវឌ្ឍធនធានមនុស្សរបស់កម្ពុជាមានពិន្ទុ ៦៨,៩ លើសពិន្ទុកំណត់ (≥ ៦៦ ពិន្ទុ) ។ សន្ទស្សន៍នៃភាពងាយរងគ្រោះខាងសេដ្ឋកិច្ច បានថយពី ៥០,៥ ពិន្ទុ ក្នុងឆ្នាំ២០១២ មកត្រឹម ៣៤,៨ ពិន្ទុ ក្នុងឆ្នាំ២០១៨ ប៉ុន្តែ តម្រូវឱ្យកាត់បន្ថយ ២,៨ ពិន្ទុបន្ថែមទៀត ទើបអាចចុះមកត្រឹម ៣២ ពិន្ទុ ឬទាបជាងនេះ ដែលជាពិន្ទុកំណត់ ។ ក្នុងឆ្នាំ ២០១៨ កម្ពុជាមានចំណូលជាតិសម្រាប់ប្រជាជនម្នាក់ប្រមាណ ១.០៧៥ ដុល្លារអាមេរិក (តាមការវាស់វែងរបស់អង្គការសហប្រជាជាតិ) ដែលមានគម្លាតត្រឹមតែ ១៩៥ ដុល្លារអាមេរិក ពីលក្ខខណ្ឌវិនិច្ឆ័យ (១.២៩២ ដុល្លារអាមេរិក), និងតាមការព្យាករណ៍ ចំណូលនេះអាចកើនដល់ ១.៣៥៣ ដុល្លារអាមេរិក ក្នុងឆ្នាំ២០២១ ពោលគឺខ្ពស់ជាងលក្ខខណ្ឌវិនិច្ឆ័យ ។

ក្នុងន័យនេះ កម្ពុជាសង្ឃឹមថា នឹងត្រូវបានដាក់បញ្ចូលក្នុងបញ្ជីប្រទេសសម្រាប់ឆ្លងផុតពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច នៅក្នុងកិច្ចប្រជុំត្រួតពិនិត្យរបស់គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ ដែលគ្រោងប្រព្រឹត្តទៅក្នុងឆ្នាំ២០២១ ។ បញ្ជីនេះនឹងត្រូវពិនិត្យម្ដងទៀត ក្នុងឆ្នាំ២០២៤ និងស្នើការអនុម័តពីមហាសន្និបាតអង្គការសហប្រជាជាតិ នាឆ្នាំបន្ទាប់ ។ បន្ទាប់មក ប្រទេសបេក្ខភាពនីមួយៗ រួមទាំងកម្ពុជាអាចទទួលរយៈពេលអន្តរកាល ៣ ឆ្នាំ ។ បន្ទាប់ពីចាកចេញជាផ្លូវការ, ប្រទេសនីមួយៗអាចបន្តទទួលបានការគាំទ្រ និងភាពអនុគ្រោះរយៈពេល ៣ ឆ្នាំបន្ថែមទៀត ដើម្បីធានាថា ប្រទេសនោះមិនធ្លាក់ចូលក្នុងក្រុមប្រទេសមានការអភិវឌ្ឍតិចតួចម្ដងទៀតឡើយ ។ ផ្អែកលើសេណារីយ្យូនេះ កម្ពុជាអាចឆ្លងផុតពីប្រទេសមានការអភិវឌ្ឍតិចតួច ក្នុងឆ្នាំ ២០២៧ និងរយៈពេលអន្តរកាលអាចបន្តរហូតដល់ឆ្នាំ២០៣០ ។

**តារាងទី ៦.១ លក្ខខណ្ឌវិនិច្ឆ័យសម្រាប់កម្ពុជាឆ្លងផុតពីប្រទេសមានការអភិវឌ្ឍតិចតួច**

| | ឆ្នាំនៃការពិនិត្យ (រាល់បីឆ្នាំម្តង) | 2006 | 2009 | 2012 | 2015 | 2018 | 2021 (ព្យាករណ៍) |
|---|---|---|---|---|---|---|---|
| ១ | ពិន្ទុនៃចំណូលជាតិសម្រាប់ប្រជាជនម្នាក់ | 900 | 1,086 | 1,190 | 1,242 | 1,230 | 1,292 |
| | ចំណូលជាតិសម្រាប់ប្រជាជនកម្ពុជាម្នាក់ | 303 | 490 | 707 | 852 | 1,075 | 1,353 |
| | គម្លាតធៀបនឹងពិន្ទុកំណត់* | -597 | -596 | -483 | -390 | -155 | +61 |
| | | *ពុំទាន់សម្រេច* | *ពុំទាន់សម្រេច* | *ពុំទាន់សម្រេច* | *ពុំទាន់សម្រេច* | *ពុំទាន់សម្រេច* | *សម្រេច* |
| ២ | ពិន្ទុនៃការអភិវឌ្ឍធនធានមនុស្ស | 64 | 66 | 66 | 66 | 66 | 66 |
| | សន្ទស្សន៍នៃការអភិវឌ្ឍធនធានមនុស្សកម្ពុជា | 46 | 58 | 58 | 67 | 69 | 78 |
| | គម្លាតធៀបនឹងពិន្ទុកំណត់* | -18 | -8 | -8 | +1 | +3 | +12 |
| | | *ពុំទាន់សម្រេច* | *ពុំទាន់សម្រេច* | *ពុំទាន់សម្រេច* | *សម្រេច* | *សម្រេច* | *សម្រេច* |
| ៣ | ពិន្ទុនៃភាពងាយរងគ្រោះខាងសេដ្ឋកិច្ច | 38 | 38 | 32 | 32 | 32 | 32 |
| | សន្ទស្សន៍នៃភាពងាយរងគ្រោះខាងសេដ្ឋកិច្ចកម្ពុជា | 52 | 56 | 50 | 38 | 35 | 29 |
| | គម្លាតធៀបនឹងពិន្ទុកំណត់* | -14 | -18 | -18 | -6 | -3 | +3 |
| | | *ពុំទាន់សម្រេច* | *ពុំទាន់សម្រេច* | *ពុំទាន់សម្រេច* | *ពុំទាន់សម្រេច* | *ពុំទាន់សម្រេច* | *សម្រេច* |

*ប្រភព : ការត្រួតពិនិត្យក្នុងឆ្នាំ២០១៨ របស់គណៈកម្មាធិការគោលនយោបាយអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិ ។ សញ្ញាដក (-) បង្ហាញ "គម្លាត"; សញ្ញាបូក(+) បង្ហាញ"លើស" ពិន្ទុកំណត់ ។*

## *ផលប៉ះពាល់នៃការឆ្លងផុតពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច*

ការចាកចេញពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច គឺជាការទទួលស្គាល់អំពីសមិទ្ធផល និងភាពជោគជ័យក្នុងការអនុវត្តលក្ខខណ្ឌវិនិច្ឆ័យ ៣ (ចំណូលជាតិសម្រាប់ប្រជាជនម្នាក់, ធនធានមនុស្ស, និងភាពងាយរងគ្រោះខាងសេដ្ឋកិច្ច) ។ ប្រការនេះ បានលើកកម្ពស់កិត្យានុភាពជាតិ ក្នុងការដឹកនាំកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព ។ សមិទ្ធផលទាំងនេះ គួបផ្សំនឹងការកែទម្រង់ស៊ីជំរៅរបស់រាជរដ្ឋាភិបាលសម្រាប់ធ្វើឱ្យប្រសើរឡើងនូវបរិយាកាសវិនិយោគ ក៏អាចទាក់ទាញការវិនិយោគថ្មីៗបន្ថែមទៀតផងដែរ ។

ការចាកចេញពីប្រទេសមានការអភិវឌ្ឍតិចតួច អាចប្រឈមនឹងការបាត់បង់អត្ថប្រយោជន៍ និងសម្បទានមួយចំនួនក្នុងក្របខណ្ឌនៃវិធានការគាំទ្រអន្តរជាតិ (ISMs) ពិសេសពាក់ព័ន្ធនឹងពាណិជ្ជកម្ម, ហិរញ្ញប្បទានសហប្រតិបត្តិការ និងការគាំទ្រសម្រាប់ចូលរួមកិច្ចដំណើរការរបស់អង្គការសហប្រជាជាតិ និងកិច្ចដំណើរការដទៃទៀត ។ សម្រាប់កម្ពុជា, ការចាកចេញពីប្រទេសមានការអភិវឌ្ឍតិចតួច អាចនាំទៅដល់ការធ្លាក់ចុះនៃទំហំហិរញ្ញប្បទានឥតសំណង ទន្ទឹមនឹងការផ្លាស់ប្តូរលក្ខខណ្ឌនៃការផ្តល់ឥណទានសម្បទាន ពីកម្រិតសម្បទានខ្ពស់ទៅកម្រិតសម្បទានទាប ឬអាចឈានដល់ឥណទានដែលមានលក្ខណៈពាណិជ្ជកម្ម ក្នុងរយៈពេលវែង ។ ទន្ទឹមនឹងនេះ កម្ពុជានឹងបាត់ភាពអនុគ្រោះពន្ធ, ការមិនកំណត់ចំនួនកូតា និងការសម្រួលនីតិវិធីក្នុងការបញ្ជាក់ប្រភពដើមទំនិញរបស់ប្រទេសមានការអភិវឌ្ឍតិចតួច ដែលអាចប៉ះពាល់ដល់ការនាំចេញសម្លៀកបំពាក់ និងទោចក្រយានទៅកាន់ទីផ្សារសំខាន់ៗ ដូចជាសហភាពអឺរ៉ុប, អាមេរិក និងកាណាដាជាដើម ។

ការចាកចេញរបស់ចក្រភពអង់គ្លេសពីសហភាពអឺរ៉ុប ពុំទាន់មានភាពច្បាស់លាស់នៅឡើយ ទោះបីមានភាពជោគជ័យក្នុងការចរចាកិច្ចព្រមព្រៀង និងការប្ដេជ្ញាខាងនយោបាយក៏ដោយ ។ ទោះជាយ៉ាងនេះក្ដី ការចាកចេញរបស់ចក្រភពអង់គ្លេសពីសហភាពអឺរ៉ុប អាចនាំឱ្យមានការផ្លាស់ប្ដូររបបពាណិជ្ជកម្មរបស់ចក្រភពអង់គ្លេស ជាមួយដៃគូពាណិជ្ជកម្ម ដោយសារប្រព័ន្ធពាណិជ្ជកម្មអង់គ្លេសមិនស្ថិតក្នុងប្រព័ន្ធអនុគ្រោះទូទៅ GSPs ឬប្រព័ន្ធអនុគ្រោះ EBA របស់សហភាពអឺរ៉ុបទៀតឡើយ ។ ការចាកចេញនេះអាចជះឥទ្ធិពលដល់ពាណិជ្ជកម្មទ្វេភាគីកម្ពុជា-អង់គ្លេស ។ ប៉ុន្តែ ដោយផ្អែកលើការចរចាបឋម, ចក្រភពអង់គ្លេសបានទទួលស្គាល់ថា កម្ពុជា គឺជាដៃគូពាណិជ្ជកម្មសំខាន់របស់ខ្លួន ហើយសង្ឃឹមថា ចក្រភពអង់គ្លេសនឹងបន្តផ្ដល់ការអនុគ្រោះពន្ធ និងការមិនកំណត់ចំនួនកូតាលើផលិតផលនាំចេញរបស់កម្ពុជា ដូចធ្លាប់បានអនុវត្តក្នុងក្របខណ្ឌ EBA របស់សហភាពអឺរ៉ុប ។

បន្ទាប់ពីកម្ពុជាចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច, អត្រាពន្ធជាមធ្យមសម្រាប់ទំនិញនាំចេញនឹងត្រូវកំណត់តាមស្ដង់ដារប្រព័ន្ធអនុគ្រោះទូទៅ (GSP) ដែលកំណត់អត្រាពន្ធផ្សេងៗពីគ្នាដោយប្រទេសមួយសម្រាប់ផលិតផលនាំចេញពីប្រទេសជាក់លាក់ដទៃទៀត ។ បើមិនដូច្នោះទេ, អត្រាពន្ធជាមធ្យមលើទំនិញនាំចេញនឹងត្រូវអនុវត្តតាមប្រព្រឹត្តិកម្មជាតិអនុគ្រោះបំផុត (MFN) ដែលកំណត់អត្រាស្មើគ្នា និងដោយគ្មានការរើសអើងចំពោះទំនិញនាំចេញរបស់ប្រទេសដែលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ។ ការបាត់បង់ភាពអនុគ្រោះផ្នែកពាណិជ្ជកម្ម បន្ទាប់ពីឆ្លងផុតពីប្រទេសមានការអភិវឌ្ឍតិចតួច ត្រូវបានបង្ហាញក្នុងតារាងទី ៦.២ ។ អត្រាពន្ធជាមធ្យមត្រូវបានព្យាករណ៍ថានឹងកើនឡើងពី 0% ក្នុងក្របខណ្ឌ EBA ដល់ ៨,៥% តាមស្ដង់ដារ GSP និង ១១% តាមស្ដង់ដារ MFN សម្រាប់នាំចេញសម្លៀកបំពាក់, វាយនភ័ណ្ឌ និងស្បែកជើង ។ សម្រាប់ការនាំចេញទោចក្រយានទៅសហភាពអឺរ៉ុប, អត្រាពន្ធជាមធ្យមអាចកើនដល់ ១០,៥% តាមស្ដង់ដារ GSP និង ១៤,៥% តាមស្ដង់ដារ MFN ។ ការនាំចេញទោចក្រយានទៅកាណាដា ក៏អាចប្រឈមនឹងកំណើនអត្រាពន្ធប្រមាណ ៨,៥% តាមស្ដង់ដារ GSP និង ១៣% តាមស្ដង់ដារ MFN និងសហរដ្ឋអាមេរិក ៧,៣% តាមស្ដង់ដារ GSP និង ៨% តាមស្ដង់ដារ MFN ។

លើមូលដ្ឋាននេះ បន្ទាប់ពីចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច, ប្រទេសនីមួយៗត្រូវបន្តគ្រប់គ្រងគោលនយោបាយពាណិជ្ជកម្ម ក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មដែលមានស្រាប់ ដូចជាការចរចាសម្រាប់ការអនុគ្រោះពន្ធ និងការមិនកំណត់ចំនួនកូតាសម្រាប់មុខទំនិញនាំចេញមួយចំនួន ឬការបន្តពិភាក្សាជាមួយសហភាពអឺរ៉ុប (ឬចក្រភពអង់គ្លេស បន្ទាប់ពីការចាកចេញពីសហភាពអឺរ៉ុប) លើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីដែលសហភាពអឺរ៉ុបផ្ដល់ដល់ប្រទេសចាកចេញពីក្រុមនេះ នូវភាពអនុគ្រោះប្រហាក់ប្រហែលគ្នាទៅនឹងការអនុគ្រោះដែលធ្លាប់បានផ្ដល់ឱ្យប្រទេសដែលមិនស្ថិតក្នុងក្រុមប្រទេសមានការអភិវឌ្ឍតិចតួច សម្រាប់នាំចេញទំនិញទៅកាន់ទីផ្សារអឺរ៉ុប ។

### តារាងទី ៦.២ កំណើនអត្រាពន្ធជាមធ្យមបន្ទាប់ពីការឆ្លងផុតពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច

| ផលិតផល | ទីផ្សារនាំចេញ* | | អត្រាពន្ធជាមធ្យម | | |
|---|---|---|---|---|---|
| | | | អត្រាពន្ធបច្ចុប្បន្ន | បន្ទាប់ពីឆ្លងផុតពីប្រទេសមានការអភិវឌ្ឍតិចតួច | |
| | | | | ស្តង់ដារ GSP | ស្តង់ដារ MFN |
| ១. សម្លៀកបំពាក់, វាយនភណ្ឌ និងស្បែកជើង | សហភាពអឺរ៉ុប | (43%) | 0% | 8.5% | 11% |
| | សហរដ្ឋអាមេរិក | (24%) | 9.5% | 9.5% | 10.05% |
| | កាណាដា | (8%) | 0% | 10.7% | 15% |
| ២. ទោចក្រយាន | សហភាពអឺរ៉ុប | (86%) | 0% | 10.5% | 14.5% |
| | សហរដ្ឋអាមេរិក | (5%) | 0% | 7.3% | 8% |
| | កាណាដា | (3%) | 0% | 8.5% | 13% |
| ៣. អង្ករ | សហភាពអឺរ៉ុប | (48%) | 150 អឺរ៉ូ/តោន** | 175 អឺរ៉ូ/តោន/ | 175 អឺរ៉ូ/តោន/ |
| | សហរដ្ឋអាមេរិក | (0.4%) | 0% | USD140/ តោន | 11.2% or USD140/ តោន |
| | កាណាដា | (0.1%) | 0% | 0% | 0% |
| ៤. ផលិតផលដទៃ | សហភាពអឺរ៉ុប | (4%) | 0% | 2.9% | 5.9% |
| | សហរដ្ឋអាមេរិក | (24%) | 0.5% | 1.8% | 4.9% |
| | កាណាដា | (2%) | 0% | 1.2% | 1.7% |

*ប្រភព : ទិន្នន័យពន្ធរបស់ UNCTAD and WTO (2019),*ភាគរយក្នុងវង់ក្រចក គឺអត្រាធៀបនឹងទីផ្សារនាំចេញ, ** អត្រាពន្ធនេះនឹងបញ្ចប់ក្នុងឆ្នាំ ២០២១*

ក្នុងន័យនេះ រាជរដ្ឋាភិបាលបានត្រៀមខ្លួនជាស្រេចដើម្បីដោះស្រាយបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងពាណិជ្ជកម្ម តាមរយៈការពង្រឹងកិច្ចសម្រួលពាណិជ្ជកម្ម, ការកែលម្អបរិយាកាសសម្រាប់ការនាំចេញ និងការលើកកម្ពស់ភាពប្រកួតប្រជែងខាងពាណិជ្ជកម្ម ។ ការបាត់បង់ភាពអនុគ្រោះផ្នែកពាណិជ្ជកម្ម នឹងអាចគ្រប់គ្រងបានតាមរយៈការបន្តចរចាលើកិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មសេរីទ្វេភាគី និងកិច្ចព្រមព្រៀងស្តីពីកិច្ចសហប្រតិបត្តិការភាពជាដៃគូ ដើម្បីរក្សាបានភាពអនុគ្រោះនានា ទាំងក្នុងដំណាក់កាលអន្តរកាល និងដំណាក់កាលបន្តបន្ទាប់ទៀត ។ ក្នុងន័យនេះ ការបន្តពង្រឹងសមត្ថភាពក្នុងការចរចាទ្វេភាគី និងពហុភាគីលើកិច្ចព្រមព្រៀងពាណិជ្ជកម្មទាំងនេះ គឺជាកិច្ចការចាំបាច់ ។

### *គោលនយោបាយសំខាន់ៗសម្រាប់ការឆ្លងផុតពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច*

ការឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួចនឹងអាចមកដល់នាពេលខាងមុខ ។ រាជរដ្ឋាភិបាលនឹងប្រកាន់យកអភិក្រមបុរេសកម្ម ដើម្បីរៀបចំផែនទីចង្កូលផ្លូវ និងវិធានការគោលនយោបាយសំខាន់ៗ រួមមាន÷

#### *១-ផែនទីចង្កូលផ្លូវសម្រាប់ការឆ្លងផុតពីឋានៈប្រទេសមានការអភិវឌ្ឍតិចតួច*

រាជរដ្ឋាភិបាលនឹងរៀបចំផែនការបឋម ដើម្បីគិតគូរអំពីគន្លងផ្លូវដែលត្រូវដំណើរការ, តម្រូវការនៃការចាកចេញ និងបញ្ហាប្រឈម ក៏ដូចជាផលប៉ះពាល់នានា ។ កិច្ចការនេះនឹងត្រូវរៀបចំដោយរួសរាន់ សម្រាប់ធ្វើជាផែនទីចង្កូលផ្លូវ ដើម្បីត្រៀមឆ្លើយតបទៅនឹងបញ្ហានានាពាក់ព័ន្ធនឹងបញ្ជីប្រទេសចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍ

តិចតួច ដែលនឹងត្រូវរៀបចំដោយគណៈកម្មាធិការគោលនយោបាយសម្រាប់កិច្ចអភិវឌ្ឍន៍ ក៏ដូចជាសម្រាប់រៀបចំ "យុទ្ធសាស្ត្រអន្តរកាល" សម្រាប់ដំណាក់កាលបន្ទាប់ ។ កិច្ចការនេះក៏តម្រូវឱ្យមានស្ថាប័ននាំមុខរបស់រាជរដ្ឋាភិបាល ដោយមានកិច្ចសហការជាមួយបណ្ដាក្រសួង និងស្ថាប័នពាក់ព័ន្ធនឹងដំណើរការនេះ ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងពិនិត្យលទ្ធភាពបង្កើតយន្តការក្រុមការងារថ្នាក់ជាតិ និងក្រុមការងារស្នូល ដោយមានការចូលរួមពីមន្ត្រីបង្គោលរបស់បណ្ដាក្រសួង និងស្ថាប័នពាក់ព័ន្ធ ។ ក្រុមការងារថ្នាក់ជាតិនេះនឹងចាត់តាំងក្រុមមន្ត្រីបង្គោលរបស់បណ្ដាក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីវាយតម្លៃផលប៉ះពាល់ដែលបណ្ដាលមកពីការចាកចេញនេះ និងលើកទៅពិភាក្សាក្នុងវេទិកានានា ។ រាជរដ្ឋាភិបាលនឹងផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីលើកកម្ពស់ការយល់ដឹងរបស់សាធារណជន អំពីលទ្ធភាពនៃការចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ដែលជាកិច្ចការសំខាន់ក្នុងកិច្ចដំណើរការអភិវឌ្ឍន៍កម្ពុជា ក្នុងភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំ របស់រាជរដ្ឋាភិបាល ។ ទន្ទឹមនឹងនេះ ការគាំទ្រធនធាន និងបច្ចេកទេស នៅតែមានតួនាទីសំខាន់សម្រាប់គាំទ្រកិច្ចដំណើរការនេះ ។ រាជរដ្ឋាភិបាលនឹងដាក់បញ្ចូលយុទ្ធសាស្ត្រអន្តរកាលសម្រាប់ការចាកចេញនេះ ទៅក្នុងផែនការអភិវឌ្ឍន៍ជាតិ និងផែនការអភិវឌ្ឍន៍តាមវិស័យ ដើម្បីធានាឱ្យមានសង្គតិភាពជាមួយនឹងចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការសម្រេចឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ នាឆ្នាំ២០៣០ ។

ជាមួយគ្នានេះ ដោយមានការគាំទ្រពី UNDP និង UNESCAP, រាជរដ្ឋាភិបាលនឹងត្រៀមសហការជិតស្និទ្ធជាមួយស្ថាប័នពាក់ព័ន្ធ ដូចជា UNDESA និង UNCTAD ដើម្បីកំណត់បញ្ហាប្រឈម និងស្វែងរកការគាំទ្រ ព្រមទាំងប្រើប្រាស់យុទ្ធសាស្ត្រអន្តរកាលនេះ សម្រាប់ជាឧបករណ៍ក្នុងការកំណត់ និងដោះស្រាយបញ្ហានានាកម្រិតគោលនយោបាយ ក៏ដូចជាស្វែងរកការគាំទ្រផ្នែកហិរញ្ញប្បទានផងដែរ ។ ការចូលរួមរបស់តួអង្គពាក់ព័ន្ធដទៃទៀត ដើម្បីកំណត់បញ្ហាប្រឈម, កាលានុវត្តភាព ពិសេសការត្រួសត្រាយផ្លូវសម្រាប់ដំណាក់កាលអន្តរកាល គឺជាកិច្ចការសំខាន់ ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលលើកទឹកចិត្តឱ្យមានការគាំទ្រហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ តាមរយៈការផ្ដល់ធនធានម្ដងរួមគ្នា ឬតាមទម្រង់ផ្ដល់ដទៃទៀត រួមទាំងការបង្កើតមូលនិធិសម្រាប់កម្ពុជាចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍន៍តិចតួច ដើម្បីធានាប្រសិទ្ធភាព និងចីរភាពនៃការចាកចេញនេះ ។

### *២. វិធានការគោលនយោបាយ*

ដូចបានគូសបញ្ជាក់ខាងដើម, វិធានការគោលនយោបាយមានតួនាទីសំខាន់ជាផែនទីចង្អុលផ្លូវសម្រាប់ដំណើរការនៃការចាកផុតពីប្រទេសមានការអភិវឌ្ឍតិចតួច ដូចខាងក្រោម ÷

*ក-ការផ្លាស់ប្ដូររចនាសម្ព័ន្ធសេដ្ឋកិច្ច :* ភាពងាយរងគ្រោះខាងសេដ្ឋកិច្ច គឺជាលក្ខខណ្ឌវិនិច្ឆ័យចាំបាច់ក្នុងការកំណត់វឌ្ឍនភាពរបស់កម្ពុជាសម្រាប់ចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច ។ ក្នុងន័យនេះ ការបន្តអនុវត្តប្រកបដោយប្រសិទ្ធភាព នូវគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ និងគោលនយោបាយដទៃទៀត ពិសេសពាក់ព័ន្ធនឹងការពង្រីកវិស័យកម្មន្តសាល, សហគ្រាសតូច និងមធ្យម និងសេវា, ការលើកកម្ពស់ឧស្សាហូបនីយកម្ម, ការធ្វើពិពិធកម្មការនាំចេញ, ការធ្វើទំនើបកម្មកសិកម្ម និងការត្រៀមបង្ការគ្រោះ

មហន្តរាយ គឺជាកត្តាគន្លឹះសម្រាប់ពន្លឿនការកាត់បន្ថយភាពងាយរងគ្រោះខាងសេដ្ឋកិច្ច ដែលកិច្ចការនេះត្រូវបន្តអនុវត្ត ទោះបីកម្ពុជាបានឆ្លងផុតពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួចរួចហើយក៏ដោយ ។

*ខ-ហិរញ្ញវត្ថុសាធារណៈ* : ការចាកចេញពីប្រទេសមានការអភិវឌ្ឍតិចតួច អាចជះឥទ្ធិពលខ្លាំងក្លាដល់ហិរញ្ញវត្ថុសាធារណៈ ។ គោលនយោបាយគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធត្រឹមត្រូវ និងដោយប្រយ័ត្នប្រយែង នឹងជួយគាំទ្រដល់ការពង្រឹងសមត្ថភាព និងការបង្កើនភាពធន់នៃសេដ្ឋកិច្ច ។ ទន្ទឹមនឹងនេះ គោលនយោបាយរូបិយវត្ថុប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព (រួមទាំងបដិដុល្លារូបនីយកម្មជាបណ្តើរៗ) និងការអភិវឌ្ឍទីផ្សារហិរញ្ញវត្ថុ អាចបង្កើតស្វ័យតភាពក្នុងការគ្រប់គ្រងអត្រាការប្រាក់ និងថ្លៃចំណាយមូលធន ដើម្បីលើកទឹកចិត្តការវិនិយោគនៅក្នុងវិស័យផលិតកម្ម ។

*គ-ការកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ :* ដៃគូអភិវឌ្ឍន៍នឹងពិនិត្យឡើងវិញលើកម្មវិធី និងទម្រង់នៃការគាំទ្រ ។ ការថយចុះទំហំហិរញ្ញប្បទានឥតសំណង និងជំនួសដោយឥណទានសម្បទាន នឹងអាចកើតឡើងទន្ទឹមនឹងពេលដែលរាជរដ្ឋាភិបាលបន្តប្រឹងប្រែងកៀរគរធនធានក្នុងស្រុក ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងខិតខំរក្សាទំហំហិរញ្ញប្បទានឥតសំណងដូចបច្ចុប្បន្ន ទន្ទឹមនឹងការបង្កើនកៀរគរឥណទានសម្បទាន ។ រាជរដ្ឋាភិបាលនឹងបន្តអនុវត្តប្រកបដោយប្រសិទ្ធភាព នូវយុទ្ធសាស្ត្រស្តីពីការកៀរគរចំណូល ឆ្នាំ២០១៩-២០២៣ ។ ទន្ទឹមនឹងនេះ យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ ឆ្នាំ២០១៩-២០២៣ បានក្លាយជាឧបករណ៍គោលនយោបាយសំខាន់ សម្រាប់កៀរគរធនធានអភិវឌ្ឍន៍ ទាំងក្នុង និងក្រៅប្រទេស ។ ក្នុងពេលបច្ចុប្បន្ន កម្ពុជាប្រើប្រាស់ឱ្យអស់លទ្ធភាពនូវអត្ថប្រយោជន៍ទាំងឡាយដែលទទួលបានក្នុងឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួច និងត្រៀមលក្ខណៈសម្រាប់ការអភិវឌ្ឍនាពេលអនាគតផងដែរ ។

*ឃ-គោលនយោបាយ និងការពង្រឹងសមត្ថភាពផ្នែកពាណិជ្ជកម្ម :* កម្ពុជានឹងបន្តទំនាក់ទំនងជាមួយបណ្តាដៃគូពាណិជ្ជកម្ម ដើម្បីពិនិត្យលទ្ធភាពទទួលបានភាពអនុគ្រោះ និងសម្បទាននានា ។ រាជរដ្ឋាភិបាលបានប្រកាន់យកអភិក្រមបុរេសកម្ម ដើម្បីចរចាជាមួយដៃគូពាណិជ្ជកម្មទ្វេ និងពហុភាគី សំដៅបន្តទទួលបានអត្ថប្រយោជន៍បន្ទាប់ពីការចាកចេញពីប្រទេសមានការអភិវឌ្ឍតិចតួច ក៏ដូចជាក្នុងដំណាក់កាលអន្តរកាលផងដែរ ។ ការចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទ្វេភាគី បាន និងកំពុងអនុវត្តជាមួយដៃគូសំខាន់ៗ ។ រដ្ឋាភិបាលបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងជាមួយសាធារណរដ្ឋកូរ៉េ សម្រាប់សិក្សារួមគ្នាអំពីសមិទ្ធិលទ្ធភាពនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ។ រាជរដ្ឋាភិបាលក៏បានចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ជាមួយសាធារណរដ្ឋប្រជាមានិតចិន នាចុងឆ្នាំ២០១៩ ដោយក្រសួងពាណិជ្ជកម្មនៃប្រទេសទាំងពីរបានរៀបចំយន្តការកម្រិតបច្ចេកទេស សម្រាប់ផ្លាស់ប្តូរព័ត៌មានគ្នាទៅវិញទៅមក ហើយសង្ឃឹមថា កិច្ចព្រមព្រៀងនឹងត្រូវចុះហត្ថលេខាក្នុងពេលដ៏ខ្លីខាងមុខនេះ ។

រាជរដ្ឋាភិបាលបាន និងកំពុងពង្រឹងសមត្ថភាពសម្រាប់ចរចាកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់ ដើម្បីធ្វើពិពិធកម្មការទំនិញនាំចេញ និងទីផ្សារ ។ ទន្ទឹមនឹងនេះ ក៏បានគិតគូរដល់កិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគីជាមួយដៃគូសំខាន់ដទៃទៀត ដូចជាជប៉ុន, ឥណ្ឌា, អូស្ត្រាលី និងនូវែលសេឡង់ ក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន +១ និងភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) ។ ការពង្រីកដៃគូ

ពាណិជ្ជកម្មដទៃទៀត ដូចជាសហភាពសេដ្ឋកិច្ចអឺរ៉ាស៊ី (EAEU) និងដៃគូទ្វេភាគីដទៃទៀត ក៏ជាកិច្ចការសំខាន់ដែលត្រូវបន្តយកចិត្តទុកដាក់ផងដែរ ។

*ង-ហេដ្ឋារចនាសម្ព័ន្ធ និងឡូជីស្ទីក :* ការបន្តកែលម្អហេដ្ឋារចនាសម្ព័ន្ធ, ឡូជីស្ទីក និងគោលនយោបាយវិនិយោគ គឺជាកិច្ចការគន្លឹះ សម្រាប់ជំរុញ និងទាក់ទាញការវិនិយោគបន្ថែមក្នុងវិស័យឧស្សាហកម្មថ្មីៗ ។ ចំណាយលើការដឹកជញ្ជូន និងឡូជីស្ទីក នឹងត្រូវកាត់បន្ថយបន្ថែមទៀត តាមរយៈការបន្តសាងសង់ និងកែលម្អផ្លូវថ្នល់, ការអភិវឌ្ឍផ្លូវល្បឿនលឿន, ប្រព័ន្ធដឹកជញ្ជូនផ្លូវដែក, កំពង់ផែ, ប្រព័ន្ធគយអេឡិចត្រូនិច និងការពន្លឿនបែបបទតាមច្រកព្រំដែន, ការលើកកម្ពស់ការតភ្ជាប់ក្នុងផ្ទៃប្រទេស និងតំបន់ និងការបន្តចរចាលើកិច្ចព្រមព្រៀងស្តីពីការដឹកជញ្ជូនឆ្លងដែនក្នុងតំបន់ ។ ការលើកកម្ពស់កិច្ចសម្រួលពាណិជ្ជកម្ម, ការកែលម្អបរិស្ថានធុរកិច្ច និងការកែទម្រង់រដ្ឋបាលសាធារណៈ សុទ្ធសឹងតែជាកិច្ចការសំខាន់ និងចាំបាច់សម្រាប់បន្តកាត់បន្ថយចំណាយ និងលើកកម្ពស់ភាពប្រកួតប្រជែងនៃវិស័យផលិតកម្ម ។

*ច-ការលើកកម្ពស់ការវិនិយោគ :* ការបន្តលើកកម្ពស់កិត្យានុភាពកម្ពុជា គឺជាកិច្ចការមានសារៈសំខាន់ ដើម្បីជំរុញការវិនិយោគបន្ថែមក្នុងវិស័យឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់, មានបច្ចេកវិទ្យា និងដែលប្រើប្រាស់ទុនវិនិយោគច្រើន ។ គោលដៅទាំងនេះអាចសម្រេចបាន តាមរយៈការពិនិត្យឡើងវិញនូវច្បាប់ស្តីពីការវិនិយោគ និងច្បាប់ស្តីពីតំបន់សេដ្ឋកិច្ចពិសេស ដើម្បីកែលម្អបរិស្ថានវិនិយោគ, ពង្រីកការផ្តល់ការលើកទឹកចិត្តក្រៅពីពន្ធដារ, ពង្រឹងការប្រកួតប្រជែង និងបង្កើនផលិតភាព ។ ច្បាប់ទាំងនេះនឹងជំរុញឱ្យមានកិច្ចប្រឹងប្រែងបន្ថែមទៀត ដើម្បីលើកកម្ពស់អភិបាលកិច្ច រួមទាំងបទប្បញ្ញត្តិប្រកបដោយគុណភាព, កិច្ចគាំពារការវិនិយោគ, ការអនុម័តឆាប់រហ័ស និងប្រកបដោយតម្លាភាពលើគម្រោងវិនិយោគ និងអនុលោមភាពនៃកិច្ចដំណើរការ ។

*ឆ-ជំនាញ និងផលិតភាព :* ការផ្តល់ការលើកទឹកចិត្តគប្បីផ្សារភ្ជាប់ជាមួយនឹងការបណ្តុះបណ្តាលជំនាញ និងលទ្ធកម្មក្នុងស្រុក ដែលជាការតម្រូវយ៉ាងម៉ឺងម៉ាត់សម្រាប់វិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញរបស់ប្រទេសដែលមិនមែនជាប្រទេសមានការអភិវឌ្ឍតិចតួច ។ ទន្ទឹមនឹងនេះ គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ នឹងត្រូវបន្តអនុវត្តប្រកបដោយប្រសិទ្ធភាព ដើម្បីប្រែក្លាយពីខឿនឧស្សាហកម្មអតិពលកម្មឱ្យទៅជាខឿនឧស្សាហកម្មផ្អែកលើជំនាញ ។ ការលើកកម្ពស់ការបណ្តុះបណ្តាលជំនាញ, ការដាក់ឱ្យអនុវត្តនូវពាណិជ្ជកម្មអេឡិចត្រូនិច, ការកើនឡើងការប្រើប្រាស់គ្រឿងចក្រក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម, ការចាប់ផ្តើមអាជីវកម្មថ្មីៗ, ការលើកកម្ពស់នវានុវត្តន៍បច្ចេកវិទ្យា និងការលើកទឹកចិត្តក្នុងការផ្ទេរបច្ចេកវិទ្យា គឺជាអាទិភាពជាយុទ្ធសាស្ត្រសម្រាប់លើកកម្ពស់សមត្ថភាព ។ លើសពីនេះ ការអភិវឌ្ឍធនធានមនុស្ស និងការសិក្សាស្រាវជ្រាវ ក៏ជាអាទិភាពសម្រាប់អភិវឌ្ឍចំណេះដឹង និងសមត្ថភាពរបស់ប្រជាជនកម្ពុជា ដើម្បីឈានទៅពង្រឹងសមត្ថភាព, សមិទ្ធកម្ម និងផលិតភាពជាតិ និងស្ថាប័ន ។

ជារួម ការងារគន្លឹះគឺការបន្តជំរុញផលិតភាព និងភាពប្រកួតប្រជែងរបស់កម្ពុជា តាមរយៈការលើកកម្ពស់សមត្ថភាពផលិតកម្ម និងការផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ការលើកកម្ពស់សមត្ថភាពផលិតកម្មតម្រូវឱ្យមានគោលនយោបាយគ្រប់ជ្រុងជ្រោយក្នុងការកែទម្រង់អភិបាលកិច្ច, គោលនយោបាយម៉ាក្រូសេដ្ឋកិច្ច

និងសារពើពន្ធប្រកបដោយភាពប្រយ័ត្នប្រយែង, គោលនយោបាយសង្គមកិច្ច, គោលនយោបាយវិស័យឧស្សាហកម្ម និងគោលនយោបាយតាមវិស័យ ។ ការចាកចេញពីក្រុមប្រទេសមានការអភិវឌ្ឍតិចតួច តម្រូវឱ្យផ្តល់អាទិភាពខ្ពស់ទៅលើកិច្ចការទាំងនេះ ។

# ជំពូកទី ៧
# ការគ្រប់គ្រងដោយផ្ដោតលើលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព

## ការវិវត្តបន្ទាប់ពីអភិក្រមស្ដីពីការគ្រប់គ្រងដោយផ្ដោតលើលទ្ធផលនៃកិច្ចអភិវឌ្ឍន៍

ដើម្បីតម្រឹមជាមួយនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព សហគមន៍អន្តរជាតិបានកែសម្រួលគោលការណ៍ស្ដីពីការគ្រប់គ្រងដោយផ្ដោតលើលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ និងបន្តអនុវត្តអភិក្រមស្ដីពីគ្រប់គ្រងដោយផ្ដោតលើលទ្ធផល តាមរយៈការដាក់ឱ្យអនុវត្តគោលការណ៍ថ្មី គឺការគ្រប់គ្រងដោយផ្ដោតលើលទ្ធផលនៃកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព (Managing for Sustainable Development Results-MfSDR) ដែលអាចដំណើរការទន្ទឹមគ្នានឹងគោលការណ៍ស្ដីពីស័ក្តិសិទ្ធិភាពនៃកិច្ចអភិវឌ្ឍន៍ និងអាចជួយពង្រឹងឱ្យគ្នាទៅវិញទៅមក ។

